**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economique

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃអច្ច័យទាននៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **តេង ធិត្យដារ៉ា**

**អ៊ា ប៊ុងហុង**

សាស្ត្រាចារ្យណែនាំ

លោក **ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **គេង និត្យដារ៉ា** និងខ្ញុំបាទ **អ៊ិរ ម៉ិងហុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ យើងខ្ញុំសូមសម្តែងនូវសេចក្តីកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតជូនចំពោះ ៖

**លោកឪពុក អ្នកម្តាយ អ្នកអាណាព្យាបាល** ដែលលោកមានគុណដ៏សែនមហាធំធេងចំពោះរូបកូនដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវក្តីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌អប់រំទូន្មានប្រៀនប្រដៅ និង ទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឱ្យកូនបានរៀនសូត្រដល់បច្ចុប្បន្ននេះ ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបាទចូលសិក្សានៅសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ ។

**លោកសាស្ត្រាចារ្យ ជិន ចណ្ណារ៉ា** ជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀន ព្រមទាំងផ្តល់អនុសាសន៍ និង ការណែនាំ ដើម្បីរៀបចំសារណាបញ្ចប់ការសិក្សានេះ ។

**គណៈគ្រប់គ្រងសាកលវិទ្យាល័យ សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកសិក្សា** សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្ហាត់បង្រៀន និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សាយើងខ្ញុំ ។

សូមសម្តែងនូវសេចក្តីអំណរគុណយ៉ាងជ្រាវជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាវជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងពីយើងខ្ញុំ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមបួងសួងដល់ទេវតាឱ្យប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមឱ្យបានប្រកបតែជោគជ័យគ្រប់ភារកិច្ចការងារ និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសុភមង្គលកុំបីឃ្លៀងឃ្លាតឡើយ ។

# **អារម្ភកថា**

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សាស្ត្រាចារ្យ ជាទីគោរព !

ជាបឋម ខ្ញុំបាទ **តេខ ឧិត្យដារ៉ា** និងខ្ញុំបាទ **អ៊ា ម៉ុខហុខ** សូមគោរពជាថ្មីម្តងទៀតដល់ លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសនិស្សិត ជាទីរាប់អាន ។

ក្នុងនាមយើងខ្ញុំ ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី " **របបគតិយុត្តនៃអច្ច័យទាននៅកម្ពុជា** " នេះឡើង ដោយសារមើលឃើញថា ការរស់នៅរបស់ប្រជាជនខ្មែរបច្ចុប្បន្នកំពុងស្ថិតក្នុងលក្ខខណ្ឌអភិវឌ្ឍ សេដ្ឋកិច្ចក៏មានការរីកចំរើន ប៉ុន្តែបញ្ហាទំនាក់ទំនងទ្រព្យសម្បត្តិនៅតែកើតមានឡើងជារឿយៗ បញ្ហារវាង អ្នកនៅរស់និងអ្នកនៅរស់ បញ្ហារវាងបងប្អូន ឬបញ្ហាមរតកជាដើម ។ ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិនេះផងដែរ យើងក៏ឃើញមានបញ្ហាស្មុកស្មាញជាច្រើន ជាហេតុនាំឲ្យយើងទាំងពីរអ្នកបានសម្រេចចិត្តក្នុងការរៀបចំសារណា ក្រោមប្រធានបទមួយនេះ ព្រមទាំងមានការគាំទ្រ និងលើកទឹកចិត្តបង្ហាញយ៉ាងពេញទំហឹងពីសំណាក់ លោកសាស្ត្រាចារ្យ **ខិន ទណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងការយល់ដឹងអំពី **"របបគតិយុត្តិនៃអច្ច័យទាននៅក្នុងប្រទេសកម្ពុជា"** ដែលកន្លងមកប្រជាជនខ្មែរយើងមិនបានចាប់អារម្មណ៍ពីការធ្វើមរតកក្នុងការរស់នៅរបស់ខ្លួន ដោយមិនបានដឹងថាមានគុណប្រយោជន៍អ្វីខ្លះ អំពីទំនាក់ទំនងរវាងសង្គម និង មរតក និងនៅពេលដែលទទួលមរណភាព ដោយមូលហេតុណាមួយ ដូចជា ភាពចាស់ជរា ឧបទ្ទវហេតុ ជំងឺប្រចាំកាយ ជាដើម ហើយយើងខ្ញុំសង្ឃឹមទៀតថា សារណាមួយនេះនឹងក្លាយជាឯកសារស្រាវជ្រាវ ដែលបាន នឹងកំពុងជួបប្រទះនូវកង្វះខាតផងដែរ ។

យើងខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងឡាយដែលមាននៅ ក្នុងសារណានេះ យើងខ្ញុំរង់ចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់មិត្តអ្នកអានទាំងអស់គ្នា ។

ជាចុងក្រោយនេះ សូមជូនពរដល់អ្នកអានគ្រប់រូបឱ្យជួបប្រទះតែនឹងភាពសុខដុមរមនារុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ០១

## ជំពូកទី ១
## សញ្ញាណទូទៅនៃអច្ច័យទាន

**ផ្នែកទី១៖ សាវតារនៃអច្ច័យទាន** ........ ៣

កថាខណ្ឌទី១- ការអនុវត្តក្នុងជីវិតរស់នៅរបស់ប្រជាជន ........ ៣

កថាខណ្ឌទី២- វត្តមានក្នុងក្រមរដ្ឋប្បវេណីចាស់កម្ពុជាឆ្នាំ១៩២០ ........ ៤

**ផ្នែកទី២៖ អច្ច័យទានជាផ្នែកមួយនៃសន្តតិកម្ម** ........ ៤

កថាខណ្ឌទី១- សញ្ញាណនៃសន្តតិកម្មតាមច្បាប់ ........ ៥

កថាខណ្ឌទី២- ខ្លឹមសារនៃសន្តតិកម្មតាមមតកសាសន៍ ........ ៦

**ផ្នែកទី៣៖ សញ្ញាណបឋមនៃអច្ច័យទាន** ........ ៦

កថាខណ្ឌទី១- និយមន័យនៃអច្ច័យទាន ........ ៦

កថាខណ្ឌទី២- បុគ្គលដែលជាអច្ច័យលាភី ........ ៧

កថាខណ្ឌទី៣- ទំនាក់ទំនងរវាងអច្ច័យទាន និងប្រទានកម្ម ........ ៧

**ផ្នែកទី៤៖ ប្រភេទនៃអច្ច័យទាន** ........ ៨

កថាខណ្ឌទី១- អច្ច័យទានមានកំណត់ ........ ៨

កថាខណ្ឌទី២- អច្ច័យទានសកល ........ ៩

កថាខណ្ឌទី៣- ករណីដោយឡែកដែលអច្ច័យទានមានភ្ជាប់បន្ទុក ........ ៩

**ផ្នែកទី៥៖ គោលការណ៍ដែលមិនអាចបំពានភាគបម្រុងរបស់សន្តតិជន** ........ ១០

## ជំពូកទី ២
## ការបង្កើតអច្ច័យទាន

**ផ្នែកទី១៖ សមាសភាពអច្ច័យលាភី និងម្ចាស់បណ្តាំ** ........ ១១

កថាខណ្ឌទី១- សមាសភាពអច្ច័យលាភី ........ ១១

១.១. ករណីទូទៅនៃសមាសភាពអច្ច័យលាភី ........ ១១

១.១.១. អច្ច័យលាភីជានីតិជន ........ ១១

១.១.២. អច្ច័យលាភីជាអនីតិជនទទួលអត្តាធីនភាព ........ ១១

១.២. ករណីដោយឡែកនៃសមាសភាពអច្ច័យលាភី ..... ១២
១.២.១. អច្ច័យលាភីជាជននៅក្រោមអាណាព្យាបាលទូទៅ ..... ១២
១.២.២. ជននៅក្រោមហិតូបត្ថម្ភ ..... ១៣
១.២.៣. អច្ច័យលាភីជាអនីតិជនគ្មានអត្តាធីនភាព ..... ១៣
១.២.៤. អច្ច័យលាភីជាទារកក្នុងគ៌ភ ..... ១៤
កថាខណ្ឌទី២- សមាសភាពម្ចាស់បណ្តាំ ..... ១៤
២.១. ករណីទូទៅនៃសមាសភាពម្ចាស់បណ្តាំ ..... ១៥
២.១.១. ម្ចាស់បណ្តាំជានីតិជន ..... ១៥
២.១.២. ម្ចាស់បណ្តាំជាអនីតិជនទទួលបានអត្តាធីនភាព ..... ១៥
២.២. ករណីដោយឡែកនៃសមាសភាពម្ចាស់បណ្តាំ ..... ១៥
២.២.១. ប្រសិនបើម្ចាស់បណ្តាំជាជននៅក្រោមអាណាព្យាបាលទូទៅ ..... ១៥
២.២.២. ប្រសិនបើម្ចាស់បណ្តាំជាជននៅក្រោមហិតូបត្ថម្ភ ..... ១៦
**ផ្នែកទី២៖ គោលការណ៍សមត្ថភាពខាងឆន្ទៈក្នុងការធ្វើអច្ច័យទាន** ..... ១៧
កថាខណ្ឌទី១ សមត្ថភាពធ្វើអច្ច័យទានរបស់ម្ចាស់បណ្តាំ ..... ១៧
កថាខណ្ឌទី២ ករណីម្ចាស់បណ្តាំខ្វះសមត្ថភាពខាងឆន្ទៈ ..... ១៧
**ផ្នែកទី៣៖ ទម្រង់នៃអច្ច័យទាន** ..... ១៨
កថាខណ្ឌទី១- វិធីធម្មតា ..... ១៨
១.១. អច្ច័យទានដោយលិខិតយថាភូត ..... ១៨
១.២. អច្ច័យទានដោយលិខិតឯកជន ..... ១៩
១.៣. អច្ច័យទានដោយលិខិតសម្ងាត់ ..... ២០
កថាខណ្ឌទី២- វិធីដោយឡែក ..... ២១
២.១. ករណីម្ចាស់បណ្តាំជាជននៅក្រោមអាណាព្យាបាលទូទៅ ..... ២២
២.២. ករណីម្ចាស់បណ្តាំជាជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ..... ២៣
២.៣. ករណីម្ចាស់បណ្តាំជាជនបានជាប់ឃុំឃាំងជាអាទិ៍ ..... ២៤
២.៤. ករណីម្ចាស់បណ្តាំជាបុគ្គលដែលមិនអាចនិយាយបាន ..... ២៥
**ផ្នែកទី៤៖ កម្មវត្ថុនៃអច្ច័យទាន** ..... ២៥
កថាខណ្ឌទី១- ការធ្វើអនុប្បទាននូវអចលនវត្ថុ និងចលនវត្ថុ ..... ២៥

១.១. ការធ្វើអនុប្បទានអចលនវត្ថុ ........................................................................ ២៥
១.២. ការធ្វើអនុប្បទានចលនវត្ថុ ........................................................................ ២៥
កថាខណ្ឌទី២- ករណីដោយឡែកនៃកម្មវត្ថុនៃអច្ច័យទាន ........................................ ២៦
២.១. ឧបាទេសកម្មនៃសិទ្ធិលើវត្ថុ ........................................................................ ២៦
២.២. ឧបាទេសកម្មនៃសិទ្ធិលើបំណុល ........................................................................ ២៦
កថាខណ្ឌទី៣- ករណីដោយឡែកផ្សេងទៀតនៃកម្មវត្ថុនៃអច្ច័យទាន ........................................ ២៧
៣.១. កម្មសិទ្ធិអវិភាគ ........................................................................ ២៧
៣.២. សិទ្ធិជួលអចិន្ត្រៃយ៍ ........................................................................ ២៨
**ផ្នែកទី៥៖ សិទ្ធិរបស់ម្ចាស់បណ្ដាំចំពោះអច្ច័យទានអំឡុងពេលមុនទទួលមរណភាព** ..២៨
កថាខណ្ឌទី១- សិទ្ធិកែប្រែ ឬការលុបចោលលិខិតអច្ច័យទាន ........................................ ២៨
កថាខណ្ឌទី២- សិទ្ធិជាកម្មសិទ្ធិករលើកម្មវត្ថុនៃអច្ច័យទាន ........................................ ២៩

## ជំពូកទី ៣

## អានុភាពនៃអច្ច័យទាន

**ផ្នែកទី១៖ មរណភាពរបស់ម្ចាស់បណ្ដាំ** ........................................................................ ៣១
កថាខណ្ឌទី១- មរណភាពរបស់ម្ចាស់បណ្ដាំដោយធម្មជាតិ ........................................ ៣១
កថាខណ្ឌទី២- មរណភាពរបស់ម្ចាស់បណ្ដាំដោយការប្រកាសអំពីការបាត់ខ្លួន ........................ ៣២
**ផ្នែកទី២៖ ករណីដោយឡែកនៃអច្ច័យលាភីដែលទទួលមរណភាព ឬក្លាយជាអភ័ព្វបុគ្គល** ........................................ ៣៣
កថាខណ្ឌទី១- ករណីអច្ច័យលាភីទទួលមរណភាព ........................................ ៣៣
១.១. ប្រសិនបើអច្ច័យលាភីទទួលមរណភាពមុនម្ចាស់បណ្ដាំ ........................................ ៣៣
១.២. ប្រសិនបើអច្ច័យលាភីជាសន្តតិជន ហើយសន្តតិជនបានទទួលមរណភាព ដោយមិនបានស្គាល់ ឬបោះបង់អច្ច័យទាន ........................................ ៣៣
កថាខណ្ឌទី២- ករណីអច្ច័យលាភីក្លាយជាអភ័ព្វបុគ្គល ........................................ ៣៤
**ផ្នែកទី៣៖ ករណីមានការដាស់តឿនរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ទៅកាន់អច្ច័យលាភី** ........................................ ៣៥
កថាខណ្ឌទី១- បុគ្គលដែលជាជនពាក់ព័ន្ធនឹងផលប្រយោជន៍នៃអច្ច័យទាន ........................ ៣៥
កថាខណ្ឌទី២- អានុភាពនៃការដាស់តឿន ........................................ ៣៥

**ផ្នែកទី៤៖ ករណីពិសេសអច្ច័យទានមានភ្ជាប់លក្ខខណ្ឌ** ....................................... ៣៦
កថាខណ្ឌទី១- អច្ច័យទានមានភ្ជាប់បន្ទុក ....................................... ៣៦
១.១. អច្ច័យលាភីទទួលខុសត្រូវមានកម្រិតនៅក្នុងអច្ច័យទានភ្ជាប់បន្ទុក ....................................... ៣៦
១.២. ករណីតម្លៃនៃកម្មវត្ថុនៃអច្ច័យទានត្រូវបានកាត់បន្ថយ ....................................... ៣៧
១.៣. ករណីដោយឡែកនៃការលុបចោលអច្ច័យទានភ្ជាប់បន្ទុក ....................................... ៣៨
កថាខណ្ឌទី២- អច្ច័យទានមានលក្ខខណ្ឌបង្អង់ ....................................... ៣៩
កថាខណ្ឌទី៣- កម្មវត្ថុនៃអច្ច័យទានភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន ....................................... ៤០

## ជំពូកទី ៤

## សិទ្ធិរបស់អច្ច័យលាភី

**ផ្នែកទី១៖ ការទទួលស្គាល់ និការបោះបង់អច្ច័យទានមានកំណត់** ....................................... ៤១
**ផ្នែកទី២៖ ការទទួលស្គាល់ និងការបោះបង់អច្ច័យទានសកល** ....................................... ៤១
កថាខណ្ឌទី១- ការទទួលស្គាល់អច្ច័យទានសកល ....................................... ៤១
១.១. ការយល់ព្រមទាំងស្រុង ....................................... ៤២
១.២. ការយល់ព្រមដោយមានកម្រិត ....................................... ៤២
១.២.១. នីតិវិធីនៃការយល់ព្រមដោយមានកម្រិត ....................................... ៤២
១.២.២. ករណីអច្ច័យលាភីជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ....................................... ៤៣
១.២.៣. ករណីអច្ច័យលាភីជាជននៅក្រោមហិតូបត្ថម្ភ ....................................... ៤៣
កថាខណ្ឌទី២- ការបោះបង់អច្ច័យទានសកល ....................................... ៤៣
២.១. នីតិវិធីនៃការបោះបង់ ....................................... ៤៤
២.២. ករណីអច្ច័យលាភីសកលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ....................................... ៤៤
**ផ្នែកទី៣៖ ករណីដោយឡែកនៃការទទួលស្គាល់ ឬបោះបង់ ដែលអច្ច័យលាភីជាសន្តតិជន** ....................................... ៤៤
**ផ្នែកទី៤៖ ករណីដោយឡែកនៃការលុបចោលនូវការទទួលស្គាល់ ឬការបោះបង់អច្ច័យទាន** ....................................... ៤៤
កថាខណ្ឌទី១- មូលហេតុនៃវិការៈនៃការទទួលស្គាល់ ឬការបោះបង់អច្ច័យទាន ....................................... ៤៤
កថាខណ្ឌទី២- អាជ្ញាយុកាលនៃសិទ្ធិលុបចោលនូវការទទួលស្គាល់ ឬការបោះបង់អច្ច័យទាន ....................................... ៤៦

២.១. ចិរវេលា ៦ ខែ គិតចាប់ពីពេលអាចផ្ដល់សច្ចានុមតិ.......................................... ៤៦
២.២. ចិរវេលា ៥ ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម.....................................៤៧
**សេចក្ដីសន្និដ្ឋាន**.............................................................................................................. ៤៩
**អនុសាសន៍**.................................................................................................................... ៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សូរសម្លេងអ៊ូអរបានកើតចេញពីមនុស្សមួយហ្វូងធំ ហាក់បីដូចជាមានភាពខ្វែងគំនិតនឹងដំណោះស្រាយរបស់ភាគីម្ខាងៗ ជាមួយនឹងអាកាសធាតុនៃខ្យល់ល្អបរិសុទ្ធ ក៏ត្រូវបានប្រែក្លាយទៅជាអាប់អួរណែនតាន់តាប់ ។ ទង់មរណៈបក់រវិចៗ នៅពីមុខភូមិគ្រឹះដ៏ធំស្កឹមស្កៃ លាយឡំនឹងសំនៀងពិណពាទ្យដ៏ស្រទន់ ធាតុពិតកូនចៅគួរម្ចីម្នារៀបចំបុណ្យសពឪពុក តែបែរជាបង្កើតឡើងនូវបញ្ហាមរតកឱ្យមានភាពចម្រូងចម្រាសគ្នាទៅវិញ ។ នេះអាចជាបរិបទមួយដែលកំពុងនឹងកែប្រែស្មារតីរបស់មនុស្សឱ្យធ្លាក់ទៅសភាពនៃស្បែអន្ធកាល លោភលន់ ដោយភ្លេចពីកំណើតនៃឈាមជ័រតែមួយ ។ ក្នុងនោះផងដែរ ច្បាប់ក៏បានចូលខ្លួនមកសម្រួលដល់បញ្ហានេះ ដោយឱ្យមានយន្តការសន្តតិកម្ម ដើរតួនាទីយ៉ាងសំខាន់សម្រាប់ដោះស្រាយវិបត្តិទាំងនេះ ។

តាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្នកាលនេះមក ការរស់នៅក្នុងសង្គមខ្មែរ ក៏ដូចជាការរស់នៅរបស់ប្រជាជននៅលើពិភពលោកទាំងមូល ការវិវត្តន៍នៃការការរស់នៅពីសម័យមួយទៅសម័យមួយ យើងឃើញថាមានការផ្លាស់ប្តូរទាំងបរិបទសង្គម និងការរស់នៅក្នុងសង្គមផងដែរ ដោយយើងបានឃើញជាក់ស្តែងនៅក្នុងរឿងព្រេងជាច្រើន ដែលបាននិយាយពីការឈ្លោះប្រកែកគ្នានឹងមរតកជាដើម ។ ក្នុងន័យនេះ ទើបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិទទួលស្គាល់នូវកម្មសិទ្ធិឯកជនក្នុងគោលបំណង ដើម្បីធានាដល់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗខិតខំស្វែងរកដោយលំបាកនោះ ។ ពាក្យថាកម្មសិទ្ធិ គឺ អាស្រ័យទៅលើសិទ្ធិក្នុងការកាន់កាប់អាស្រ័យផល និងសិទ្ធិក្នុងការចាត់ចែងដោយកម្មសិទ្ធិករ មានន័យថា កម្មសិទ្ធិករមានសិទ្ធិយ៉ាងទូលំទូលាយលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួនទាំងក្នុងពេលបច្ចុប្បន្ន ទៅអនាគត និងព្រមទាំងពេលទទួលមរណភាពផងដែរថាតើនឹងត្រូវធ្វើអច្ច័យទានដោយរបៀបណា ។ យើងដឹងហើយថាអច្ច័យទាន ជាប្រធានបទមួយដ៏ក្តៅគគុកចំពោះបណ្តាលនិស្សិតច្បាប់ ដែលទទួលបានការចាប់អារម្មណ៍ជាខ្លាំង ពីសំណាក់សង្គមនៃកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយសារបញ្ញត្តិស្តីពីអច្ច័យទាននៅកម្ពុជានៅមានលក្ខណៈចង្អៀត ឬអាចហៅបានថាពុំទាន់ទូលំទូលាយនៅឡើយ ។ បញ្ហាមួយចំនួនដែលទាក់ទងនឹងអច្ច័យទានពុំសូវបានជួបប្រទះដោយសារពុំមានសាលក្រម ឬសាលដីកាអំពីអច្ច័យទានច្រើននោះទេ នេះប្រហែលជាហេតុបណ្តាលមកពីប្រជាពលរដ្ឋមិនទាន់មានការយល់ដឹងទូលំទូលាយអំពីផ្នែកមត៌កនេះ ។

បច្ចុប្បន្ននេះកម្ពុជាកំពុងមានវត្តមានលើឆាកអន្តរជាតិជាច្រើនដូចជា ជាសមាជិកនៃអាស៊ាន ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងទំនាក់ទំនងជាមួយប្រទេសជាច្រើននៅលើពិភពលោក ក្នុងវិស័យពាណិជ្ជកម្មផ្សេងៗទៀតជាច្រើន ដោយសារប្រទេសមានភាពរីកចម្រើន ដូច្នេះហើយ ទើបនៅក្នុងបណ្តាលគ្រួសារមួយចំនួនក្នុងសង្គមក៏រកស៊ីទទួលទានមានបាននូវទ្រព្យសម្បត្តិស្តុកស្តម្ភ ហើយមនោសញ្ចេតនាក៏មិនអាចដូចគ្នា ឬស្មើគ្នា ផងដែរ ជាមូលហេតុនាំឱ្យមានការផ្តល់មកនូវទ្រព្យសម្បត្តិទៅសន្តតិជនមិនស្មើគ្នា ដោយ

មូលហេតុច្បាប់បានយល់ឃើញនូវសិទ្ធិរបស់ញាតិ ដើម្បីឱ្យមានតុល្យភាពនៃសិទ្ធិទើបបង្កើតជាអច្ច័យទាននេះឡើង ។ ការបង្កើតនេះក្នុងគោលបំណង ដើម្បីជួយសម្រួល ដល់បញ្ហាដែរនឹងកើតមានឱ្យមានភាពងាយស្រួលក្នុងការដោះស្រាយ និងដើម្បីភាពស្រុះស្រួល ចុះសម្រុងនៃប្រជាពលរដ្ឋ ។

ការលើកយកប្រធានបទស្ដីពី **"របបគតិយុត្តិនៃអច្ច័យទាននៅកម្ពុជា"** ដែលស្ថិតក្នុងគន្ថី៨ ជំពូកទី២ ផ្នែកទី៦ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាដែលអនុម័តក្នុងឆ្នាំ២០០៧ មកធ្វើការតាក់តែងជាសារណាបញ្ចប់ការសិក្សា គឺក្នុងគោលបំណងសិក្សាស្វែងយល់លម្អិតអំពីសារៈប្រយោជន៍ និងខ្លឹមសារនៃអច្ច័យទាន ។ ក្នុងនេះដែរ ដើម្បីឱ្យកាន់តែមានភាពស៊ីជម្រៅយើងមានធ្វើការបកស្រាយជា៣ជំពូកធំៗរួមមានៈ

ជំពូកទី១៖ សញ្ញាណទូទៅនៃអច្ច័យទាន

ជំពូកទី២៖ ការបង្កើតអច្ច័យទាន

ជំពូកទី៣៖ អានុភាពនៃអច្ច័យទាន

ជំពូកទី៤៖ សិទ្ធិរបស់អច្ច័យលាភី

# ជំពូកទី ១
# សញ្ញាណទូទៅនៃអច្ច័យទាន

ក្នុងជំពូកស្តីពី "សញ្ញាណទូទៅនៃអច្ច័យទាន" នេះមានការបង្ហាញផ្នែកធំៗចំនួន ៥ ហើយដែលក្នុងនោះរួមមានៈ

ផ្នែកទី១៖ សារតារនៃអច្ច័យទាន

ផ្នែកទី២៖ អច្ច័យទានជាផ្នែកមួយនេះសន្តតិកម្ម

ផ្នែកទី៣៖ សញ្ញាណបឋមនៃអច្ច័យទាន

ផ្នែកទី៤៖ ប្រភេទនៃអច្ច័យទាន

ផ្នែកទី៥៖ គោលការណ៍ដែលមិនអាចបំពានភាគបម្រុងរបស់សន្តតិជន

## ផ្នែកទី១៖ សារតារនៃអច្ច័យទាន

### កថាខណ្ឌទី១- ការអនុវត្តក្នុងជីវិតរស់នៅរបស់ប្រជាជន

ប្រជាជនខ្មែរ គឺជាប្រជាជននៃស្នាមញញឹម ដែលមានចិត្តទូលាយ មានក្តីអាណិតស្រលាញ់ និងចូលចិត្តចែករំលែក ហើយចំពោះការបែងចែងទ្រព្យសម្បត្តិរបស់ខ្លួនវិញ គឺតែងតែគិតគូដល់កូនចៅៗ ហើយករណីខ្លះផ្តល់ទ្រព្យសម្បត្តិដល់មនុស្សដែលមិនមែនជាសាច់ញាតិរបស់ខ្លួនក៏មានផងដែរក្នុងប្រការណាមួយ ។ ត្បិតថាមិនអាចកំណត់សម័យកាលថា ទម្លាប់នៃការបែងចែងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋខ្មែរមានលក្ខណៈបែបណាឬក៏ខុសគ្នាតាមតំបន់យ៉ាងណានោះ ក៏ប៉ុន្តែជាភាពសមហេតុផលដែលចាំបាច់ពិចារណាវែងឆ្ងាយនោះ គឺទ្រព្យសម្បត្តិរបស់អ្នកដែលស្លាប់នឹងត្រូវធ្លាក់ ឬបែងចែងឱ្យទៅសាច់ញាតិរបស់អ្នកដែលបានស្លាប់នោះ ។ ប៉ុន្តែការទទួលមរណភាព ដោយម្ចាស់ទ្រព្យមិនទាន់បានរៀបចំទុកដាក់បែងចែងទ្រព្យរបស់ខ្លួនឱ្យទៅសាច់ញាតិរបស់ពួកគាត់ឱ្យរួចស្រេចនោះ អាចនាំឱ្យមានជម្លោះប៉ះពាល់ទំនាក់ទំនងសាច់ញាតិ ។ ប៉ុន្តែការធ្វើលិខិតបណ្តាំទុកជាមុននោះ អាចចាត់ទុកជាបំណងរបស់ម្ចាស់ទ្រព្យ ពោលគឺជាការបង្ហាញឆន្ទៈរបស់មតកជនដែលគួរអនុវត្តតាមខ្លឹមសារនៃបណ្តាំនោះ ។ ក្នុងនោះដែរ និងជាធម្មតា ការបែងចែកទ្រព្យសម្បត្តិរបស់ឪពុក ម្តាយ ទៅកូនម្នាក់ៗ ពោលគឺការបែងចែងទ្រព្យរបស់មតកជនចំពោះសន្តតិជនអាចមានភាពលំអៀង ឬអាចបែងចែងទៅបុគ្គលដទៃក្រៅពីគ្រួសារទៀតផង ប៉ុន្តែទាំងនេះគឺជាឆន្ទៈដែលត្រូវគោរពតាម ប្រសិនបើមិនហួសហេតុពេក ។ ករណីនេះបញ្ជាក់ឱ្យឃើញថាក្នុងជីវភាពរស់នៅជាក់ស្តែងពីអតីតកាលរហូតដល់បច្ចុប្បន្នកាល បុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន ក្នុងនោះសន្តតិជនខ្លះទទួលបានចំណែកប៉ុណ្ណេះ សន្តតិជនខ្លះទទួលបានចំណែកប៉ុណ្ណោះ (ករណីសហសន្តតិជន) ។ ករណីខ្លះទៀតជនដែលមិនមែនជាសន្តតិជនត្រូវទទួលបានអំណោយពីមតកជនតាមរយៈខ្លឹមសារនៃលិខិតបណ្តាំនោះដែរ ដែលនេះគឺជាការសម្រេចចិត្ត និងជាបំណងរបស់មតកជនកាលនៅ

រស់រានមានជីវិត ។

### កថាខណ្ឌទី២- វត្តមានអច្ច័យទានក្នុងក្រមរដ្ឋប្បវេណីប្រទេសកម្ពុជាឆ្នាំ១៩២០

ដោយសារតែសកម្មភាពដែលបានកើតឡើងជាទម្លាប់ក្នុងជីវភាពរបស់ប្រជាពលរដ្ឋពីមួយជំនាន់ទៅមួយជំនាន់បែបនេះហើយ រហូតដល់សម័យកាលដែលមានការវិវត្តន៍ផ្នែកប្រព័ន្ធនយោបាយ និងការគ្រប់គ្រងរដ្ឋបាលដែលនាំឱ្យមានការបង្កើតច្បាប់ផ្សេងៗដើម្បីធានានូវដំណើរការរបស់សង្គមជាតិ ក្នុងនោះដែរប្រទេសកម្ពុជាបានមានវត្តមានជាលើកដំបូងនូវក្រមរដ្ឋប្បវេណីក្នុងឆ្នាំ១៩២០ ក្នុងសម័យកាលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមនិយមបារាំង ។ ក្រមរដ្ឋប្បវេណីប្រទេសកម្ពុជាដំបូង ដែលផ្អែកលើច្បាប់ណាប៉ូឡេអុង (Napoleon) ត្រូវបានព្រាង និងប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ១៧ ដោយព្រះបាទស៊ីសុវត្ថិ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ មានចំណងជើងថា "ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា" ។[1] ក្នុងគោលបំណងស្តារឡើងវិញនូវប្រជា_ប្រិយភាពអក្សរសាស្ត្រខ្មែរ លោក អេង សុត ដែលជាមន្ត្រីក្រសួងយុត្តិធម៌ (ក្នុងឆ្នាំ១៩៦៧) បានបកប្រែ និងបោះពុម្ពជាភាសាខ្មែរនូវក្រមរដ្ឋប្បវេណីនៅក្នុងឆ្នាំ១៩៦៧ ។[2] ក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ ចាប់ពីផ្អែកនេះទៅហៅថា "ក្រមរដ្ឋប្បវេណីចាស់" ហើយនៅក្នុងក្រមរដ្ឋប្បវេណីនោះទៀតសោតក៏មានបញ្ញត្តិអំពីអច្ច័យទានផងដែរ ខ្លឹមសារនៃអច្ច័យទានត្រូវបានចែងទុកចាប់ពីមាត្រា៥៧០ រហូតដល់មាត្រា៥៧៧ ស្ថិតក្នុងផ្នែកទី៨ ដែលមានចំណងជើងថា "អំពីអច្ច័យទាន" ហើយផ្នែកទី៨នេះស្ថិតក្នុងជំពូកទី៤ ដែលមានចំណងជើងថា "អំពីសន្តតិកម្មមានបណ្តាំ" ហើយនិងស្ថិតក្នុងមាតិកាទី៦នៃក្រម ដែលមានចំណងជើងធំថា "អំពីសិទ្ធិ និងកាតព្វកិច្ចទាំងឡាយលើបេតិកភណ្ឌក្នុងគ្រួសារ" ។ វត្តមាននៃអច្ច័យទានក្នុងក្រមរដ្ឋប្បវេណីចាស់គឺជាការសបញ្ជាក់ថាការបែងចែកទ្រព្យសម្បត្តិឱ្យទៅសន្តតិជន ឬមិនមែនជាសន្តតិជន មិនមែនជាការវិត្តន៍ថ្មីដែលទើបនឹងមានក្នុងក្រមរដ្ឋប្បវេណីថ្មីនាពេលបច្ចុប្បន្ននោះទេ ពោលគឺមានវត្តមាននៅក្នុងក្រមរដ្ឋប្បវេណីចាស់ មកម្ល៉េះ ។ សម្រាប់បច្ចុប្បន្នភាពនេះ ក្រមរដ្ឋប្បវេណីចាស់ ដែលបានអនុញ្ញាតប្រកាសឱ្យប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩២០ និងដែលត្រូវបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មិនមានអានុភាពឡើយ ។[3]

## ផ្នែកទី២៖ អច្ច័យទានជាផ្នែកមួយនៃសន្តតិកម្ម

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនឱ្យទៅសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់ ។[4] ជាការឈ្វេងយល់ បុគ្គលម្នាក់ដែលទទួលមរណភាពនឹងបាត់បង់សមត្ថភាពទទួលសិទ្ធិ ឬ

---

[1] Pecter Backer, *សេចក្តីផ្តើមក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា,* ៣ និង ៤

[2] Pecter Backer, *សេចក្តីផ្តើមក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា,* ៤

[3] មាត្រា៨២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, កាលបរិច្ឆេទចុះថ្ងៃទី៣១ ឧសភា ២០១១

[4] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី

បំពេញកាតព្វកិច្ច ពោលគឺមិនអាចតាំងខ្លួនជាកម្មសិទ្ធិករ ឬជាម្ចាស់បំណុលបានទៀតឡើយ ។ ដូចនេះហើយ ទាក់ទងនឹងទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ត្រូវមានការគិតគូរថា តើមានបុគ្គលណាផ្សេងទៀតនឹងត្រូវទទួលបន្តជាម្ចាស់សិទ្ធិថ្មីលើទ្រព្យសម្បត្តិទាំងនោះដែរឬទេ ? ចំណែកឯកាតព្វកិច្ចវិញ ប្រសិនបើគ្មានកូនបំណុលថ្មីទទួលបន្តទេនោះ សុវត្ថិភាពរបស់ម្ចាស់បំណុលក៏មិនអាចធានាបានដែរ ។ វិធានការទាំងឡាយទាក់ទងដល់ការទទួលបន្តនេះសុទ្ធតែត្រូវបានកំណត់នៅក្នុងបញ្ញត្តិនៃច្បាប់ស្តីពីសន្តតិកម្ម ។ បុគ្គលដែលនឹងទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចពីមនុស្សដែលស្លាប់ហៅថា "សន្តតិជន" រីឯបុគ្គលដែលធ្វើសន្តតិកម្មនោះហៅថា "មតកជន" ។

បុគ្គលដែលបានទទួលមរណភាពហៅថា "មតកជន" ចំណែកឯបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតដែលបានទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចពីមតកជនតាមរយៈសន្តតិកម្មហៅថា "សន្តតិជន" ។ ដើម្បីឱ្យមានគ្រប់លក្ខណៈសម្បត្តិជាសន្តតិជន បុគ្គលនោះត្រូវមានសមត្ថភាពអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន (សន្តតិ_ជនត្រូវតែនៅរស់រានមានជីវិតនៅពេលចាប់ផ្តើមសន្តតិកម្ម ប៉ុន្តែលើកលែងតែទារកនៅក្នុងគភ៌) ។

សន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ដែលហៅថា "សន្តតិកម្មតាមច្បាប់" ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជនដែលហៅថា "សន្តតិកម្មតាមមតកសាសន៍" ។

**កថាខណ្ឌទី១- សញ្ញាណនៃសន្តតិកម្មតាមច្បាប់**

សន្តតិកម្មតាមច្បាប់ គឺជាទម្រង់មួយនៃសន្តតិកម្មដែលត្រូវអនុវត្តទៅតាមការកំណត់របស់បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធនឹងសន្តតិជននៅក្នុងករណីដែលមតកជនមិនបានធ្វើបណ្តាំមត៌ក (មតកសាសន៍) ។[5] សន្តតិកម្មតាមច្បាប់ គឺជាសន្តតិកម្មដែលផ្អែកតាមបញ្ញត្តិច្បាប់ ពោលគឺអនុវត្តតាមខ្លឹមសារដែលមានកំណត់ទុកជាមុននៅក្នុងបញ្ញត្តិច្បាប់ ។ ចំពោះលំដាប់សន្តតិជនក្នុងការទទួលបាននូវចំណែកមត៌ក តាមសន្តតិកម្មតាមច្បាប់គឺមានតែបីលំដាប់តែប៉ុណ្ណោះដែលក្នុងនោះរួមមាន៖

លំដាប់ទី១គឺ "បច្ឆាញាតិ" ៖ កូននិងសន្តតិជនជំនួសរបស់ពួកគេ និងកូនសុំ ( សុំកូនពេញលេញ និងសុំកូនធម្មតា) ដោយក្នុងនោះបច្ឆាញាតិទទួលបានសិទ្ធិអាទិភាពក្នុងការទទួលបាននូវសន្តតិកម្មនោះ ហើយក៏បានរាប់បញ្ចូលទាំងកូនបង្កើត និងកូនសុំផងដែរ ។ ទោះបីជាការសុំកូនធម្មតាក្តី ការសុំកូនពេញលេញក្តីគឺសុទ្ធតែទទួលបាននូវចំណែកមត៌កស្មើៗគ្នា ។ ប្រសិនបើមតកជនពុំមានកូនតែមានចៅ ដូច្នេះចៅនោះនឹងត្រូវក្លាយជាសន្តតិជនជំនួសកូនរបស់មតកជន ហើយជាអ្នកទទួលចំណែកមត៌កនោះ ។ ប៉ុន្តែប្រសិនបើមិនមានសន្តតិជនជំនួសទេនោះ សន្តតិជនលំដាប់ទី២ ដែលជាបុព្វញាតិ ។

លំដាប់ទី២ គឺ "បុព្វញាតិ" ៖ ឪពុក ម្តាយ និង ជីដូនជីតានឹងចូលខ្លួនមកដើម្បីទទួលចំណែកមត៌ក ។

[5] មាត្រា១១៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រសិនបើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ក្នុងការទទួលសន្តតិកម្មទេនោះ ។ សន្តតិជនលំដាប់ទី៣ គឺបងប្អូនបង្កើត និងសន្តតិជនជំនួសរបស់ពួកគេ ប៉ុន្តែបញ្ចប់ត្រឹមក្មួយ ។

លំដាប់ទី៣គឺ "បងប្អូនបង្កើត និងសន្តតិជនជំនួសរបស់ពួកគេ ប៉ុន្តែបញ្ចប់ត្រឹមក្មួយ" ៖ បងប្អូនបង្កើត និងសន្តតិជនជំនួសរបស់ពួកគេដោយបញ្ចប់ត្រឹមក្មួយនឹងត្រូវក្លាយជាសន្តតិជន ។ បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗ ត្រូវបានចំណែកស្មើៗគ្នា ។

"សន្តតិជនជានិច្ច" ៖ ចំណែកឯសហព័ន្ធរបស់មតកជនវិញត្រូវក្លាយជាសន្តតិជនជានិច្ចមានន័យថានៅក្នុងករណីដែលសហព័ន្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្នុងលំដាប់ណាមួយនោះសហព័ន្ធត្រូវទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននោះដែរ ។

### កថាខណ្ឌទី២- ខ្លឹមសារនៃសន្តតិកម្មតាមមតកសាសន៍

សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជនហៅថា "សន្តតិកម្មមានលិខិតបណ្តាំ ឬ សន្តតិកម្មតាមមតកសាសន៍ ។[6]

មតកសាសន៍ គឺជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍បន្ទាប់ពីមរណភាពចំពោះជនដែលត្រូវបានសន្មតជាសន្តតិជន ហើយត្រូវបានសន្មតជាការកំណត់នូវវិធីបែងចែកមត៌ក ឬកំណត់ចំពោះមត៌ករបស់ខ្លួន ។ ការធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិចំពោះតតិយជនហៅថា "អច្ច័យទាន" ប្រសិនបើភាគបម្រុងរបស់សន្តតិជនត្រូវបំពាន នោះសន្តតិជនអាចទាមទារភាគបម្រុងដែលបាត់ ដោយកាត់បន្ថយប្រទានកម្មទាំងមូល ឬមួយផ្នែក ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" មានមត៌កសរុបដូចជា៖ ផ្ទះមួយល្វែង រថយន្តមួយគ្រឿង និងទឹកប្រាក់ចំនួន ១២,០០០ USD ។ ម្ចាស់បណ្តាំបានធ្វើមតកសាសន៍ដោយក្នុងនោះប្រគល់ឱ្យសន្តតិជនដែលមានចំនួន ២នាក់ ។ ក្នុងនោះម្ចាស់បណ្តាំបានបែងចែកឱ្យសន្តតិជន "ខ" នូវរថយន្តមួយគ្រឿង និងទឹកប្រាក់សុទ្ធចំនួន ១០,០០០ USD ហើយដែលរថយន្តនោះមានតម្លៃលក់ប្រមាណ ៤០,០០០ USD រីឯសន្តតិជន "គ" បានទទួលនូវផ្ទះមួយល្វែង ដែលមានតម្លៃលក់ប្រមាណ ៦០,០០០ USD និងទឹកប្រាក់សុទ្ធចំនួន ២,០០០ USD ។

## ផ្នែកទី៣៖ សញ្ញាណបឋមនៃអច្ច័យទាន

### កថាខណ្ឌទី១- និយមន័យនៃអច្ច័យទាន

ដោយយោងតាមសទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី បានផ្តល់និយមន័យឱ្យ "អច្ច័យទាន" គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាម

[6] មាត្រា១១៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

រយៈមតកសាសន៍ ហើយបុគ្គលដែលបានទទួលអច្ច័យទាននោះ ហៅថា "អច្ច័យលាភី" ។ អច្ច័យទាន គឺជាសកម្មភាពនៃការផ្តល់អំណោយឱ្យទៅមនុស្សម្នាក់ ឬច្រើននាក់ នូវទ្រព្យសម្បត្តិរបស់ខ្លួនដែលជាកម្មសិទ្ធករ ។ យោងតាមមាត្រា១១៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អច្ច័យទានមានពីរប្រភេទ គឺអច្ច័យទានមានកំណត់ និង អច្ច័យទានសកល ។

**កថាខណ្ឌទី២- បុគ្គលដែលជាអច្ច័យលាភី**

ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់បញ្ញត្តិនៃអច្ច័យទាន មិនបានចែងបង្ហាញថាអច្ច័យលាភីជាមួយនឹងម្ចាស់បណ្តាំមានទំនាក់ទំនងថ្នាក់ញាតិ ឬស្ថិតនៅក្នុងស្ថានភាពបែបណាជាមួយគ្នាទេ ដោយយោងតាមសទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី បានផ្តល់និយមន័យដល់ "អច្ច័យលាភី" យ៉ាងខ្លីថាជាបុគ្គលដែលបានទទួលអច្ច័យទាន ។ ក្នុងន័យនេះ បុគ្គលដែលជាអច្ច័យលាភី គឺអាស្រ័យលើការកំណត់របស់ម្ចាស់បណ្តាំនៅក្នុងលិខិតអច្ច័យទាន ។ ផ្ទុយពីសន្តតិជន នៃសន្តតិកម្ម ដែលត្រូវបានកំណត់ច្បាស់លាស់ដោយបញ្ញត្តិច្បាប់ ។ ភាពទូលាយនៃបុគ្គលដែលជាអច្ច័យលាភី គឺគ្រប់រូបវន្តបុគ្គលសុទ្ធតែអាចក្លាយជាអច្ច័យលាភីដោយផ្អែកទៅលើការឆន្ទៈរបស់ម្ចាស់បណ្តាំ ហើយដែលក្នុងនោះសូម្បីតែសន្តតិជនរបស់ម្ចាស់បណ្តាំក៏អាចជាអច្ច័យលាភីនៃអច្ច័យទានបានដែរ ។ និងដោយយោងតាមបទបង្ហាញស្តីពី "អច្ច័យទាន" របស់ Masao SHIMANUKI នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៧ បានបញ្ជាក់ថា អច្ច័យលាភី គឺជាជនដែលទទួលអច្ច័យទាន ហើយជាទូទៅ គឺជាជនដែលមិនមែនសន្តតិជន ប៉ុន្តែក៏មានករណី សន្តតិជនជាអច្ច័យលាភីផងដែរ ។[7]

ឧទាហរណ៍៖ ក- ម្ចាស់បណ្តាំ "ក" និងមានសន្តតិជនចំនួន ៤នាក់ គឺសន្តតិជន "ខ" "គ" "ឃ" និង "ង" ។ ម្ចាស់បណ្តាំ "ក" បានធ្វើមតកសាសន៍បែងចែងទ្រព្យឱ្យសន្តតិជនទាំង៤នាក់ ។ ប៉ុន្តែក្នុងការបែងចែងមតក៏នោះ ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទានបន្ថែមឱ្យទៅសន្តតិជន "គ" ។

ខ- ម្ចាស់បណ្តាំ "ក" និងមានសន្តតិជនចំនួន ៤នាក់ គឺសន្តតិជន "ខ" "គ" "ឃ" និង "ង" ។ ម្ចាស់បណ្តាំ "ក" បានធ្វើមតកសាសន៍បែងចែងទ្រព្យឱ្យសន្តតិជនទាំង៤នាក់ ។ ប៉ុន្តែក្នុងការបែងចែងមតក៏នោះ ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទាននូវចំណែកមត៌កឱ្យទៅបុគ្គលម្នាក់ទៀតជាតតិយជន ។

**កថាខណ្ឌទី៣- ទំនាក់ទំនងរវាងអច្ច័យទាន និងប្រទានកម្ម**

ជានិយមន័យ "អច្ច័យទាន" គឺជាប្រទានកម្មដែលម្ចាស់បណ្តាំជាកម្មសិទ្ធិករបានធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍ ។[8] ដើម្បីឱ្យយល់កាន់តែស៊ីជម្រៅអំពីអច្ច័យទាននេះ

[7] *បទបង្ហាញស្តីពី "អច្ច័យទាន"* របស់ Masao SHIMANUKI, ២២ តុលា ២០១៧

[8] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី

ជាបន្តយើងគប្បីយល់នូវអត្ថន័យនៃ "ប្រទានកម្ម" សំដៅទៅលើកិច្ចសន្យាមួយដែលត្រូវមានអានុភាព ដោយម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល ។[9] បន្ថែមលើសពីនេះទៀតករណីប្រទានកម្មដោយមូលហេតុមរណភាព ដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក គឺត្រូវអនុវត្តដូចគ្នានឹងអច្ច័យទាន ។[10] អច្ច័យទាន គឺមានចរិតជាប្រទានកម្ម ។

ប្រទានកម្ម គឺជាកិច្ចសន្យាដែលតម្រូវឱ្យមានការព្រមព្រៀងរវាងទាយក និងបដិគ្គាហក ហើយកិច្ចសន្យាប្រទានកម្មនេះអាចត្រូវបានបង្កើតឡើងដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីប៉ុណ្ណោះ ដោយឡែកចំពោះការបង្កើតអច្ច័យទានក៏មានចំនុចសំខាន់ដូចនឹងការបង្កើតកិច្ចសន្យាប្រទានកម្ម ដែលសុទ្ធសឹងជាប្រភេទនៃកិច្ចសន្យាមុជា ឬកិច្ចសន្យាឯកតោភាគី ។ ដើម្បីបង្កើតកិច្ចសន្យាអច្ច័យទាន គឺសំខាន់ផ្អែកលើការព្រមព្រៀងរវាងអ្នកឱ្យ និងអ្នកទទួល ពោលគឺរវាងម្ចាស់បណ្តាំ និងអច្ច័យលាភី ។ ប៉ុន្តែជាលក្ខណៈពិសេសខុសពីប្រទានកម្ម ម្ចាស់បណ្តាំបានបង្ហាញការព្រមព្រៀងជាឯកតោភាគីនៅក្នុងលិខិតមតកសាសន៍ ដែលភាគីអច្ច័យលាភីមិនអាចដឹងខ្លួនមុនឡើយ ហើយបើទោះបីជាដឹងខ្លួនមុនថាជាភាគីអច្ច័យលាភីក៏ដោយ រហូតដល់តែម្ចាស់បណ្តាំទទួលមរណភាព ទើបភាគីអច្ច័យលាភីមានសិទ្ធិបង្ហាញឆន្ទៈយល់ព្រម ឬបដិសេធទទួលអច្ច័យទាននោះ ។

## ផ្នែកទី៤៖ ប្រភេទនៃអច្ច័យទាន

### កថាខណ្ឌទី១- អច្ច័យទានមានកំណត់

អច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ឱ្យទៅមនុស្សម្នាក់ ឬច្រើននាក់តាមរយៈមតកសាសន៍ ។[11] និងយោងតាមក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ បានផ្តល់និយមន័យឱ្យ អច្ច័យទានមានកំណត់ សំដៅដល់ការណ៍ដែលម្ចាស់បណ្តាំឱ្យវត្ថុតែ មួយមុខ ឬច្រើនមុខមានកំណត់ ហើយហៅថាអច្ច័យទានដោយចំពោះវត្ថុ ។[12] អច្ច័យទានមានកំណត់ គឺជាអច្ច័យទានដែលមានកម្មវត្ថុជាទ្រព្យសម្បត្តិជាក់លាក់មានចំនួន ឬបរិមាណច្បាស់លាស់ ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" មានមត៌កសរុបរួមមាន ផ្ទះល្វែងតម្លៃ ១០០,000 USD រថយន្តចំនួនពីរតម្លៃហាងឆេង ៦,៥000 USD និងប្រាក់សុទ្ធគិតជាប្រាក់ដុល្លារចំនួន ៣០,000 USD ។ អត្ថន័យនៅក្នុងលិខិតបណ្តាំ ម្ចាស់បណ្តាំបានសរសេរដោយធ្វើអច្ច័យទាននូវរថយន្តចំនួនពីរគ្រឿងឱ្យទៅអច្ច័យលាភី "ខ" ។ ករណីនេះគឺជាប្រភេទ "អច្ច័យទានមានកំណត់" ។

---

[9] មាត្រា៥៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[10] មាត្រា៥៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[11] មាត្រា១១៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[12] មាត្រា៥៧០ នៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០

**កថាខណ្ឌទី២- អច្ច័យទានសកល**

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើឱ្យទៅមនុស្សម្នាក់ ឬច្រើននាក់ជាក់លាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់តាមភាគនៃទ្រព្យតាមរយៈមតកសាសន៍ (ទាំងអស់ , ពាក់កណ្តាល , មួយភាគបីជាអាទិ៍) ។[13] និងយោងតាមក្រមរដ្ឋប្បវេណីចាស់ អច្ច័យទានសកល សំដៅដល់សិទ្ធិដែលម្ចាស់បណ្តាំអាចលើកបេតិកភណ្ឌទាំងអស់ឱ្យទៅជាអច្ច័យទានដល់អ្នកណាតែម្នាក់ក៏បាន ហើយម្ចាស់បណ្តាំអាចផ្តាំឱ្យចែកបេតិកភណ្ឌរបស់ខ្លួនទាំងអស់ដល់មនុស្សច្រើននាក់ គឺឱ្យម្នាក់ៗបាននូវភាគមួយៗ បេតិកភណ្ឌទាំងអស់របស់ខ្លួនទៅក៏បាន ។[14] អច្ច័យលាភីនៃអច្ច័យទានសកល មានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងសន្តតិជន ។[15]

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" មានមត៌កសរុបរួមមាន ផ្ទះល្វែងតម្លៃ ១០០,០០០ USD រថយន្តចំនួនពីរតម្លៃហាងឆេង ៦,៥០០០ USD និងប្រាក់សុទ្ធគិតជាប្រាក់ដុល្លារចំនួន ៣០,០០០ USD ។ អត្ថន័យនៅក្នុងលិខិតបណ្តាំ ម្ចាស់បណ្តាំបានសរសេរដោយធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិចំនួន ១ភាគ៣ នៃមត៌កសរុបឱ្យទៅអច្ច័យលាភី "ខ" ។ ករណីនេះគឺជាប្រភេទ "អច្ច័យទានសកល" ។

**កថាខណ្ឌទី៣- ករណីដោយឡែកដែលអច្ច័យទានមានភ្ជាប់បន្ទុក**

អច្ច័យទានមានភ្ជាប់បន្ទុក គឺជាអច្ច័យទានដែលតម្រូវឱ្យអច្ច័យលាភីទទួលករណីយកិច្ចមួយចំនួនកំណត់ដោយមតកជនក្នុងមតកសាសន៍ ។ ក្នុងអច្ច័យទានមានភ្ជាប់បន្ទុកនេះមិនស្ថិតនៅក្នុងប្រភេទនៃអច្ច័យទានណាមួយនោះទេ ពោលគឺទាំងអច្ច័យទានសកល និង អច្ច័យទានមានកំណត់អាចក្លាយជាអច្ច័យទានភ្ជាប់បន្ទុកអាស្រ័យលើខ្លឹមសារនៃអច្ច័យទាននោះជាក់ស្តែងដែលមតកជនបានកំណត់ឱ្យអច្ច័យលាភី ។

ឧទាហរណ៍៖ ក- ម្ចាស់បណ្តាំ "ក" បានធ្វើលិខិតមតកសាសន៍ដោយក្នុងនោះធ្វើអច្ច័យទាននូវចំណែកមត៌កចំនួន១ភាគ១០ នៃមត៌កសរុបឱ្យទៅភាគី "ខ" ដែលជាអច្ច័យលាភី ប៉ុន្តែតម្រូវឱ្យភាគី "ខ" បង់ប្រាក់ឱ្យភាគី "គ" ជាតតិយជនម្នាក់ទៀតនូវទឹកប្រាក់សុទ្ធចំនួន ៥០០ USD ។

ខ- បុរស "ច" ជាម្ចាស់បណ្តាំបានធ្វើមតកសាសន៍ដោយបានសរសេរថាធ្វើអច្ច័យទានដោយប្រគល់ដីមួយកន្លែងទំហំ១ហិកតាទៅឱ្យបុរស "ឆ" ប៉ុន្តែបុរស "ឆ" ត្រូវបង់ប្រាក់ចំនួន៥០០ USD ទៅឱ្យស្ត្រី "ជ" និងបង់ប្រាក់ចំនួន ១,០០០ USD ទៅឱ្យបុរស "ឈ" ។

គ- បុរស "ច" ជាម្ចាស់បណ្តាំបានធ្វើមតកសាសន៍ដោយបានសរសរថាធ្វើអច្ច័យទានដោយប្រគល់ឡានតូយ៉ូតាស៊េរីឆ្នាំ២០១០ចំនួន១គ្រឿងទៅឱ្យបុរស "ឆ" ប៉ុន្តែបុរស "ឆ" ត្រូវបង់ប្រាក់៩០០ USDទៅឱ្យបុរស "ជ" ។

---

[13] មាត្រា១១៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[14] មាត្រា៥៧០ នៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០

[15] មាត្រា១២១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ផ្នែកទី៥៖ គោលការណ៍ដែលមិនអាចបំពានភាគបម្រុងរបស់សន្តតិជន

យោងតាមសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ភាគ៣ បានបញ្ជាក់ថា ភាគបម្រុង គឺជារបបដែលធានាឱ្យបាននូវចំណែកមត៌ករបស់សន្តតិជនដើម្បីការពារផលប្រយោជន៍របស់សន្តតិជននោះ ដែលក្នុងន័យនេះ សន្តតិជនម្នាក់ៗត្រូវទទួលបានយ៉ាងហោចក៏ភាគបម្រុងរបស់ខ្លួនដែរ ហើយដែលមិនអាចបំពានបាន ។[16] អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្ត ពោលគឺសន្តតិជន និងសន្តតិជនជំនួស អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទានជាអាទិ៍ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបានត្រឹមកម្រិតដែលចាំបាច់ថែរក្សាភាគបម្រុងនោះ ។ បើទោះបីជាមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅអច្ច័យលាភីដែលមិនមែនជា សន្តតិជនក៏ដោយ ក៏សន្តតិជននៅតែមានសិទ្ធិទទួលបានចំណែកភាគបម្រុងរបស់ខ្លួន ។[17]

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" មានសន្តតិជនចំនួន ៣នាក់ គឺ "ខ" "គ" និង "ឃ" និងមានមត៌កសរុបចំនួន ១០០០០ USD ។ ប៉ុន្តែខ្លួនបែរជាធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិទាំងអស់ឱ្យទៅ តតិយជន "ង" ។ ក្នុងករណីនេះ ក្រោយពេលដែលម្ចាស់បណ្តាំ "ក" ទទួលមរណភាព ហើយប្រសិនបើភាគីអច្ច័យលាភី "ង" ទទួលយកអច្ច័យទាននេះ សន្តតិជនទាំង៣នាក់ មានសិទ្ធិទាមទារចំណែកភាគបម្រុងរបស់ខ្លួនទៅតាមបញ្ញត្តិច្បាប់ ។

[16] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧,ភាគ៣,ទំព័រ៧៧

[17] មាត្រា១២១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី ២

# ការបង្កើតអច្ច័យទាន

ក្នុងជំពូកស្តីពី "ការបង្កើតអច្ច័យទាន" នេះមានការបង្ហាញផ្នែកធំៗចំនួន ៥ ហើយនៅក្នុងនោះរួមមាន៖

ផ្នែកទី១៖ សមាសភាពអច្ច័យលាភី និងម្ចាស់បណ្តាំ

ផ្នែកទី២៖ គោលការណ៍សមត្ថភាពខាងឆន្ទៈក្នុងការបង្កើតអច្ច័យទាន

ផ្នែកទី៣៖ ទម្រង់នៃអច្ច័យទាន

ផ្នែកទី៤៖ កម្មវត្ថុនៃអច្ច័យទាន

ផ្នែកទី៥៖ សិទ្ធិរបស់ម្ចាស់បណ្តាំចំពោះអច្ច័យទានអំឡុងពេលមុនទទួលមរណភាព

## ផ្នែកទី១៖ សមាសភាពអច្ច័យលាភី និងម្ចាស់បណ្តាំ

### កថាខណ្ឌទី១- សមាសភាពអច្ច័យលាភី

#### ១.១. ករណីទូទៅនៃសមាសភាពអច្ច័យលាភី

##### ១.១.១. អច្ច័យលាភីជានីតិជន

នីតិជន គឺជាជនទាំងឡាយដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ។ គ្រប់ជនទាំងអស់មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។[18] ក្នុងការក្លាយជាម្ចាស់កម្មសិទ្ធិ សំដៅទៅលើកម្មសិទ្ធិករដែលមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត ។[19] ចំពោះការទទួលយកអំណោយ នីតិជនមានសិទ្ធិពេញលេញក្នុងទទួលយកអំណោយនោះដោយស្របច្បាប់ ។ ដូចនេះ នីតិជនដែលជាជនដល់អាយុនៃនីតិភាពមានសិទ្ធិក្លាយជាអច្ច័យលាភីទទួលយកអច្ច័យទាន ។

##### ១.១.២. អច្ច័យលាភីជាអនីតិជនទទួលបានអត្តាធីនភាព

អនីតិជនដែលទទួលបានអត្តាធីនភាពត្រូវបានចាត់ទុកថាបានដល់នីតិភាព ពោលគឺមានភាពដូចគ្នានឹងនីតិជន ។[20] លក្ខខណ្ឌដើម្បីឱ្យអនីតិជនទទួលបានអត្តាធីនភាពរួមមាន៖

(១) បានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឬអាចហៅថាមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ

(២) មានសមត្ថភាពទ្រទ្រង់ជីវភាពខ្លួនដោយឯករាជ្យ

(៣) បុគ្គលជាអនីតិជនត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីទទួលអត្តាធីនភាព

(៤) តុលាការធ្វើការសាកសួរយោបល់ពីអ្នកមានសិទ្ធិមានអំណាចមេបា

---

[18] មាត្រា៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[19] មាត្រា១៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[20] មាត្រា២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

(៥) តុលាការធ្វើការសម្រេចក្នុងការផ្តល់អត្តាធីនភាពដែលជាផលប្រយោជន៍ដល់អនីតិជន

ករណីមួយទៀត អនីតិជននឹងត្រូវបានទទួលអត្តាធីនភាពតាមរយៈការរៀបអាពាហ៍ពិពាហ៍ ។ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។[21] ចំពោះការទទួលយកអំណោយ អនីតិជនដែលទទួលបានអត្តាធីនភាពមានឋានៈ និងសិទ្ធិដូចនឹងនីតិជនដែរ ។

### ១.២. ករណីដោយឡែកនៃសមាសភាពអច្ច័យលាភី

#### ១.២.១. អច្ច័យលាភីជាជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅដល់ជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។

ឧទាហរណ៍៖

(១) ជនដែលមិនអាចទៅទិញអីវ៉ាន់ប្រចាំថ្ងៃដោយខ្លួនឯងបាន ហើយចាំបាច់ត្រូវមានអ្នកណាធ្វើជំនួស

(២) ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងរៀងរាល់ថ្ងៃ (ឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួននៅ ជាដើម)

(៣) ជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ស្ថានភាពស្លាប់ខួរក្បាល) ។[22]

ដើម្បីកំណត់ថាជននោះគឺជាជនក្រោមអាណាព្យាបាលទូទៅពេញលក្ខណៈច្បាប់ លុះត្រាតែជននោះបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ។[23] ការដាក់ពាក្យសុំឱ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ លុះត្រាតែសាមីខ្លួនមានអាយុយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំនៅពេលដាក់ពាក្យសុំ ។ ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅគឺជាភារកិច្ចរបស់តុលាការ ដែលធ្វើឡើងតាមរយៈពាក្យសុំសាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិ_ជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ ។ ចំពោះសកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅដែលធ្វើឡើងដោយផ្ទាល់អាចលុបចោលបាន លើកលែងតែសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងនោះដែរសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃជាដើម ។ ក្នុងន័យនេះដែរ ការធ្វើអំណោយទៅជននៅក្រោមអាណាព្យាបាលទូទៅក្នុងទម្រង់ជា អច្ច័យទានត្រូវមានការយល់ព្រមពីអ្នកអាណា_ព្យាបាលទូទៅរបស់ជននៅក្រោមអាណាព្យាបាលនោះ ។ ដូចនេះ ជននៅក្រោមអាណាព្យាបាលទូទៅមានសិទ្ធិ

---

[21] មាត្រា២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[22] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,២០០៩-២០១០,ភាគ១,ទំព័រ១៨

[23] មាត្រា២៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្លាយជាអច្ច័យលាភីដើម្បីទទួលយកអច្ច័យទានបានលុះត្រាតែមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ។

### ១.២.២. អច្ច័យលាភីជាជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមហិតូបត្ថម្ភ សំដៅទៅលើអ្នកដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ ដើម្បីកំណត់ថាជននោះគឺជាជននៅក្រោមហិតូបត្ថម្ភពេញលក្ខណៈច្បាប់ លុះត្រាតែជននោះបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។[24] ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភគឺជាភារកិច្ចរបស់តុលាការ ដែលធ្វើឡើងតាមរយៈពាក្យសុំសាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ ។ ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសន្តតិកម្ម ឬការបែងចែកនូវមត៌ក អាចលុបចោលបាន ប្រសិនបើសកម្មភាពទាំងនេះធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភឯកឯងដែលគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ។[25] ក្នុងន័យនេះ សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើឡើងទាក់ទងនឹងការទទួលស្គាល់ ឬបោះបង់អច្ច័យទាន ពុំមែនដាច់ខាតត្រូវតែលុបចោលនោះទេ ។ ដូចនេះ ហិតូបត្ថម្ភមានសិទ្ធិក្លាយជាអច្ច័យលាភីដើម្បីទទួលយកអច្ច័យទានបានលុះត្រាតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ ប៉ុន្តែមិនមែនជាករណីដាច់ខាតឡើយ ។

### ១.២.៣- អច្ច័យលាភីជាអនីតិជនគ្មានអត្តាធីនភាព

ផ្ទុយពីអនីតិជនទទួលបានអត្តាធីនភាព អនីតិជនដែលគ្មានអត្តាធីនភាព ស្ថិតនៅក្នុងប្រភេទនៃជនដែលត្រូវបានកម្រិតសមត្ថភាព ។[26] សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាគោលការណ៍អាចលុបចោលបាន ។[27] ប៉ុន្តែចំពោះសកម្មភាពទទួលសិទ្ធិ ឬសកម្មភាពឱ្យរួចផុតពីការទទួលយកកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ មិនចាំបាច់ឱ្យមានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ ។ យោងតាមមាត្រា ១០៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបង្ហាញថា អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និងក្នុងការតំណាងឱ្យកូននោះ

[24] មាត្រា២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[25] មាត្រា៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[26] មាត្រា១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[27] មាត្រា១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ចំពោះសកម្មភាពដែលទាក់ ទងទៅនឹងទ្រព្យសម្បត្តិនោះ ។[28] អនីតិជនអាចទទួលបាននូវទ្រព្យសម្បត្តិតាមរយៈ សន្តតិកម្ម ប្រទានកម្ម សំណងនៃការខូចខាត ឬប្រាក់ដែលបានមកពីការធានារ៉ាប់រងជាអាទិ៍ ។ អនីតិជនគ្មានអត្តាធីនភាពដែលជាជនមិនទាន់ដល់អាយុនៃនីតិភាពមានសិទ្ធិក្លាយ ជាអច្ច័យលាភីក្នុងការទទួលយកកម្មវត្ថុនៃអច្ច័យទានដោយតម្រូវឱ្យមានអ្នកមានអំណាចមេបាជាអ្នកតំណាង ។

ដូចនេះការធ្វើប្រទានកម្មជាអច្ច័យទានដល់អនីតិជនដែលគ្មានអត្តាធីនភាពមានន័យស្មើនឹងការផ្តល់សិទ្ធិដល់អនីតិជនប្រភេទនេះក្នុងការសម្រេចចិត្តទទួលយកប្រទានកម្ម ។

### ១.២.៤- អច្ច័យលាភីជាទារកក្នុងគភ៌

ទារកដែលនៅក្នុងគភ៌មានសិទ្ធិទទួលមត៌កដោយសន្តតិកម្ម ដែលក្នុងនោះក៏មាននូវអច្ច័យទានផងដែរ ។ ទារកក្នុងគភ៌នាពេលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌កដោយសន្តតិកម្មនោះបាន ។[29] ទារកក្នុងគភ៌ដែលមានកំណើតមកមានលក្ខណៈមិនខុសពីអនីតិជននោះទេ ដែលក្នុងន័យនេះ អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ឆ្នាំ ។ ប្រសិនបើអនីតិជនមានសិទ្ធិទទួលអច្ច័យទានដែលមានអ្នកមានអំណាចមេបាជាអ្នកតំណាង នោះទារកដែលកើតមកនោះក៏មានសិទ្ធិទទួលអច្ច័យទានបានដែរ ដោយចាំបាច់មានអ្នកមានអំណាចមេបាជាអ្នកតំណាង ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" ជាជីតាដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យ ក្នុងនោះខ្លួនបានធ្វើលិខិតបណ្តាំបែងចែកទ្រព្យសម្បត្តិឱ្យទៅសន្តតិជន ជាមួយគ្នានេះដែរក៏បានធ្វើអច្ច័យទាននូវដី១ហិកតានៅខេត្តកំពតឱ្យទៅចៅដែលកូនស្រីរបស់ខ្លួនកំពុងពរពោះ ។ ក្នុងករណីនេះ ប្រសិនបើទារកក្នុងគ៌ភបានកើតមក មុន ឬក្រោយពេលម្ចាស់បណ្តាំ "ក" ទទួលមរណភាព នោះឱ្យទារកនោះមានសិទ្ធិទទួលយកកម្មវត្ថុនៃអច្ច័យទាននោះដែលមានឪពុកម្តាយជាអ្នកមានអំណាចមេបា គឺជាតំណាងក្នុងគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

## កថាខណ្ឌទី២- សមាសភាពម្ចាស់បណ្តាំ

យោងតាមមាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី១ បានកំណត់យ៉ាងច្បាស់នូវបុគ្គលដែលអាចធ្វើមតកសាសន៍បាន ដោយក្នុងនោះមានតែបុគ្គលដែលជានីតិជន និង អនីតិជនទទួលអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា មានសិទ្ធិធ្វើមតកសាសន៍ ។ បើទោះបីជាពុំបានកំណត់ថាជនដទៃក្រៅពីនីតិជន និងអនីតិជនទទួលអត្តាធីនភាព អាចធ្វើមតកសាសន៍បាន ប៉ុន្តែត្រង់កថាខណ្ឌទី២ នៃមាត្រាដដែលនោះ បានកំណត់ពីការហាមប្រាមប្រើប្រាស់សិទ្ធិលុបចោលសកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ ក្នុងករណីដែលជនទាំងពីរប្រភេទនេះបានធ្វើមតកសាសន៍ ។ ជារួម

[28] មាត្រា១០៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[29] មាត្រា៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រភេទជនដែលអាចធ្វើមតកសាសន៍បានមានដូចជាៈ ទីមួយ នីតិជន ទីពីរ អនីតិជនដែលទទួលបានអត្តា_ធីនភាព ទីបី ជននៅក្រោមអាណាព្យាបាលទូទៅ និងទីបួន ជននៅក្រោមហិតូបត្ថម្ភ ។

### ២.១. ករណីទូទៅនៃសមាសភាពម្ចាស់បណ្ដាំ

#### ២.១.១. ម្ចាស់បណ្ដាំជានីតិជន

នីតិជន គឺជាជនដែលមាននីតិភាពក្នុងការធ្វើសកម្មភាពផ្សេងៗដោយស្របច្បាប់ ។ នីតិជនមានសិទ្ធិក្នុងការក្លាយជាកម្មសិទ្ធិករដោយស្របច្បាប់ ។ ដូចនេះ នីតិជនពិតជាមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនក្នុងទម្រង់សន្តតិកម្ម ឬអច្ច័យទានជាអំណោយទៅបុគ្គលដទៃ ។

#### ២.១.២. ម្ចាស់បណ្ដាំជាអនីតិជនទទួលបានអត្តាធីនភាព

អនីតិជនទទួលបានអត្តាធីនភាព គឺមាននីតិភាពក្នុងការធ្វើសកម្មភាពផ្សេងៗដោយស្របច្បាប់ដូចនីតិ_ជនផងដែរ ។ ក្នុងន័យនេះអនីតិជនទទួលបានអត្តាធីនភាពមានសិទ្ធិក្នុងក្លាយជាកម្មសិទ្ធិករដោយស្របច្បាប់។ ដូចនេះ អនីតិជនមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួន និងរួមទាំងការធ្វើសន្តតិកម្ម ឬការធ្វើប្រទានកម្ម ឬការធ្វើអច្ច័យទានឱ្យទៅសន្តតិជន ឬតតិយជន ។

ផ្ទុយទៅវិញចំពោះអនីតិជនគ្មានអត្តាធីនភាព ពោលគឺសំដៅលើអនីតិជន ។ ជាទូទៅអនីតិជនពុំមានសិទ្ធិធ្វើសកម្មភាពណាមួយដែលត្រូវបានចាត់ទុកថាស្របច្បាប់នោះទេ លើកលែងតែសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងការទទួលសិទ្ធិ ។ ដោយឡែកចំពោះការធ្វើមតកសាសន៍ អនីតិជនពុំមានសិទ្ធិក្នុងការធ្វើមតកសាសន៍ក្នុងទម្រង់ណាមួយនោះឡើយ ។ ជាគោលការណ៍ អនីតិជនមិនអាចធ្វើមតកសាសន៍បានទេលុះត្រាតែជននោះទទួលបានអត្តាធីនភាព ។[30]

ឧទាហរណ៍ៈ ក្មេងប្រុស "ក" មានវ័យ ១៦ឆ្នាំ ហើយធ្លាប់បានទទួលបានអត្តាធីនភាពតាមរយៈការប្រកាសរបស់តុលាការ ។ ក្មេងប្រុស "ក" មានទ្រព្យសម្បត្តិផ្ទាល់ខ្លួនមួយចំនួនតាមការធ្វើអច្ច័យទានពីជីតារបស់ខ្លួន និងមានមុខរបរផ្ទាល់ខ្លួនផងដែរ ។ ដោយសារតែបញ្ហាសុខភាពមានជំងឺប្រចាំកាយដែលមិនអាចព្យាបាលបាន ក្មេងប្រុស "ក" ក៏បានធ្វើប្រទានកម្មជាអច្ច័យទានឱ្យមិត្តស្រីរបស់ខ្លួននូវចំណែក ១ភាគ៣ នៃមត៌កសរុប ។ ក្នុងករណីនេះក្មេងប្រុស "ក" មានសិទ្ធិពេញលេញក្នុងការធ្វើមតកសាសន៍នេះ ។

### ២.២. ករណីដោយឡែកនៃសមាសភាពម្ចាស់បណ្ដាំ

#### ២.២.១. ម្ចាស់បណ្ដាំជាជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅមានសិទ្ធិធ្វើមតកសាសន៍ដោយស្របច្បាប់ និងធ្វើឡើងដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅនោះទេ ។ បើទោះបីជាជននៅក្រោមអាណាព្យាបាលទូទៅ

[30] សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧,ភាគ៣,ទំព័រ៤៩

ស្ថិតនៅក្នុងប្រភេទនៃជនដែលត្រូវបានកម្រិតសមត្ថភាព ក្នុងការធ្វើសកម្មភាពផ្សេងៗដោយសារតែការបាត់បង់ស្មារតី និងមិនអាចពិចារណារកខុសត្រូវជានិរន្តរ៍ក៏ដោយ ប៉ុន្តែនៅករណីដែលជននោះមានសមត្ថភាពខាងឆន្ទៈឡើងវិញ ឬសះស្បើយឡើយវិញក្នុងខណៈពេលមតកសាសន៍ សកម្មភាពក្នុងការធ្វើមតកសាសន៍នេះមិនអាចទាមទារឱ្យមានការលុបចោលបានឡើយ ។ ជាគោលការណ៍ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅបានសះស្បើយមួយរយៈពេលឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ (ពីរ) នាក់ ។[31] នៅក្នុងការបង្ហាញភស្តុតាងអំពីការសះស្បើយមួយរយៈនូវសមត្ថភាពជាបណ្តោះអាសន្ននោះ នៅពេលធ្វើមតកសាសន៍គួរតែមានវត្តមានរបស់វេជ្ជបណ្ឌិត ២ (ពីរ) ឬច្រើននាក់ ហើយក្នុងនោះទៀតសោតវេជ្ជបណ្ឌិតត្រូវសរសេរបញ្ជាក់បន្ថែមលើមតកសាសន៍នោះ ។[32]

ឧទាហរណ៍៖ បុរស "ក" ជានីតិជន និងជាជននៅក្រោមអាណាព្យាលទូទៅដោយសារតែការមិនអាចគ្រប់គ្រងខ្លួនឯង និងមិនអាចពិចារណាខុសត្រូវបានអស់រយៈពេលជាង១០ឆ្នាំមកហើយ ។ ស្រាប់តែរយៈពេល៥ថ្ងៃមកហើយ បុរស "ក" បានមានស្មារតីឡើងវិញ និងដឹងខុសត្រូវឡើងវិញជាប្រក្រតីដូចជាមនុស្សទូទៅដទៃផងដែរ ហើយបុរស "ក" បានធ្វើមតកសាសន៍ដើម្បីបែងចែកទ្រព្យសម្បត្តិឱ្យទៅសន្តតិជន និងអច្ច័យលាភី ហើយការធ្វើនូវមតកសាសន៍នេះមានការចូលរួមពីវេជ្ជបណ្ឌិតចំនួន២រូបផងដែរ ដើម្បីពិនិត្យអំពីសមត្ថភាពខាងឆន្ទៈរបស់បុរស "ក" និងចូលរួមបញ្ជាក់លើលិខិតមតកសាសន៍ ។

### ២.២.២. ម្ចាស់បណ្តាំជាជននៅក្រោមហិតូបត្ថម្ភ

ប្រសិនបើប្រៀបធៀបនឹងជននៅក្រោមអាណាព្យាបាលទូទៅ ស្ថានភាពនៃជននៅក្រោមហិតូបត្ថម្ភគឺមានលក្ខណៈល្អប្រសើរជាង ហើយជននៅក្រោមហិតូបត្ថម្ភក៏មានសិទ្ធិធ្វើមតកសាសន៍ដូចនឹងជននៅក្រោមអាណាព្យាបាលទូទៅផងដែរដោយស្របច្បាប់ និងមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ ។ ជាតក្កភាពប្រសិនបើជននៅក្រោមអាណាព្យាបាលទូទៅ ដែលមានស្ថានភាពក្នុងការពិចារណាខុសត្រូវធ្ងន់ធ្ងរជាងជនដែលនៅក្រោមហិតូបត្ថម្ភមានសិទ្ធិធ្វើមតកសាសន៍ នោះនាំឱ្យជននៅក្រោមហិតូបត្ថម្ភដែលមានស្ថានភាពពិចារណាខុសត្រូវល្អប្រសើរជាងជននៅក្រោមអាណាព្យាបាលទូទៅមានសិទ្ធិធ្វើមតកសាសន៍ផងដែរ ។ ចំពោះនីតិវិធីនៃការធ្វើមតកសាសន៍របស់ជននៅក្រោមហិតូបត្ថម្ភ គឺដូចករណីរបស់ជននៅក្រោមអាណាព្យាបាលទូទៅផងដែរ ដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ១១៧៦ ស្តីពីមតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ។

---

[31] មាត្រា១១៧៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[32] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧,ភាគ៣,ទំព័រ៤៩

ឧទាហរណ៍៖ ស្ត្រី "ក" ជានីតិជន និងជាជននៅក្រោមហិតូបត្ថម្ភដោយសារខ្លួនមានមានសមត្ថភាពដឹងខុសត្រូវតិចតួច និងមិនអាចពិចារណាដូចមនុស្សពេញលក្ខណៈដទៃទៀតឡើយ ហើយដែលអាការៈបែបនេះកើតមានជាច្រើនឆ្នាំមកហើយ ។ ស្រាប់តែរយៈពេលប្រមាណ ១០ ថ្ងៃមកហើយ ស្ត្រី "ក" បានមានស្មារតីឡើងវិញ និងដឹងខុសត្រូវឡើងវិញជាប្រក្រតីដូចជាមនុស្សទូទៅដទៃផងដែរ ហើយស្ត្រី "ក" បានធ្វើមតកសាសន៍ដើម្បីបែងចែកទ្រព្យសម្បត្តិឱ្យទៅសន្តតិជន និងអច្ច័យលាភី ហើយចំពោះការធ្វើមតកសាសន៍នេះមានការចូលរួមពីវេជ្ជបណ្ឌិតចំនួន២រូបផងដែរ ដើម្បីពិនិត្យអំពីសមត្ថភាពខាងឆន្ទៈរបស់ស្ត្រី "ក" និងចូលរួមបញ្ជាក់លើលិខិតមតកសាសន៍ ។

## ផ្នែកទី២៖ គោលការណ៍សមត្ថភាពខាងឆន្ទៈក្នុងការបង្កើតអច្ច័យទាន

### កថាខណ្ឌទី១- សមត្ថភាពខាងឆន្ទៈក្នុងការបង្កើតអច្ច័យទាន

នៅដំណាក់កាលនេះ គឺជាដំណាក់កាលដំបូងដែលយើងត្រូវពិចារណាអំពីសមត្ថភាពរបស់បុគ្គលដែលមានបំណងធ្វើមតកសាសន៍ ។ នៅចំណុចនេះផងដែរ ត្រូវពិចារណាលើសមត្ថភាពអាចធ្វើមតកសាសន៍ និងសមត្ថភាពនាពេលធ្វើមតកសាសន៍ ។ បុគ្គលខ្លះ ច្បាប់កំណត់ថា ជាបុគ្គលដែលមានសមត្ថភាព ឬលក្ខណៈសម្បត្តិអាចធ្វើមតកសាសន៍បាន ប៉ុន្តែនាពេលធ្វើមតកសាសន៍ អាចជាបុគ្គលដែលស្ថិតក្នុងស្ថានភាពដែលខ្វះសមត្ថភាពខាងឆន្ទៈ ហេតុនេះទើបច្បាប់ធ្វើការបែងចែកដូចខាងលើ ដើម្បីងាយស្រួលក្នុងការវាយតម្លៃ ។ ជាគោលការណ៍ដើម្បីធ្វើមតកសាសន៍ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពនាពេលធ្វើមតកសាសន៍ ។[33]

ឧទាហរណ៍៖ បុគ្គល "ក" មានអាយុ ៤០ ឆ្នាំ គាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើមតកសាសន៍ ។ ប៉ុន្តែបុគ្គល "ក" បានធ្វើមតកសាសន៍ក្នុងស្ថានភាពនៃការគំរាមកំហែងពីសំណាក់តតិយជនក្នុងករណីនេះ ដូចនេះ បុគ្គល "ក" ត្រូវបានចាត់ទុកថាពុំមានសមត្ថភាពនាពេលធ្វើមតកសាសន៍នោះទេ ។

### កថាខណ្ឌទី២- ករណីម្ចាស់បណ្តាំខ្វះសមត្ថភាពខាងឆន្ទៈ

ជាទូទៅសមត្ថភាពខាងឆន្ទៈ សំដៅដល់សកម្មភាពដែលបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនអាចយល់ដឹងនិងវិនិច្ឆ័យបាន ផ្ទុយមកវិញ កង្វះសមត្ថភាពខាងឆន្ទៈ សំដៅដល់សកម្មភាពដែលបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។ នីតិជន និងអនីតិជនទទួលបានអត្តាធីនភាព បើទោះជាមាននីតិភាពក្នុងការធ្វើសកម្មភាពផ្សេងៗដោយស្របច្បាប់ ប៉ុន្តែចាំបាច់ត្រូវមានសមត្ថភាពឆន្ទៈ ក្នុងករណីធ្វើឡើងដោយខ្វះសមត្ថភាពខាងឆន្ទៈ សកម្មភាពនោះអាចលុបចោលបាន ។ ក្នុងនោះដែរ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ ត្រូវមានការយល់ព្រមពី

[33] មាត្រា១១៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អ្នកអាណាព្យាបាលទូទៅក្នុងការធ្វើសកម្មភាពផ្សេងៗ លើកលែងតែសកម្មភាពប្រចាំថ្ងៃដែលច្បាប់ ឬអ្នកអាណាព្យាបាលទូទៅអនុញ្ញាត ។

ឧទាហរណ៍៖ បុគ្គលដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបាននូវសកម្មភាពរបស់ខ្លួន ដោយសារជននោះបរិភោគស្រារហូតស្រវឹង ឬជននោះប្រើប្រាស់ថ្នាំដែលប៉ះពាល់ដល់សមត្ថភាពខាងឆន្ទៈ ។ នាំឲ្យសកម្មភាពរបស់សាមីជន ឬសន្តតិជន ឬអច្ច័យលាភីនោះ ត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

**ផ្នែកទី៣៖ ទម្រង់នៃអច្ច័យទាន**

អច្ច័យទាន គឺជាសណ្ឋាននៃសន្តតិកម្មតាមមតកសាសន៍ ហើយចំពោះការបង្កើតអច្ច័យទាន គឺត្រូវអនុវត្តតាមទម្រង់នៃលិខិតមតកសាសន៍ ។

យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១១៧០ កថាខណ្ឌទី១ បានបង្ហាញថា មតកសាសន៍ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះ ។

បើយើងពិនិត្យមើលលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ដដែល ផ្នែកទី២ "ទម្រង់នៃមតកសាសន៍" បានបង្ហាញឱ្យឃើញថាមតកសាសន៍អាចធ្វើឡើងបានក្នុងទម្រង់ដូចខាងក្រោម៖

**កថាខណ្ឌទី១- វិធីធម្មតានៃទម្រង់នៃអច្ច័យទាន**

ដូចដែរយើងបានដឹងហើយថា អច្ច័យទាន កើតចេញពីទម្រង់នៃមតកសាសន៍ ។ ការបង្កើតមតកសាសន៍គឺជាសេរីភាពរបស់ម្ចាស់បណ្តាំ ប៉ុន្តែដើម្បីឲ្យមានភាពងាយស្រួលក្នុងការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ក្រោយពេលគាត់ទទួលមរណភាពច្បាប់តម្រូវឲ្យមតកសាសន៍ត្រូវតែបង្កើតឡើងក្នុងទម្រង់ជាក់លាក់ណាមួយ ។

**១.១. អច្ច័យទានដោយលិខិតយថាភូត**

យោងតាមមាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ថាមតកសាសន៍ដោយលិខិត_យថាភូតត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះសារការីដើម្បីអោយមានប្រសិទ្ធភាពនាពេលធ្វើអច្ច័យទាន។

លិខិតយថាភូតមានចំនួនពីរប្រភេទ រួមមាន៖

- លិខិត ឬ កិច្ចសន្យា ដែលធ្វើឡើងដោយសារការី (សារការីជាអ្នកតាក់តែងឡើង) ។
- លិខិត ឬ កិច្ចសន្យាឯកជន ដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់
- និងចុះកាលបរិច្ឆេទ និង ហត្ថលេខាក្រោយពេលសារការីបញ្ជាក់ថា លិខិនោះមានភាពត្រឹមត្រូវតាមច្បាប់ (លិខិត ឬ កិច្ចសន្យាឯកជន ដែលស្នើរសុំឱ្យសារការីផ្តល់យថាភូតភាព) ។

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល លិខិតយថាភូត ជាលិខិតដែលត្រូវចុះហត្ថលេខានៅចំពោះមុខសារការី ឬ មន្ត្រីសាធារណៈ ដែលត្រូវអនុញ្ញាតអោយប្រតិបត្តិមុខងារនោះ ឬ ដែលត្រូវផ្តល់ជាកស្សិណដោយត្រាសាធារណៈ ឬ

ត្រូវបានធ្វើអោយទៅជាសាធារណៈដោយតុលាការដែលមានសមត្ថកិច្ច ឬដែលត្រូវបានបញ្ជាក់ថាជា សេចក្តីចម្លងបញ្ជីសាធារណៈ ។

មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយយោងតាមទម្រង់ដូចខាងក្រោមនេះ៖

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ)នាក់។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវ ហើយជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើកឯកសារអំពីឈ្មោះ អាយុ និងលំនៅដ្ឋាន ហើយចុះហត្ថលេខារៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងចុះហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅដ្ឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនេះផង ។

ង-សារការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ហើយចុះហត្ថលេខា ។

**១.២. អច្ច័យទានដោយលិខិតឯកជន**

មតកសាសន៍ដោយលិខិតឯកជន គឺជាប្រភេទនៃមតកសាសន៍ដែលសរសេរឡើងដោយផ្ទាល់ដៃរបស់មតកជន មានចុះហត្ថលេខា និងចុះថ្ងៃ ខែ ឆ្នាំ ។[34]

មតកសាសន៍ដោយលិខិតឯកជន មិនអាចសរសេរដោយម៉ាស៊ីន ឬឧបករណ៍អេឡិចត្រូនិក ដូចជាការវាយអង្គុលីលេខ ឬកុំព្យូទ័រ ឬក៏សរសេរជំនួសដោយអ្នកដទៃឡើយ បើពុំនោះទេវានឹងត្រូវបានមោឃភាព ។

ដើម្បីធ្វើមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្តាំត្រូវសរសេរមតកសាសន៍ទាំងមូលព្រមទាំងចុះថ្ងៃ ខែ ឆ្នាំ ដោយខ្លួនឯងហើយចុះហត្ថលេខា ។ ពេលដែលមានបញ្ហាអំពីសុក្រឹត្យភាពនៃមតកសាសន៍នោះកើតឡើង បន្ទាប់ពីពេលសាមីខ្លួនបានទទួលមរណភាពហើយ ដូច្នេះគេមិនអាចទាមទារឱ្យម្ចាស់បណ្តាំធ្វើសេចក្តីថ្លែងការណ៍បានទេ ហេតុនេះហើយពេលនោះចាំបាច់ត្រូវផ្ទៀងផ្ទាត់មើលអក្សររបស់សាមីខ្លួនម្ចាស់បណ្តាំ ដែលបានសរសេរក្នុងលិខិតផ្សេងៗពេលនៅរស់ ( ដូចជាសំបុត្រ ឬសៀវភៅកំណត់ហេតុជាអាទិ៍ ) ។ ហេតុនេះហើយបានជាតម្រូវឱ្យម្ចាស់បណ្តាំសរសេរខ្លឹមសារនៃមតកសាសន៍ និងទាមទារឱ្យចុះហត្ថលេខា ជាអាទិ៍ដោយសាមីខ្លួនផ្ទាល់ ។ ដូច្នេះប្រសិនបើសាមីខ្លួនចុះហត្ថលេខាដោយខ្លួនឯងមិនមានការអនុវត្តតាម មាត្រា ១១៨០ នៃ

[34] មាត្រា១១៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្រមរដ្ឋប្បវេណីទេ ។

ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា ដោយហេតុថាអាចមានករណីដែលតតិយជនផ្លាស់ប្តូរដូចជាសរសេរបន្ថែម ឬលុបចោលពាក្យខ្លះក្នុងមតកសាសន៍ ហេតុនេះហើយក្នុងករណីដែលម្ចាស់បណ្តាំខ្លួនឯងចង់ផ្លាស់ប្តូរនោះ ចាំបាច់ត្រូវចុះហត្ថលេខាផងដែរ ដើម្បីបញ្ជាក់មើលដោយផ្ទៀងផ្ទាត់ប្រៀបធៀបនឹងលិខិតផ្សេងថាតើការផ្លាស់ប្តូរដូចជាសរសេរបន្ថែម ឬការលុបចោលជាអាទិ៍ ធ្វើដោយសាមីខ្លួនមែនឬទេ ។

ក្នុងករណីមានមតកសាសន៍ច្រើន ដែលពុំបានចុះថ្ងៃ ខែ ឆ្នាំ ដូចគ្នា ហើយខ្លឹមសារមិនផ្ទុយគ្នា នាំឱ្យមតកសាសន៍នោះមានសុពលភាព ។[35]

ប៉ុន្តែប្រសិនបើមតកសាសន៍នោះមានខ្លឹមសារផ្ទុយគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នា ។[36]

ឧទាហរណ៍: ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទានតាមទម្រង់លិខិតឯកជន ។ ម្ចាស់បណ្តាំ "ក" បានឱ្យសាក្សី២នាក់ដឹងលឺ និងបានឱ្យមេធាវីប្រថាប់ត្រា ដោយលក្ខខណ្ឌនៃលិខិតឯកជនពុំតម្រូវអោយមានមេធាវី ឬសាក្សីឡើយ ប៉ុន្តែរាល់លក្ខខណ្ឌនៃទម្រង់ទាំងអស់ ម្ចាស់បណ្តាំ "ក" បានបំពេញដោយពុំមានចំណុចខ្វះខាតនាំឱ្យលិខិតនោះជាលិខិតបានការ ។ ផ្ទុយទៅវិញ ប្រសិនបើម្ចាស់បណ្តាំ "ក" ប្រើស្នាមម្រាមដៃជំនួសហត្ថលេខាត្រូវចាត់ទុកថាពុំបានបំពេញលក្ខខណ្ឌ ដែលនាំឱ្យលិខិតនោះត្រូវចាត់ទុកជាមោឃៈ ។

### **១.៣. អច្ច័យទានដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ គឺជាទម្រង់មតកសាសន៍មួយដែលអនុញ្ញាតឱ្យអ្នកចេះអក្សរធ្វើមតកសាសន៍ដោយរក្សាខ្លឹមសារនោះជាការសម្ងាត់ទាំងស្រុងហើយដែលអាចការពារកុំឱ្យមានការលុបចោល ឬការលួចកែប្រែដោយតតិយជន ។ ចំពោះមតកសាសន៍ដោយលិខិតឯកជន ក៏ដូចគ្នាដែរគឺអាចបិទដោយប្រថាប់ត្រាហើយប្រសិនបើតតិយជនបានបើកដោយមិនឆ្លងកាត់ការបញ្ជាក់តាមនីតិវិធីរបស់តុលាការទេ ត្រូវទទួលពិន័យស៊ីវិល ដូច្នេះអាចលាក់ការសម្ងាត់បានខ្លះ ក៏ប៉ុន្តែអាចមានការលុបចោល ឬកែប្រែដោយតតិយជនដែរ ។ ចំពោះមតកសាសន៍ដោយលិខិតសម្ងាត់វិញ សារការីជាអ្នករក្សាទុក ដូច្នេះការបើក ការលុបចោល ឬការកែប្រែ មិនអាចមានការកើតមានឡើងបានឡើយ ។

ដើម្បីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ ចាំបាច់ត្រូវអនុលោមតាមបញ្ញត្តិចំណុច ក ដល់ចំណុច ឃ មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណី ។ វិធីនេះខុសពីមតកសាសន៍ដោយលិខិតឯកជន ដោយម្ចាស់បណ្តាំមិនចាំបាច់សរសេរនូវខ្លឹមសារនៃមតកសាសន៍ដោយខ្លួនឯងទេ ពោលគឺម្ចាស់បណ្តាំអាចពឹងឱ្យអ្នកផ្សេងដែរខ្លួនជឿ

[35] មាត្រា១១៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[36] មាត្រា១១៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ទុកចិត្ត សរសេរជំនួស ឬប្រើម៉ាស៊ីនអង្គុលីលេខ ឬកុំព្យូទ័រជាអាទិ៍បាន ។ ក៏ប៉ុន្តែប្រសិនបើសរសេរដោយខ្លួនឯង និងចុះថ្ងៃ ខែ ឆ្នាំ ព្រមទាំងចុះហត្ថលេខាដោយខ្លួនផ្ទាល់ ទោះបីជាមិនស្របនឹងលក្ខខណ្ឌនៃវិធីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយ ក៏មានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ ។[37]

➢ **មតកសាសន៍ដោយលិខិតសម្ងាត់ (ចំពោះមុខសារការី)**

១- ម្ចាស់បណ្តាំ អាចសរសេរខ្លួនឯងផ្ទាល់ ឬអ្នកដទៃ នូវខ្លឹមសារមតកសាសន៍ ត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិតចុះហត្ថលេខាលើលិខិតមតកនិងមាត់ស្រោមសំបុត្រ ។

២- ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមមុខ សារការីនិងសាក្សីពីរនាក់ ហើយថ្លែងការណ៍ពីលិខិតនោះ ថាជាលិខិតមតកសាសន៍របស់ខ្លួនអ្នកណាជាអ្នកសរសេរអោយខ្លួនជាដើម ។

៣- សារការី ត្រូវចុះថ្ងៃខែឆ្នាំ ហត្ថលេខា និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ ព្រមទាំងសាក្សីហត្ថលខាផងដែរ ។

## កថាខណ្ឌទី២- វិធីដោយឡែកនៃទម្រង់នៃអច្ច័យទាន

### ២.១. ករណីម្ចាស់បណ្តាំជាជននៅក្រោមអាណាព្យាបាលទូទៅ

ទោះបីជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏អាចមានពេលដែលបុគ្គលនោះបានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យនូវលទ្ធិផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដែរ ដូច្នេះបញ្ញត្តិនេះទទួលស្គាល់នូវការធ្វើមតកសាសន៍នៅពេលនោះ ។ មាត្រា៩៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់នូវអាពាហ៍ពិពាហ៍របស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ ដូច្នេះចំពោះការធ្វើមតកសាសន៍ក៏ត្រូវទទួលការពិចារណាដូចគ្នាដែរ ។ តែចាំបាច់ត្រូវមានគ្រូពេទ្យយ៉ាងតិចពីរនាក់ នៅពេលធ្វើមតកសាសន៍ ដើម្បីធ្វើការបញ្ជាក់មើលថាម្ចាស់បណ្តាំពិតជាបានបានសះស្បើយមួយរយៈឡើងនូវសមត្ថភាពធ្វើមតកសាសន៍ ដើម្បីជៀសវាងការមានជម្លោះនៅពេលអនាគត ។ ប៉ុន្តែក្នុងករណីដែលអនីតិជនបានត្រូវប្រកាសឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅតាមមាត្រា ២៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ហើយបានក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅ ជននោះមិនអាចអនុវត្តតាមមាត្រានេះបានទេ រហូតដល់ខ្លួនបានក្លាយជានីតិជន ។[38]

កាតព្វកិច្ចរបស់វេជ្ជបណ្ឌិតដែលមានវត្តមាននៅក្នុងពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន

[37] មាត្រា១១៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[38] មាត្រា១១៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដោយសារ មានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។ ម៉្យាងទៀត ចំពោះករណីដែលចាំបាច់មានវត្តមានរបស់សាក្សី ដូចជាការផ្ញើមតកសាសន៍ដោយលិខិតយថាយថាភូតជាអាទិ៍ ត្រូវមានវត្តមានរបស់សាក្សី ក្រៅពីគ្រូពេទ្យផងដែរ ។ ប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅផ្ញើមតក សាសន៍ដោយលិខិតឯកជន ឬផ្ញើមតកសាសន៍ដោយលិខិតសម្ងាត់ នៅក្នុងករណីនីមួយៗនេះ ចាំបាច់ត្រូវមាន វត្តមានរបស់គ្រូពេទ្យដែលមានរៀបរាប់ដូចខាងលើ នៅពេលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬនៅ ពេលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឱ្យសារការី ។

➢ **ជននៅក្រោមហិតូបត្ថម្ភ**

- **ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ**

១- ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យ អំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភលើ ជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ បើសាមីខ្លួនជា ជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការ ប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ ចំពោះជននោះ ។

- **អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ**

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវហៅថា "ជននៅក្រោមហិតូបត្ថម្ភ" ហើយត្រូវស្ថិត នៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

- **សិទ្ធិលុបចោលសកម្មភាព**

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល បានធ្វើឡើងដោយ ជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈដូចខាង ក្រោមនេះ អាចលុបចោលបាន៖

ក- ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ- ការខ្ចីទ្រព្យ ឬ ការធានា ។

គ- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិ ដែលទាក់ទងនឹងអចលន វត្ថុ ឬ ទ្រព្យសម្បត្តិ ដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ- ការធ្វើសកម្មភាពបណ្ដឹង ។

ង- ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យា មជ្ឈត្តកម្ម ។

ច- ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិ សន្តតិកម្ម ឬ ការ បែងចែកនូវមត៌ក ។

ឆ- ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវ ប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ- ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ ត្រូវមានការ យល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ ឬ ហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភ ។

- **ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ**

បើមូលហេតុដែលបានកំណត់ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះត្រូវបានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល សម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់ អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

**២.២- ករណីម្ចាស់បណ្តាំជាជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**

នេះជាបញ្ញត្តិពិសេស សម្រាប់ករណីដែលជនដែរកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតធ្វើមតកសាសន៍ ។

ទោះជាកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតក៏ដោយ ប្រសិនបើមានសមត្ថភាពធ្វើមតកសាសន៍ដោយលិខិតឯកជន ជននេះអាចធ្វើបាន ។ ម៉្យាងទៀត ប្រសិនបើមានពេលអាចហៅសារការីបាន ក៏អាចធ្វើមតកសាសន៍ដោយលិខិតយថាភូតដែរ ។ ក៏ប៉ុន្តែអាចមានករណីដែលគ្មានសមត្ថភាព ឬគ្មានពេលវេលា ពេលនោះម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់ ចំពោះមុខអ្នកមានវត្តមានបានដែរ ។ ប្រសិនបើជនដែលកំពុងដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតដោយសារជម្ងឺ ឬហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិចចំនួន ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសាររបស់មតកសាសន៍នោះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ ។

មតកសាសន៍ដែលបានធ្វើតាមបញ្ញាតិខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

### ២.៣. ករណីម្ចាស់បណ្តាំជាជនដែលបានជាប់ឃុំឃាំងជាអាទិ៍

ជនដែលជាប់ឃុំឃាំង ឬនៅក្នុងនាវាជាអាទិ៍ អាចធ្វើមតកសាសន៍ដោយវិធីដូចគ្នានឹងការធ្វើមតកសាសន៍ដោយលិខិតយថាភូតដែរ ។ ជនទាំងនេះអាចធ្វើមតកសាសន៍ដោយលិខិតឯកជន ដោយយោងតាមមាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានដែរ ប៉ុន្តែមានករណីខ្លះដែលមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបានឡើយ ដោយសារជននោះជាអនក្ខរជន ឬមានរបួសដៃ ហេតុនេះហើយបានជាចាំបាច់មានបញ្ញត្តិនេះ ។

បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយតម្រូវឱ្យមានវត្តមានរបស់នគរបាល ឬមន្ត្រីមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច២ (ពីរ)នាក់ ។

បុគ្គលដែលនៅក្នុងនាវា ឬយន្តហោះ អាចធ្វើមតកសាសន៍បាន ដោយតម្រូវឱ្យមានវត្តមានមេបញ្ជាការបរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ២ (ពីរ)នាក់ ។

នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬ បុគ្គលិកនាវា ឬយន្តហោះបាន ។

មតកសាសន៍ដោយលិខិតយថាភូតនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ ។ ក្នុងករណីនេះ ពាក្យសារការីត្រូវបានបកស្រាយថាជា នគរបាលមន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ ។

មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញាត្តិខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជានេះ ក្រោយពេលដែលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬចុះពីនាវា ឬយន្តហោះ ។

### ២.៤. ករណីម្ចាស់បណ្តាំជាបុគ្គលដែលមិនអាចនិយាយបានជាអាទិ៍

នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុង មាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួប ប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមរដ្ឋប្បវេណីនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បានដោយធ្វើ សេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍ តាម ការបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់នៅចំពោះមុខសារការី ឬសាក្សី ។

ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះត្រូវអានឱ្យម្ចាស់បណ្តាំ ឬសាក្សី ស្តាប់នូវខ្លឹមសារនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតក សាសន៍នោះ បើម្ចាស់បណ្តាំ និងសាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចឱ្យស្តាប់បានទេ សារការី ឬបុគ្គលផ្សេង ទៀតដែរត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបាន សរសេរនោះ តាមការបកប្រែទៅម្ចាស់បណ្តាំ ឬសាក្សីនោះ ។

ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ សារការីឬបុគ្គលផ្សេងទៀតដែលបានកំណត់ នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះ ចូលទៅក្នុងលិខិតនោះ ។

## ផ្នែកទី៤៖ កម្មវត្ថុនៃអច្ច័យទាន

### កថាខណ្ឌទី១- ការធ្វើអនុប្បទាននូវអចលនវត្ថុ និងចលនវត្ថុ

#### ១.១. ការធ្វើអនុប្បទាននូវអចលនវត្ថុ

អចលនវត្ថុ សំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។[39] ជាគោលការណ៍ អចលនវត្ថុដែលគ្មានម្ចាស់ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ។[40] កម្មសិទ្ធិលើអចលនវត្ថុអាចត្រូវបានធ្វើលទ្ធកម្មតាមរយៈកិច្ចសន្យា សន្តតិកម្ម និងមូលហេតុផ្សេងដទៃទៀត ។[41] ម្ចាស់បណ្តាំដែលមានអចលនវត្ថុជាកម្មសិទ្ធិរបស់ខ្លួន មានសិទ្ធិយកអចលនវត្ថុធ្វើជាកម្មវត្ថុនៃអច្ច័យទានឱ្យទៅ អច្ច័យលាភី ។

#### ១.២. ការធ្វើអនុប្បទាននូវចលនវត្ថុ

ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។[42] កម្មសិទ្ធិលើចលនវត្ថុអាចត្រូវបានធ្វើលទ្ធកម្មតាមរយៈ

---

[39] មាត្រា១២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[40] មាត្រា១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[41] មាត្រា១៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[42] មាត្រា១២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

កិច្ចសន្យា សន្តតិកម្ម និងមូលហេតុផ្សេងដទៃទៀតដែលមានកំណត់ក្នុងច្បាប់ ។[43] ម្ចាស់បណ្តាំមានសិទ្ធិយកចលនវត្ថុដែលខ្លួនជាកម្មសិទ្ធិករមកធ្វើជាកម្មវត្ថុនៃអច្ច័យទានឱ្យទៅអច្ច័យលាភី ។

**កថាខណ្ឌទី២- ករណីដោយឡែកនៃកម្មវត្ថុនៃអច្ច័យទាន**

ជាទូទៅ ឧបាទេសកម្ម គឺជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់ ។[44] ក្នុងឋានៈជាម្ចាស់បំណុល ម្ចាស់បណ្តាំមានសិទ្ធិយកការទាមទារ ឬទទួលវត្ថុនៃការសងពីកូនបំណុលមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។ ការទទួលយកនូវសិទ្ធិទាមទារសំណង ឬទទួលវត្ថុដែលជាកម្មវត្ថុនៃការសងពីកូនបំណុលរបស់ម្ចាស់បណ្តាំ គឺជាឧបាទេសកម្មនៃសិទ្ធិរបស់ម្ចាស់បណ្តាំឱ្យទៅអច្ច័យលាភី ។

ក្នុងនោះឧបាទេសកម្មនៃសិទ្ធិមានពីរចំនុច គឺទី១ ឧបាទេសកម្មនៃសិទ្ធិលើវត្ថុ និងឧបាទេសកម្មនៃសិទ្ធិលើបំណុល ។

**២.១. ឧបាទេសកម្មនៃសិទ្ធិលើវត្ថុ**

ម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណងពីតតិយជនមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ដោយមូលហេតុថាតតិយជននោះបានធ្វើឱ្យបាត់បង់ ឬកែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬការបាត់បង់ការកាន់កាប់វត្ថុនោះ ។[45]

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទាននូវរថយន្តមួយគ្រឿងឱ្យទៅភាគី "ខ" ជាអច្ច័យលាភី ។ ក្នុងអំឡុងពេលម្ចាស់បណ្តាំកំពុងរស់នៅ រថយន្តនោះត្រូវបានជួលឱ្យភាគី "គ" ហើយពេលមួយនោះ ភាគី "គ" បានបង្កគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលឱ្យរថយន្តនោះខូចខាតទាំងស្រុង ។ ម្ចាស់បណ្តាំបានទាមទារប្រាក់សំណងលើតម្លៃរថយន្តនោះពីភាគី "គ" ចំនួន ១០,០០០ USD ។ ជាបន្តបន្ទាប់ ម្ចាស់បណ្តាំបានយកប្រាក់ចំនួន ១,០០០ USD មកចំណាយផ្សេងៗនូវតម្រូវការរបស់ខ្លួន ។ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំ "ក" ទឹកប្រាក់នៅសល់ចំនួន ៩,០០០ USD ហើយប្រាក់ចំនួន ៩,០០០ USD នេះហើយគឺជាអច្ច័យទានចំពោះភាគី "ខ" ដែលជាអច្ច័យលាភីនោះ ។

**២.២. ឧបាទេសកម្មនៃសិទ្ធិលើបំណុល**

ម្ចាស់បណ្តាំមានសិទ្ធិយកសិទ្ធិលើបំណុលមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។ នៅពេលចាប់ផ្តើមសន្តតិកម្ម ហើយប្រសិនបើអច្ច័យលាភីទទួលស្គាល់ នោះអច្ច័យលាភីត្រូវទទួលបន្តនូវសិទ្ធិលើបំណុលហើយដែលក្នុងនោះអាចមានសិទ្ធិលើបំណុលជាប្រាក់ ឬសិទ្ធិទាមទារឱ្យប្រគល់វត្ថុត្រលប់មកវិញ ។ ក្នុងករណីដែលកូនបំណុល

[43] មាត្រា១៨៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[44] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី

[45] មាត្រា១២០៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បានធ្វើការសងបំណុលជាប្រាក់មកម្ចាស់បណ្តាំដែលកំពុងរស់នៅ ហើយដែលអច្ច័យទាននេះនៅតែមាននៅក្នុងមត៌ក ត្រូវសន្មតថាម្ចាស់បណ្តាំបានយកតម្លៃនៃប្រាក់សំណងមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។ ម៉្យាងវិញទៀតក្នុងករណីដែលកូនបំណុលបានធ្វើការសងបំណុលជាវត្ថុ (ចលនវត្ថុ) មកម្ចាស់បណ្តាំដែលកំពុងរស់នៅ ហើយដែលអច្ច័យទាននេះនៅតែមាននៅក្នុងមត៌ក ត្រូវសន្មតថាម្ចាស់បណ្តាំបានយកវត្ថុនៃសំណងនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។[46]

ឧទាហរណ៍៖ ក- ភាគី "គ" បានខ្ចីប្រាក់ចំនួន ២,០០០ USD ពីភាគី "ក" ។ ក្រោយមកភាគី "ក" បានធ្វើមតកសាសន៍ដោយក្នុងនោះខ្លួនបានធ្វើអច្ច័យទាននូវសិទ្ធិលើបំណុលដែលភាគី "គ" បានខ្ចីនោះឱ្យទៅភាគី "ខ" ដែលជាអច្ច័យលាភី ។ រយៈពេល ៤ឆ្នាំបន្ទាប់ ភាគី "គ" បានធ្វើការសងប្រាក់ចំនួន ២,០០០ USD មកភាគី "ក" ដែលជាម្ចាស់បំណុល និងជាម្ចាស់បណ្តាំ ។ ខ្លឹមសារនៃអច្ច័យទានដែលមាននៅក្នុងមតកសាសន៍ពុំបានមានការលុបចោល ឬកែប្រែនោះឡើយ ។ ដូចនេះ នៅពេលចាប់ផ្តើមសន្តតិកម្ម ភាគី "ខ" ដែលជាអច្ច័យលាភីត្រូវទទួលបានប្រាក់ចំនួន ២,០០០ USD ដែលជាកម្មវត្ថុនៃអច្ច័យទាន ប៉ុន្តែប្រសិនបើចំនួនទឹកប្រាក់នោះត្រូវបានថយចុះដោយសារម្ចាស់បណ្តាំកាលរស់នៅបានយកទៅបំពេញតម្រូវការផ្សេងៗផ្ទាល់ខ្លួន នោះចំណែកនៅសល់ជាក់ស្តែង គឺជាកម្មវត្ថុនៃអច្ច័យទានដែលអច្ច័យលាភីត្រូវទទួលបាន ។

## កថាខណ្ឌទី៣- ករណីដោយឡែកផ្សេងទៀតនៃកម្មវត្ថុនៃអច្ច័យទាន

### ៣.១. កម្មសិទ្ធិអវិភាគ

ម្ចាស់បណ្តាំមានសិទ្ធិយកសិទ្ធិដែលខ្លួនមានលើកម្មសិទ្ធិអវិភាគមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។ កម្មសិទ្ធិអវិភាគ សំដៅលើស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ។[47] ជាសារធាតុនៃកម្មសិទ្ធិអវិភាគ គឺជាការដែលមិនអាចបែងចែកអំពីចំណែកចម្បង ឬចំណែកបន្ទាប់បន្សំចំពោះចលនវត្ថុដែលភ្ជាប់គ្នា កម្មសិទ្ធិករនៃវត្ថុនីមួយៗ ត្រូវមានកម្មសិទ្ធិអវិភាគលើវត្ថុនោះ តាមសមាមាត្រនៃតម្លៃវត្ថុៗនាពេលបានជាប់គ្នា ។[48] ករណីដែលកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នាលាយគ្នា ឬច្របល់គ្នានឹងវត្ថុផ្សេងទៀត ដែលម្ចាស់បណ្តាំជាម្ចាស់នៃកម្មសិទ្ធិអវិភាគនៃវត្ថុនោះត្រូវសន្មតថាម្ចាស់បណ្តាំបានយកកម្មសិទ្ធិអវិភាគមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" មានចំណែកជាកម្មសិទ្ធិអវិភាគលើដីចំការមួយកន្លែងដែលមានអ្នកមានសិទ្ធិដទៃទៀតសរុបចំនួន៥នាក់ ។ ដោយសារតែវ័យកាន់តែជរា ម្ចាស់បណ្តាំ "ក" មានចិត្តអាណិតស្រលាញ់

---

[46] មាត្រា១២១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[47] មាត្រា២០០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[48] មាត្រា១៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ចាត់ទុកភាគី "ខ" ដូចជា កូន ក្មួយរបស់ខ្លួន ហើយនិងបានធ្វើអច្ច័យទាននូវកម្មសិទ្ធិអវិភាគរបស់ខ្លួនលើដីចំការនោះឱ្យទៅភាគី "ខ" ។

### ៣.២. សិទ្ធិជួលអចិន្ត្រៃយ៍

ម្ចាស់បណ្តាំមានសិទ្ធិយកសិទ្ធិជួលអចិន្ត្រៃយ៍លើអចលនវត្ថុរបស់ខ្លួនមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។ សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែងចាប់ពី១៥(ដប់ប្រាំ)ឆ្នាំ និងមិនអាចឱ្យលើសពី ៥០ (ហាសិប) ឆ្នាំ បានឡើយ ។[49] ក្នុងការធ្វើអនុប្បទាននូវសិទ្ធិជួលអចិន្ត្រៃយ៍ ម្ចាស់បណ្តាំដែលជាអ្នកជួលមានសិទ្ធិយកសុពលភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។[50] ចំពោះសុពលភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍នេះអាចជាផលប្រយោជន៍ទៅដល់អច្ច័យលាភី ឬអាចជាករណីយកិច្ចដែលត្រូវទទួលបន្តក្នុងអច្ច័យទាន ។

ឧទាហរណ៍៖ ភាគី "ក" មានដីចំការចំនួន ១០ ហិកតាសម្រាប់ដាក់ជួល ។ ភាគី "ខ" បានជួលដីចំការនោះក្នុងលក្ខខណ្ឌជាការជួលអចិន្ត្រៃយ៍ចំនួន៣០ឆ្នាំ ដោយផ្តល់ថ្លៃជួលរៀងរាល់ ៥ឆ្នាំម្តង ។ ភាគី "ខ" យកដីដែលជួលនោះមកដាំដំណាំស្វាយអស់រយៈពេល១០ឆ្នាំហើយក៏លែងដាំ និងទុកដីនោះចោល ។ ដោយមានជំងឺធ្ងន់ធ្ងរភាគី "ខ" បានធ្វើអច្ច័យទាននូវសិទ្ធិជួលអចិន្ត្រៃយ៍លើដីនោះឱ្យទៅភាគី "គ" ។ ៥ ឆ្នាំក្រោយធ្លាក់ខ្លួនឈឺ និងលែងដាំស្វាយនោះមក ភាគី "ខ" ដែលជាម្ចាស់បណ្តាំបានទទួលមរណភាព ។ ភាគី "គ" បានដឹងពីការចាប់ផ្តើមសន្តតិកម្ម និងអច្ច័យទានដែលខ្លួនត្រូវទទួលបាន ។ សុពលភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍លើដីចំការនោះមានចំនួន១៥ឆ្នាំបន្តទៀត ។ ដោយប្រៀបធៀបនឹងតម្លៃជួលបច្ចុប្បន្ន ភាគី "គ" ជាអច្ច័យលាភីបានទទួលយកសិទ្ធិនោះ ។ អច្ច័យលាភី "គ" បានជួលបន្តនូវដីចំការនោះឱ្យទៅតតិយជនដទៃទៀត ។

## ផ្នែកទី៥៖ សិទ្ធិរបស់ម្ចាស់បណ្តាំចំពោះអច្ច័យទានអំឡុងពេលមុនទទួលមរណភាព

### កថាខណ្ឌទី១- សិទ្ធិក្នុងការកែប្រែ ឬការលុបចោលអច្ច័យទាន

ម្ចាស់បណ្តាំមានសិទ្ធិលុបចោលនូវមតកសាសន៍មួយភាគ ឬ ទាំងស្រុងនៅពេលណាក៏បាន ។[51] ប៉ុន្តែប្រសិនបើមតកសាសន៍ត្រូវបានធ្វើពីរដង ហើយមតកសាសន៍ធ្វើក្រោយមានភាពផ្ទុយនឹងមតកសាសន៍ធ្វើមុននាំឱ្យមតកសាសន៍ធ្វើក្រោយមានអានុភាព ។[52]

បើម្ចាស់បណ្តាំធ្វើអនុប្បទាន ឬសកម្មភាពផ្សេងទៀតចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍នាពេលនៅ

[49] មាត្រា២៤៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[50] មាត្រា២៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[51] មាត្រា១១៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[52] មាត្រា១១៨៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

រស់ត្រូវចាត់ទុកថាម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ។[53]

ឧទាហរណ៍៖ លោក "ក" ជាម្ចាស់បណ្តាំបានធ្វើមតកសាសន៍នូវអច្ច័យទានឱ្យ លោក "គ" ជាតតិយជន នូវផ្ទះមួយខ្នងតម្លៃ ៥០,០០០ USD ។ ក្រោយមកលោក "ក" មានជំងឺត្រូវព្យាបាលបន្ទាន់ដោយត្រូវលក់ផ្ទះដែលបានធ្វើមតកសាសន៍នោះដើម្បីព្យាបាលជម្ងឺនោះនាំឱ្យមតកសាសន៍នោះត្រូវបាត់បង់អានុភាព ។

ប្រសិនបើម្ចាស់បណ្តាំបំផ្លាញច្បាប់ដើមនៃមតកសាសន៍ដោយចេតនា នោះនាំឱ្យមតកសាសន៍បាត់បង់អនុភាពផងដែរ ។ ប៉ុន្តែម្ចាស់បណ្តាំពុំអាចបោះបង់សិទ្ធលុបចោលមតកសាសន៍បានឡើយ ។

ករណីអញ្ញត្រកម្មមួយដែលសន្តតិជនត្រូវបានសន្មតជាអច្ច័យលាភី ហើយសន្តតិជននោះបានទទួលមរណភាព ត្រូវចាត់ទុកថាជាការកំណត់ចំពោះជនដែលធ្វើសន្តតិកម្មជំនួសបុគ្គលនោះដោយយោងតាមមាត្រា ១១៩៦ និងមាត្រា១២០០នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

ឧទាហរណ៍៖ ក្នុងមត៌កសរុបមាន ផ្ទះ ឡាន ប្រាក់ និងបំណុលសរុប ។ ម្ចាស់បណ្តាំ "ក" បានសរសេរក្នុងមតកសាសន៍ដោយបានធ្វើអច្ច័យទាននូវផ្ទះឱ្យទៅអច្ច័យលាភីដែលជាតតិយជន ។ ក្រោយមកអច្ច័យលាភីនោះបានទទួលមរណភាពមុនម្ចាស់បណ្តាំ ។ ដូចនេះ អច្ច័យទានពុំបង្កើតអានុភាពឡើយ ។

**កថាខណ្ឌទី២- សិទ្ធិជាកម្មសិទ្ធិករលើកម្មវត្ថុនៃអច្ច័យទាន**

អច្ច័យទានពុំមានអានុភាពឡើយ ប្រសិនបើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះមិនស្ថិតនៅក្នុងមត៌កនៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។[54] អច្ច័យទាន គឺជាសកម្មភាពចាត់ចែងមត៌កសម្រាប់អ្នកដែលមានសិទ្ធិចាត់ចែង ពោលគឺជាកាតព្វកិច្ចចាត់ចែងមត៌កឱ្យទៅអច្ច័យលាភីតាមខ្លឹមសារនៃអច្ច័យទាន ។ ប៉ុន្តែប្រសិនបើតម្លៃជាក់ស្តែងនៃមត៌កមិនអាចឱ្យអ្នកមានសិទ្ធិចាត់ចែងធ្វើការចាត់ចែងបានទេ នោះនាំឱ្យខ្លឹមសារនៃអច្ច័យទានមិនអាចត្រូវអនុវត្តបាន និងពុំនាំឱ្យមានអានុភាពឡើយ ។ ក្រោយពេលមរណភាពរបស់ម្ចាស់បណ្តាំដើម្បីឱ្យអច្ច័យទានមានអានុភាពបាន លុះត្រាតែតម្លៃនៃមត៌កជាក់ស្តែងនៅពេលដែលបើកសន្តតិកម្មមានលទ្ធភាពឱ្យអ្នកមានសិទ្ធិចាត់ចែងធ្វើការចាត់ចែងបាន បើមិនដូច្នោះទេនឹងមិនមានអានុភាពឡើយ ។

ឧទាហរណ៍៖ ក- ចំនួនសុរបនៃមត៌កមាន ១,០០០ USD ពេលនោះទោះបីជាបានធ្វើមតកសាសន៍ឱ្យទិញដីដែលមានតម្លៃ ៣,០០០ USD ឱ្យទៅអច្ច័យលាភី "ខ" ដែលបានជួយថែរក្សាខ្លួនក៏ដោយ ក៏មិនមានអានុភាពដែរ ។ ជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានមិនចាំបាច់ចេញលុយខ្លួនឯង ដើម្បីប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ទេ ។ ផ្ទុយទៅវិញ ប្រសិនបើមតកសាសន៍ចែងថា ឱ្យលក់ដីជាក់លាក់មួយ ហើយយក ៥០០ USD ពីប្រាក់ដែលបានមកពីការលក់ដីនោះឱ្យទៅអច្ច័យលាភី "ខ" មតកសាសន៍នោះនឹងមាន

[53] មាត្រា១១៩០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[54] មាត្រា១២០៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សុពលភាព ។[55]

ខ- ម្ចាស់បណ្តាំ "ក" បានធ្វើមតកសាសន៍ដោយធ្វើអច្ច័យទានមានកំណត់នូវទឹកប្រាក់ចំនួន ១០,០០០ USD ឱ្យទៅអច្ច័យលាភី "ខ" ។ នៅពេលបើកសន្តតិកម្មមត៌កសរុបមានទ្រព្យជាលុយសុទ្ធចំនួន ២,០០០ USD ប៉ុណ្ណោះដោយសារកាលនៅពេលមានជីវិត មតកជនបានធ្លាក់ខ្លួនឈឺ ហើយបានលក់ផ្ទះ និងឡាន ដើម្បីព្យាបាលជំងឺរបស់ខ្លួន ។ ក្នុងករណីនេះ សន្តតិជនដែលមានចំនួន៣នាក់ ពុំអាចបំពេញកាតព្វកិច្ចតាមខ្លឹមសារនៃអច្ច័យទានឱ្យទៅអច្ច័យលាភីបានឡើយ ។

[55] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧,ភាគ៦,ទំព័រ៦៨

# ជំពូកទី ៣
# អានុភាពនៃអច្ច័យទាន

ក្នុងជំពូកស្តីពី "អានុភាពនៃអច្ច័យទាន" នេះមានការបង្ហាញផ្នែកធំៗចំនួន ៤ ដែលក្នុងនោះរួមមាន៖

ផ្នែកទី១៖ មរណភាពរបស់ម្ចាស់បណ្តាំ

ផ្នែកទី២៖ ករណីដោយឡែកនៃអច្ច័យលាភីដែលទទួលមរណភាព ឬក្លាយជាអភ័ព្វបុគ្គល

ផ្នែកទី៣៖ ករណីមានការដាស់តឿនរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍ទៅកាន់អច្ច័យលាភី

ផ្នែកទី៤៖ ករណីអច្ច័យទានមានលក្ខខណ្ឌ

## ផ្នែកទី១៖ មរណភាពរបស់ម្ចាស់បណ្តាំ

### កថាខណ្ឌទី១- មរណភាពរបស់ម្ចាស់បណ្តាំដោយធម្មជាតិ

អច្ច័យទាននឹងបង្កើតអនុភាព នៅពេលម្ចាស់បណ្តាំទទួលមរណភាព ។ ប៉ុន្តែក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះត្រូវបំពេញក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះត្រូវបានអនុវត្តចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះត្រូវមានអនុភាពចាប់ពីពេលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ ។[56]

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មរតកជន នាពេលទទួលមរណៈភាព ។ ក្នុងករណីចាំបាច់មួយចំនួនដូចជា ការបោះបង់នូវសន្តតិកម្ម ការយល់ព្រមដោយមាន កម្រិត ការបែងចែកមរត៏កជាអាទិ៍ ចាំបាច់ត្រូវមានការអន្តរាគមន៏របស់តុលាការចំពោះ សន្តតិកម្ម ។ តុលាការដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់មរតកជន នៅពេលដែល មរតកជននោះទទួលមរណៈភាព ជាតុលាការដែលមានសមត្ថកិច្ច ។

ជាគោលការណ៏ អច្ច័យទាននឹងមានអានុភាពនៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។ នេះគឺដោយសារតែអច្ច័យទាន គឺឆន្ទៈរបស់ម្ចាស់បណ្តាំក្នុងការសម្រេចនូវកម្មសិទ្ធទ្រព្យសម្បត្តិជាអាទិ៏ ក្រោយពេលដែលសាមីខ្លួនទទួលមរណភាព ។

នៅក្នុងករណីដែលមតកសាសន៏ ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌ នោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាពមតកសាសន៏ ត្រូវមានអានុភាពចាប់ពីពេលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ ។

ឧទាហរណ៏៖ ការធ្វើអច្ច័យទាននូវដីធ្លីដែលមានផ្ទះ ដោយតម្រូវអោយមានអាពាហ៏ពិពាហ៏នៃអច្ច័យលាភីជាលក្ខខណ្ឌបង្អង់ ។ ចំពោះករណីនេះអានុភាពនៃមតកសាសន៏នេះនឹងកើតឡើងនៅពេលមានអាពាហ៏ពិពាហ៏

[56] មាត្រា១១៩៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព ។

បើមតកជន បានកំណត់ចំណែកមតក ឬវិធីបែងចែកមត៌កដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើនអោយចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

ដោយឡែក នៅក្នុងករណីដែលមតកសាសន៍ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះត្រូវបានបំពេញ នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់ខាងលើនេះ ត្រូវបានធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្មគិតចាប់តាំងពីពេលដែលមតកជននោះបានទទួលមរណភាព ។

### កថាខណ្ឌទី២- មរណភាពរបស់ម្ចាស់បណ្តាំដោយការប្រកាសអំពីការបាត់ខ្លួន

ការប្រកាសអំពីការបាត់ខ្លួននៃរូបវន្តបុគ្គលណាម្នាក់មានន័យស្មើនឹងជននោះបានទទួលមរណភាព ដែលជាមូលហេតុនាំឱ្យមានការចាប់ផ្តើមសន្តតិកម្ម ។ ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា រូបវន្តបុគ្គលណាម្នាក់នៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានបុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។[57] អំឡុងពេល ៥ (ប្រាំ) ឆ្នាំនេះ ត្រូវកាត់បន្ថយមក ១ (មួយ) ឆ្នាំ ក្នុងករណីដែលបុគ្គលបាត់ខ្លួននោះបានបាត់ខ្លួន ដោយសារក្រោយពីបានបញ្ចប់សង្គ្រាម ដែលខ្លួនបានស្ថិតនៅក្រោយពីបានស្ថិតនៅក្នុងហេតុការណ៍នាវាលិច ឬ ក្រោយពីបានប្រទះនឹងគ្រោះថ្នាក់ផ្សេងៗដែលនាំឱ្យទទួលមរណភាព ដែលបានកើតឡើងកន្លងផុតទៅ ។[58] ការប្រកាសអំពីការបាត់ខ្លួនរបស់បុគ្គលណាម្នាក់នាំឱ្យ មតកសាសន៍ដែលបុគ្គលនោះបានធ្វើកន្លងមកត្រូវចាប់ផ្តើមមានអានុភាព ។

ឧទាហរណ៍៖ ក- រវាងការធ្លាក់យន្តហោះ និងការរលំអគារសំណង់ ចំពោះការធ្លាក់យន្តហោះ ពេលរកមិនឃើញសាកសព នោះនឹងសន្មតថាជាការបាត់ខ្លួន រីឯការរលំអគារ ពេលរកមិនឃើញសាកសព នោះនឹងថាជាការអវត្តមាន ព្រោះជនរងគ្រោះអាចមានសង្ឃឹមថានៅមានជីវិតកប់ក្នុងគំនរសំណង់ដែលរលំ ហើយពេលរកឃើញអាចនៅមានជីវិត ឬផុតជីវិត ។ ប៉ុន្តែចំពោះការធ្លាក់យន្តហោះ អត្រានៅរស់គឺតិចតួចជាទីបំផុត ។[59]

---

[57] មាត្រា៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[58] មាត្រា៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[59] សាស្ត្រាចារ្យ ស្រី វណ្ណធី, *នីតិបេតិកកណ្ឌគ្រួសារ*,ទំព័រ១២៨

ខ- បុរស "ក" បានស្ថិតនៅក្នុងយន្តហោះដែលជួបឧបទ្ទវហេតុធ្លាក់មកដីចូលសមុទ្រ ហើយក្នុងហេតុការណ៍នោះមានសាកសពត្រូវបានរកឃើញ និងត្រូវបានកំណត់អត្តសញ្ញាណ រីឯអ្នកដំណើរជាច្រើនផ្សេងទៀតបានបន្តបាត់ខ្លួន ។ រយៈពេល ១០ ឆ្នាំក្រោយមក ស្ត្រី "ខ" ជាភរិយាបានដាក់ពាក្យទៅតុលាការដើម្បីប្រកាសអំពីការបាត់ខ្លួនរបស់ស្វាមីខ្លួន ។ តុលាការបានទទួលពាក្យសុំ និងបានទទួលស្គាល់ ហើយបានប្រកាសអំពីការបាត់ខ្លួនរបស់បុរស "ក" នោះ ។ មុនពេលបាត់ខ្លួន បុរស "ក" បានធ្វើមតកសាសន៍បែងចែកទ្រព្យសម្បត្តិរបស់ខ្លួន ហេតុនេះនាំឱ្យមានការបើកសន្តតិកម្ម ។

## ផ្នែកទី២៖ ករណីដោយឡែកនៃអច្ច័យលាភីដែលទទួលមរណភាព ឬក្លាយជាអភ័ព្វបុគ្គល

ជាគោលការណ៍ អច្ច័យទានពុំមានអានុភាព ប្រសិនបើអច្ច័យលាភីបានទទួលមរណភាព នៅមុនពេល ឬក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។[60] បន្ថែមពីនេះទៀត ករណីដែលអច្ច័យលាភីបានក្លាយជាអភ័ព្វបុគ្គល ក៏ជាហេតុនាំឱ្យអច្ច័យទានពុំមានអានុភាពផងដែរ ។ ប៉ុន្តែមិនមែនជាលក្ខខណ្ឌដាច់ខាតនោះទេ ព្រោះក៏មានករណីអញ្ញត្រកម្មដែលធ្វើឱ្យអច្ច័យលាភីដែលបានទទួលមរណភាពមិនបាត់បង់សិទ្ធិចំពោះអច្ច័យទាន ។

### កថាខណ្ឌទី១- ករណីអច្ច័យលាភីទទួលមរណភាព

#### ១.១. ប្រសិនបើអច្ច័យលាភីទទួលមរណភាពមុនម្ចាស់បណ្តាំ

ជាគោលការណ៍ អច្ច័យលាភីទទួលមរណភាពនោះនាំឱ្យអច្ច័យទានពុំមានអានុភាពឡើយ ប៉ុន្តែមានករណីអញ្ញត្រកម្ម ។ ករណីអញ្ញត្រកម្មនេះមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា១២០០ នៃក្រមរដ្ឋប្បវេណីដែលបានបង្ហាញថាប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈទុកជាមុនរួចជាស្រេចក្នុងមតកសាសន៍ នោះត្រូវអនុលោមតាមឆន្ទៈនោះ ពោលគឺឆន្ទៈរបស់ម្ចាស់បណ្តាំជាអាទិភាពនៃការអនុវត្ត ។ ករណីអច្ច័យលាភីទទួលមរណភាព នោះអច្ច័យទាននឹងត្រូវធ្វើតាមច្បាប់ករណីមតកជនពុំបានកំណត់បង្ហាញឆន្ទៈរបស់ខ្លួនទុកជាមុន ។

#### ១.២. ប្រសិនបើអច្ច័យលាភីជាសន្តតិជន ហើយសន្តតិជនបានទទួលមរណភាពដោយមិនបានទទួលស្គាល់ ឬបោះបង់អច្ច័យទាន

ករណីអច្ច័យលាភីជាសន្តតិជនបានទទួលមរណភាពក្រោយម្ចាស់បណ្តាំដោយមិនទាន់បានបង្ហាញឆន្ទៈទទួលស្គាល់ ឬបោះបង់អច្ច័យទាន នោះវាជាបញ្ហាប៉ះពាល់ដល់សន្តតិកម្មចំពោះខ្លួន ។ ក្នុងករណីនេះសន្តតិជនជំនួសរបស់អច្ច័យលាភីដែលជាសន្តតិជនមានសិទ្ធិក្នុងការទទួលស្គាល់ ឬ ការបោះបង់ត្រឹមតែខ្លឹមសារនៃសន្តតិកម្មប៉ុណ្ណោះ ដោយឡែកអច្ច័យទានវិញ សន្តតិជនជំនួសពុំមានសិទ្ធិសម្រេចក្នុងការទទួលស្គាល់ ឬការបោះបង់ទេ ។ ប៉ុន្តែក៏មានករណីអញ្ញត្រកម្មផងដែរ ប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈទុកជាមុនក្នុងលិខិត

[60] មាត្រា១២០០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អច្ច័យទាន គឺត្រូវអនុវត្តតាមឆន្ទៈនោះជាអាទិភាព ។ [61]

**កថាខណ្ឌទី២- ករណីអច្ច័យលាភីក្លាយជាអភ័ព្វបុគ្គល**

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ ៖

- បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមរតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬលំដាប់ស្មើគ្នា ទោះផ្ទាល់ក្តី ឬប្រយោលក្តី ។
- បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬមិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តន៏ឡើយ ចំពោះករណីដែលបុគ្គលនោះមិនអាច វិនិច្ឆ័យអំពើល្អ ឬអាក្រក់បាន ឬករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។
- បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬកែប្រែមតកសាសន៏ស្តីពីសន្តតិកម្មដោយការឆបោក ឬគម្រាមកំហែង ។
- បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬកែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬគម្រាមកំហែង ។
- បុគ្គលដែលបានក្លែងបន្លំ កែបន្លំ បំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៏ស្តីពីសន្តតិកម្មរបស់មតកជន ។

មតកជន កាលនៅរស់អាចដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់ចំណែកមត៌កដែលត្រូវសន្មតថា សន្តតិជននោះមិនអាចទទួលសន្តតិកម្មបាន ។ ប្រសិនបើជនដែលជាអច្ច័យលាភីបានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ដូចខាងក្រោម ៖

- បានធ្វើបាបចំពោះមតកជន ។
- បានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។
- អាចមកមើលថែទាំមរតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។
- បានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសអោយជាប់ពន្ធធនាគារអស់មួយជីវិត ។
- បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរអោយកត់សំគាល់ ។

ករណីអច្ច័យលាភីមិនមែនជាសន្តតិជនហើយបានក្លាយជាអភ័ព្វបុគ្គលក៏ដោយ ក៏មានករណីអញ្ញត្រកម្មផងដែរ ពោលគឺមានកំណត់ក្នុងមាត្រា ១១៩៨ នៃក្រមរដ្ឋប្បវេណី ដែលបានបង្ហាញថា ប្រសិន បើអច្ច័យលាភីបានក្លាយជាអភ័ព្វបុគ្គលក៏ដោយ ប៉ុន្តែប្រសិនបើម្ចាស់បណ្តាំបានធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនទុកជាមុននៅក្នុង

[61] មាត្រា១២០៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មតកសាសន៍ នោះត្រូវអនុលោមតាមឆន្ទៈនោះ ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទានសកលនូវចំណែកម្នាក់ៗ ១ភាគ៣ នៃមត៌កសរុបឱ្យទៅភាគី "ខ" និង "គ" ដែលជាតតិយជន ។ បន្ទាប់មក ភាគី "ខ" បានទទួលមរណភាពនៅពេលចាប់ផ្តើមសន្តតិកម្ម ដូចនេះនឹងត្រូវធ្វើលទ្ធកម្មដោយសន្តតិជនតាមផ្លូវច្បាប់ ។ ក្នុងករណីនេះប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង ក្នុងមរតកសាសន៍ថាក្នុងករណីអច្ច័យលាភីណាមួយបានទទួលមរណភាពនៅពេលចាប់ផ្តើមសន្តតិកម្ម នោះអច្ច័យលាភីដែលនៅរស់នឹងទទួលបានអច្ច័យទានទាំងអស់ ។ ដូចនេះក្នុងករណីដែលភាគី "ខ" ទទួលមរណភាពនៅពេលចាប់ផ្តើមសន្តតិកម្ម នោះភាគី "គ" នឹងទទួលបានចំណែករបស់ភាគី "ខ" និងចំណែករបស់ខ្លួន សរុប២ភាគ៣ដែលជាមត៌កនៃអច្ច័យទាន ។

## ផ្នែកទី៣៖ ករណីមានការដាស់តឿនរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍ទៅកាន់អច្ច័យលាភី

### កថាខណ្ឌទី១- បុគ្គលដែលជាជនពាក់ព័ន្ធនឹងផលប្រយោជន៍នៃអច្ច័យទាន

ជនដែលអាចធ្វើការដាស់តឿន គឺជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ដោយក្នុងនោះរួមមាន សន្តតិជន អច្ច័យទានសកល ឬនីតិបុគ្គលមត៌ក ហើយក្រៅពីនេះគឺជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ដែលអាចជាម្ចាស់បំណុលរបស់បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ។[62] ជាមួយគ្នានេះដែរ ប្រសិនបើមានអ្នកប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ ។ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានលាឈប់ ឬសន្មតថាបានលាឈប់ នោះសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍នៃមតកសាសន៍មានសិទ្ធិទាមទារឱ្យតុលាការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ។[63]

### កថាខណ្ឌទី២- អានុភាពនៃការដាស់តឿន

នៅពេលចាប់ផ្តើមសន្តតិកម្មគឺនាំឱ្យកើតឡើងនូវសិទ្ធិ និងករណីយកិច្ចពាក់ព័ន្ធនឹងសន្តតិជន និងរួមទាំងតតិយជន ក្នុងនោះការទទួលស្គាល់ និងមិនទទួលស្គាល់អច្ច័យទានរបស់អច្ច័យលាភីក៏អាចជាផលប្រយោជន៍របស់តតិយជនផងដែរ ។ ជនដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានសិទ្ធិដាស់តឿនឱ្យភាគីអច្ច័យលាភីធ្វើការបង្ហាញឆន្ទៈនូវការយល់ព្រមទទួល ឬបោះបង់អច្ច័យ_ទានដោយកំណត់ពេលសមរម្យ ហើយប្រសិនបើផុតអំឡុងពេលកំណត់នេះ ភាគីអច្ច័យលាភីមិនបានបង្ហាញ

[62] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧,ភាគ៦,ទំព័រ៦៤

[63] មាត្រា១២១៤ និងមាត្រា១២២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ឆន្ទៈណាមួយនោះត្រូវចាត់ទុកថាអច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។[64]

ឧទាហរណ៍៖ ស្ត្រី "ក" គឺជាអច្ច័យលាភីនៃអច្ច័យទាននូវដីមួយកន្លែងរបស់មត៌កជន "ខ" ។ ចាប់តាំងពីពេលចាប់ផ្តើមសន្តតិកម្ម អស់រយៈពេល២ខែកន្លងមក ស្ត្រី "ក" ដែលជាភាគីអច្ច័យលាភីមិនដែលបានបង្ហាញពីឆន្ទៈរបស់ខ្លួនទៅសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍សន្តតិកម្មថាខ្លួនយល់ព្រមទទួល ឬបដិសេធនោះទេ ។ សន្តតិជនម្នាក់ក្នុងចំណោមសន្តតិជនដទៃបានដាស់តឿនឱ្យភាគីអច្ច័យលាភី "ក" ឱ្យបង្ហាញឆន្ទៈចំពោះអច្ច័យទានដោយកំណត់រយៈពេល ៣ (បី) ខែ ។ ១ (មួយ) ខែក្រោយ ភាគីអច្ច័យលាភី "ក" បានផ្តល់ព័តមានទៅកាន់សន្តតិជនវិញថាខ្លួនបោះបង់អច្ច័យទាននេះ ។

## ផ្នែកទី៤៖ ករណីពិសេសអច្ច័យមានភ្ជាប់លក្ខខណ្ឌ

អច្ច័យទានភ្ជាប់បន្ទុកអាចស្ថិតនៅក្នុងប្រភេទនៃអច្ច័យទានសកល និងអច្ច័យទានមានកំណត់ ហើយការទទួលស្គាល់ ឬបោះបង់ក៏អាស្រ័យលើប្រភេទនៃអច្ច័យទានផងដែរ ។ អច្ច័យទានភ្ជាប់មានលក្ខខណ្ឌ និងនីតិវិធីទទួលស្គាល់ ឬបោះបង់ទៅតាមប្រភេទនៃអច្ច័យទាននោះ ។ ក្នុងនេះទៀតសោត អច្ច័យទានភ្ជាប់បន្ទុកគឺមានលក្ខណៈពិសេស ក្រោយការទទួលស្គាល់រួចហើយ អច្ច័យលាភីនៃអច្ច័យទានភ្ជាប់មានទំនួលខុសត្រូវលើបន្ទុកនោះ ។

### កថាខណ្ឌទី១- អច្ច័យទានមានភ្ជាប់បន្ទុក

#### ១.១. អច្ច័យលាភីទទួលខុសត្រូវមានកម្រិតនៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

កម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកពុំមានអ្វីខុសប្លែកពីអច្ច័យទានទូទៅដែលមិនមានភ្ជាប់បន្ទុក ឬលក្ខខណ្ឌបង្អង់នោះឡើយ ប៉ុន្តែចំពោះតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក អច្ច័យលាភីត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។[65] ក្នុងន័យនេះ ប្រសិនបើអច្ច័យលាភីយល់ព្រមទទួលយកអច្ច័យទានដែលមានបន្ទុកនេះ អច្ច័យលាភីមានករណីយ_កិច្ចចេញផលកម្រៃ ឬតម្លៃនៃបន្ទុកយ៉ាងច្រើនត្រឹមតែតម្លៃនៃអច្ច័យទានដែលទទួលបានប៉ុណ្ណោះ ទោះបីជាតម្លៃឬផលកម្រៃនៃបន្ទុកនោះមានតម្លៃច្រើនជាងតម្លៃនៃអច្ច័យទានក៏ដោយ ។ ជាការការពារផលប្រយោជន៍ជូនដល់អច្ច័យលាភីដែលទទួលអច្ច័យទានភ្ជាប់បន្ទុក អច្ច័យលាភីត្រូវបានធានាថាការបំពេញថ្លៃបន្ទុកមិនលើសពីតម្លៃនៃអច្ច័យទានដែលនឹងទទួលបាននោះទេ ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទាននូវផ្ទះមួយល្វែងនៅរាជធានីភ្នំពេញឱ្យទៅភាគី "ខ" ជាអច្ច័យលាភី ប៉ុន្តែអច្ច័យលាភី "ខ" ត្រូវបង់ប្រាក់ ៥,០០០ USD ឱ្យទៅភាគី "គ" ។ ក្រោយមកម្ចាស់បណ្តាំ "ក"

[64] មាត្រា១២០២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[65] មាត្រា១២១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បានទទួលមរណភាព អច្ច័យទានមានអានុភាព ។ ផ្ទះមួយល្វែងនោះត្រូវបានសិក្សាតម្លៃដោយភូមិសាស្ត្រអចលទ្រព្យតំបន់មានការធ្លាក់ថ្លៃ ដែលអាចលក់បានត្រឹមតម្លៃ ៤,២០០ USDតែប៉ុណ្ណោះ ។ ក្នុងករណីនេះ ប្រសិន បើអច្ច័យលាភី "ខ" ទទួលយកអច្ច័យទាន នោះអច្ច័យលាភី "ខ" មានករណីយកិច្ចបង់ប្រាក់ ៤,២០០ USD តែប៉ុណ្ណោះឱ្យទៅភាគី "គ" ដើម្បីឱ្យទទួលលទ្ធកម្មនូវផ្ទះមួយល្វែងនោះ ។

**១.២. ករណីតម្លៃនៃកម្មវត្ថុនៃអច្ច័យទានត្រូវបានកាត់បន្ថយ**

ប្រសិនបើសន្តតិជនណាម្នាក់នៃសន្តតិកម្មត្រូវបានបំពាន ឬបាត់បង់ភាគបម្រុងរបស់ខ្លួន នោះអច្ច័យទានគឺជាលំដាប់ដំបូងដែលត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនដែលខ្វះ ។ ដើម្បីបង្គ្រប់ភាគបម្រុងជាដំបូងត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានរបស់ជនដែលជាសន្តតិជនផង និងអច្ច័យលាភីផង ហើយប្រសិនបើនៅតែខ្វះទៀតត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានរបស់បុគ្គលផ្សេងដែលមិនមែនជាសន្តតិជន ហើយអច្ច័យទានត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុ ឬតាមឆន្ទៈពិសេសរបស់ម្ចាស់បណ្តាំ ។[66] ក្នុងការបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុកតាមសមាមាត្រដែលថយចុះ ប៉ុន្តែប្រសិនបើម្ចាស់បណ្តាំបានសម្តែងឆន្ទៈពិសេសទុកជាមុន ត្រូវអនុវត្តតាមឆន្ទៈពិសេសនោះ ។[67]

ឧទាហរណ៍៖ ក- ម្ចាស់បណ្តាំ "ប" បានសរសេរលិខិតមតកសាសន៍ដោយបានធ្វើអច្ច័យទាននូវដីមួយកន្លែងឱ្យទៅភាគី "ផ" ជាអច្ច័យលាភី ប៉ុន្តែតម្រូវឱ្យភាគី "ផ" បង់ប្រាក់ឱ្យភាគី "ព" ចំនួន ២,000 USD ។ នៅពេលចាប់ផ្តើមសន្តតិកម្ម ដីមួយកន្លែងនោះមានតម្លៃជាក់ស្តែងចំនួន ៦,000 USD ហើយភាគី "ផ" ត្រូវបង់ប្រាក់ឱ្យទៅសន្តតិជនចំនួន ៣,000 USD ដើម្បីបង្គ្រប់ភាគបម្រុងដែលខ្វះ ។ ក្នុងករណីនេះ តម្លៃនៃអច្ច័យទានមានចំនួន ៦,000 USD ប៉ុន្តែត្រូវបានកាត់បន្ថយអស់ ៣,000 USD ស្មើនឹង ៥0% នៃតម្លៃនៃអច្ច័យទាន ។ ដូចនេះ តម្លៃនៃបន្ទុកដែលអច្ច័យលាភីត្រូវបំពេញក៏ត្រូវបានកាត់បន្ថយចំនួន ៥0% ដូចនឹងតម្លៃដែលបានកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដែរ ។ ជាសរុប អច្ច័យលាភី "ផ" ត្រូវបង់ថ្លៃបន្ទុកឱ្យទៅភាគី "ព" ចំនួនតែ ១,000 USDប៉ុណ្ណោះ ។

ខ- ម្ចាស់បណ្តាំ "ត" បានសរសេរលិខិតមតកសាសន៍ដោយមានទាំងសន្តតិកម្មចំពោះសន្តតិជន និងរួមទាំងអច្ច័យទាន ។ ម្ចាស់បណ្តាំ "ត" មានមត៌កសរុបដីនិងផ្ទះមួយកន្លែងដែលមានតម្លៃ ២0,000 USD ទឹកប្រាក់សុទ្ធចំនួន ១0,000 USD និងដីចំការមួយកន្លែងដែលមានតម្លៃ ៣,000 USD ។ ក្នុងការធ្វើបណ្តាំនោះម្ចាស់បណ្តាំ "ត" បានបែងចែកឱ្យសន្តតិជន "ត១" ចំនួន ១៣,000 USD សន្តតិជន "ត២" ចំនួន ១២,៥00 USD រួមនឹងអច្ច័យទានចំនួន ២,000 USD សន្តតិជន "ត៣" ចំនួន ២,៥00 USD និងធ្វើអច្ច័យទានឱ្យភាគី

[66] មាត្រា១២៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[67] មាត្រា១២១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

"ថ" នូវដីចំការមួយកន្លែង ប៉ុន្តែភាគី "ថ" ត្រូវបង់ប្រាក់ចំនួន ៩០០ USD ឱ្យទៅភាគី "ទ" ។ ក្នុងករណីនេះតម្លៃមត៌កសរុប ២០,០០០ + ១០,០០០ + ៣,០០០ = ៣៣,០០០ USD ដែលភាគបម្រុងត្រូវនឹង ៣៣,០០០/២ = ១,៦៥០០ USD. ១៦,៥០០/៣ = ៥,៥០០ USD ។ សន្តតិជន "ត៣" បានទទួលតែ ២,៥០០ USD ប៉ុណ្ណោះដែលបំពាននឹងភាគបម្រុងមាន ៥,៥០០ USD ដូចនេះ សន្តតិជន "ត៣" ត្រូវការ ៣,០០០ USD ដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួន ។ សន្តតិជន "ត២" ទទួលបានពីការធ្វើសន្តតិកម្មចំនួន ១២,៥០០ USD និងការធ្វើអច្ច័យទានចំនួន ២,០០០ USD ក្នុងករណីនេះសន្តតិជន "ត២" គឺជាសន្តតិជនផង និងអច្ច័យលាភីផង ហើយជាដំបូងត្រូវធ្វើការកាត់តម្លៃនៃអច្ច័យទានរបស់សន្តតិជន "ត២" ដើម្បីបង្គ្រប់ភាគបម្រុងឱ្យសន្តតិជន "ត៣" ចំនួន ២,០០០ USD ។ ក្រោយពីទទួលការកាត់ពីអច្ច័យទានរបស់សន្តតិជន "ត២" នាំឱ្យសន្តតិជន "ត៣" ទទួលបានសរុប ៤,៥០០ USD ដោយនៅមិនទាន់គ្រប់ភាគបម្រុងនៅឡើយ ពោលគឺនៅខ្វះចំនួន ១,០០០ USD ។ ជាបន្តដើម្បីបង្គ្រប់ភាគបម្រុងត្រូវធ្វើការកាត់បន្ថយពីតម្លៃនៃអច្ច័យទានរបស់អច្ច័យលាភី "ថ" ចំនួន ១,០០០ USD ។ ដីចំការមួយកន្លែងមានតម្លៃ ៣,០០០ USD ដែលជាកម្មវត្ថុនៃអច្ច័យទានត្រូវបានកាត់បន្ថយចំនួន ១,០០០ USD ស្មើនឹង ១/៣ នៃ៣,០០០ USD ក្នុងករណីនេះករណីយកិច្ចដែលត្រូវបង់ឱ្យភាគី "ទ" ចំនួន ៩០០ USD ក៏ត្រូវកាត់បន្ថយ ១/៣ ដែរ ពោលគឺ ១/៣ នៃ៩០០ USD ស្មើនឹង ៣០០ USD និងនៅសល់ចំនួន ៦០០ USD ។ សរុបមក ភាគី "ថ" ត្រូវបង់ឱ្យភាគី "ទ" ចំនួន ៦០០ USD ។

### ១.៣. ករណីដោយឡែកនៃការលុបចោលអច្ច័យទានភ្ជាប់បន្ទុក

អច្ច័យទានដែលមានភ្ជាប់បន្ទុកក៏អាចត្រូវបានលុបចោល ដូចគ្នានឹងអច្ច័យទានសកល និងអច្ច័យទានមានកំណត់ផងដែរ ។ ចំពោះអច្ច័យទានអាចត្រូវបានលុបចោលតាមរយៈការបោះបង់ពីសំណាក់អច្ច័យលាភី ដោយក្នុងនោះការបោះបង់អច្ច័យទានមានកំណត់ គឺគ្រាន់តែតម្រូវឱ្យអច្ច័យលាភីបង្ហាញឆន្ទៈក្នុងការបោះបង់ប៉ុណ្ណោះ រីឯការបោះបង់អច្ច័យទានសកល គឺមានការអនុវត្តដូចនឹងសន្តតិកម្ម ពោលគឺទាមទារឱ្យអច្ច័យលាភីធ្វើការបោះបង់តាមរយៈការដាក់ពាក្យសុំនៅតុលាការ ។ ដោយឡែកការបោះបង់អច្ច័យទានភ្ជាប់បន្ទុក អច្ច័យលាភីមានសិទ្ធិបង្ហាញឆន្ទៈបោះបង់ទៅតាមប្រភេទនៃអច្ច័យទាន និងផ្ទុយពីអច្ច័យទានទាំងនោះត្រង់ថាប្រសិនបើជនដែលមានសិទ្ធិដាស់តឿនបានធ្វើការដាស់តឿនឱ្យបង្ហាញឆន្ទៈ ប្រសិនបើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈទេត្រូវចាត់ទុកថាយល់ព្រមទទួល ប៉ុន្តែចំពោះអច្ច័យទានភ្ជាប់បន្ទុកនេះ ក្រោយពីទទួលការដាស់តឿនហើយ ប្រសិនបើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈនោះទេ ជនដែលមានសិទ្ធិដាស់តឿនមានសិទ្ធិទាមទារទៅតុលាការឱ្យលុបចោលអច្ច័យទាននោះបាន ។ ក្នុងន័យនេះ បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិ_

បត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះអនុវត្តករណីយកិច្ចនោះដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះមិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការឱ្យលុបចោលអច្ច័យទាននោះបាន ។[68]

**កថាខណ្ឌទី២- អច្ច័យទានមានលក្ខខណ្ឌបង្អង់**

ជាទូទៅលក្ខខណ្ឌ សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងនៅពេលអនាគតដែលមិនទៀងទាត់ និងស្ថិតនៅក្នុងស្ថានភាពដែលភាគីនៃកិច្ចសន្យា ឬសកម្មភាពឯកតោភាគី អាចដាក់លក្ខខណ្ឌលើការបង្កើត ឬការរលត់ទៅវិញនូវអានុភាព ហើយការដាក់លក្ខខណ្ឌ លុះត្រាតែលក្ខខណ្ឌនោះមិននាំឱ្យមានការខូចខាតផលប្រយោជន៍ដល់ភាគីម្ខាងទៀត ។[69] ដោយឡែកចំពោះអច្ច័យទានដែលមានភ្ជាប់លក្ខខណ្ឌបង្អង់ ម្ចាស់បណ្ដាំបានធ្វើបណ្ដាំជាអំណោយដល់អច្ច័យលាភី ប៉ុន្តែអច្ច័យលាភីមានសិទ្ធិទទួលអំណោយនៃអច្ច័យទាននោះលុះត្រាតែបានបំពេញលក្ខខណ្ឌដែលម្ចាស់បណ្ដាំបានកំណត់នោះ ។ ប្រសិនបើម្ចាស់បណ្ដាំទទួលមរណភាព ដែលសន្តតិកម្មនឹងត្រូវចាប់ផ្ដើមពិតមែនក៏ដោយ សន្តតិកម្ម ឬអច្ច័យទាននោះនៅតែមិនមានអានុភាពអនុវត្តន៍បាន ដោយសារតែភាគីអច្ច័យលាភីមិនទាន់បំពេញលក្ខខណ្ឌដែលមត៌កជនបានកំណត់ក្នុងមតកសាសន៍ ។ ដូចនេះករណីអច្ច័យទានភ្ជាប់លក្ខខណ្ឌបង្អង់ គឺជាការតម្រូវឱ្យអច្ច័យលាភីបំពេញលក្ខខណ្ឌរបស់ម្ចាស់បណ្ដាំជាមុនសិនក្នុងអំឡុងពេលមុនមរណភាពរបស់ម្ចាស់បណ្ដាំ ដែលជាពេលវេលានៃការចាប់ផ្ដើមនៃអច្ច័យទាន ។

ឧទាហរណ៍៖ ក- បុរស "ក" បានធ្វើអច្ច័យទានមានកំណត់នូវផ្ទះមួយល្វែងនៅរាជធានីភ្នំពេញឱ្យទៅបុរស "ខ" ក្នុងករណីដែលបុរស "ខ" បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាមុនសិន ។

ខ- ក្នុងករណី បុរស "ក" បានទទួលមរណភាព ដែលនាំឱ្យអច្ច័យទានមានអានុភាពក្នុងការប្រគល់ផ្ទះមួយល្វែងឱ្យទៅបុរស "ខ" ដូចមានចែងក្នុងបណ្ដាំ ប៉ុន្តែដោយសារបុរស "ខ" មិនទាន់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅឡើយ នោះបុរស "ខ" មិនមានសិទ្ធិក្នុងការទទួលយកផ្ទះមួយល្វែងនោះទេ ដោយសារខ្លួនមិនទាន់បំពេញលក្ខខណ្ឌរបស់ម្ចាស់បណ្ដាំនៅឡើយ ។ នៅពេលអនាគតដែលបុរស "ខ" នឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នោះបុរស "ខ" នឹងមានសិទ្ធិក្នុងការទទួលបានផ្ទះមួយល្វែងនៃអច្ច័យទានរបស់មត៌កជន "ក" នោះ ។

គ- បុរស "ខ" ជាអច្ច័យលាភីបានទទួលមរណភាពមុនម្ចាស់បណ្ដាំ នោះនាំឱ្យអច្ច័យទានពុំបង្កើតអានុភាពឡើយ ទោះបីជាបុរស "ខ" មិនទាន់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឬបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្ដី ។

---

[68] មាត្រា១១៩៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[69] មាត្រា៣២៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**កថាខណ្ឌទី៣- កម្មវត្ថុនៃអច្ច័យទានភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន**

ប្រសិនបើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទានជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជននៅពេលដែលមានម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។[70] ក្នុងករណីនេះបានបង្ហាញឱ្យឃើញថាជាស្វ័យប្រវត្តិប្រសិនបើកម្មវត្ថុនៃអច្ច័យទាននេះមានការជាប់ទាក់ទងនឹងផលប្រយោជន៍របស់តតិយជនដទៃ នោះអច្ច័យលាភីដែលទទួលស្គាល់អច្ច័យទានត្រូវបំពេញកាតព្វកិច្ចដើម្បីរំលត់សិទ្ធិដែលពាក់ព័ន្ធនឹងតតិយជននោះ ហើយនាំឱ្យខ្លួនអាចធ្វើលទ្ធកម្មទទួលកម្មវត្ថុនៃអច្ច័យទាននោះ ។ ក្នុងន័យនេះជាស្វ័យប្រវត្តិ វានាំឱ្យមានលក្ខខណ្ឌ ដែលតម្រូវឱ្យអច្ច័យលាភីបំពេញកាតព្វកិច្ចដើម្បីទទួលយកអច្ច័យទាន ។

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" បានយកដី១ហិកតាដែលជាកម្មសិទ្ធិរបស់ខ្លួន ដែលកំពុងជាប់ហ៊ីប៉ូតែកនៅធនាគារ (ដីមានតម្លៃ ២០,០០០ USD ដាក់ហ៊ីប៉ូតែកធានាបំណុល ៥,០០០ USD) ធ្វើជាអច្ច័យទានមានកំណត់ឱ្យទៅភាគី "ខ" អច្ច័យលាភី ។ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំ ប្រសិនបើភាគី "ខ" យល់ព្រមទទួលអច្ច័យទាន នោះអច្ច័យលាភីត្រូវអនុវត្តកិច្ចសងបំណុលទៅធានាគារ ដើម្បីធ្វើលទ្ធកម្មទទួលយកដី១ហិកតានោះ ។ ក្នុងករណីនេះ អច្ច័យលាភី "ខ" មិនអាចទាមទារឱ្យសន្តតិជន ឬអ្នកមានសិទ្ធិចាត់ចែងមត៌កអនុវត្តកាតព្វកិច្ចសងបំណុលនោះ ដើម្បីឱ្យខ្លួនទទួលលទ្ធកម្មលើដី១ហិកតានោះឡើយ ។

[70] មាត្រា១២០៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី ៤
# សិទ្ធិរបស់អច្ច័យលាភី

ក្នុងជំពូកស្ដីពី "សិទ្ធិរបស់អច្ច័យលាភី" នេះមានការបង្ហាញពីផ្នែកធំៗចំនួន ៤ ដែលនៅក្នុងនោះរួមមាន៖

ផ្នែកទី១៖ ការទទួលស្គាល់ និងការបោះបង់អច្ច័យទានអច្ច័យទានមានកំណត់

ផ្នែកទី២៖ ការទទួលស្គាល់ និងការបោះបង់អច្ច័យទានអច្ច័យទានសកល

ផ្នែកទី៣៖ ករណីដោយឡែកនៃការទទួលស្គាល់ និងការបោះបង់ ដែលអច្ច័យលាភីជាសន្តតិជន

ផ្នែកទី៤៖ ករណីពិសេសនៃការលុបចោលនូវការទទួលស្គាល់ ឬការបោះបង់អច្ច័យទាន

## ផ្នែកទី១៖ ការទទួលស្គាល់ និងការបោះបង់អច្ច័យទានមានកំណត់

អច្ច័យទានមានកំណត់ សំដៅដល់ទម្រង់ដូចនឹងប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ដោយមតកសាសន៍ ។[71] ចំពោះអច្ច័យទានមានកំណត់ អានុភាពមាននៅពេលដែលម្ចាស់បណ្ដាំទទួលមរណភាព អច្ច័យលាភី អាចបង្ហាញឆន្ទៈក្នុងការទទួលស្គាល់អច្ច័យទានមានកំណត់នោះ និងករណីមិនបានសម្ដែង ឬបង្ហាញឆន្ទៈទទួលស្គាល់ ក៏ត្រូវបានចាត់ទុកថាអច្ច័យលាភីបានយល់ព្រមទទួលយកអច្ច័យទានមានកំណត់នោះ ។ ដោយឡែកចំពោះការបោះបង់អច្ច័យទានវិញ អច្ច័យលាភីនៃអច្ច័យទានមានកំណត់មានសិទ្ធិបោះបង់អច្ច័យទាននៅពេលណាក៏បាន មុនពេលទទួលបានការដាស់តឿនពីអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ដោយការបង្ហាញឆន្ទៈមិនទទួលយកអច្ច័យទានមានកំណត់នោះ ។[72]

ឧទាហរណ៍៖ ម្ចាស់បណ្ដាំ "ក" បានធ្វើលិខិតបណ្ដាំដោយក្នុងនោះបានផ្ញើអច្ច័យទានមានកំណត់នូវដីមួយកន្លែងឱ្យទៅបុរស "ខ" ជាភាគីអច្ច័យលាភី ។ លុះពេលដល់ចាប់ផ្ដើមសន្តតិកម្ម បុរស "ខ" បានដឹងអំពីព័ត៌មានអំពីអច្ច័យទានរបស់ខ្លួន បុរស "ខ" មិនចង់បានកម្មវត្ថុនៃអច្ច័យទាននោះទេ ហើយជាបន្ទាប់ក៏បានធ្វើការបង្ហាញឆន្ទៈទៅកាន់សន្តតិជន និងអ្នកប្រតិបត្តិមតកសាសន៍ក្នុងការបដិសេធទទួលអច្ច័យទាននោះ ។

## ផ្នែកទី២៖ ការទទួលស្គាល់ និងការបោះបង់អច្ច័យទានសកល

### កថាខណ្ឌទី១- ការទទួលស្គាល់អច្ច័យទានសកល

អច្ច័យទានសកល សំដៅដល់ទម្រង់ដូចនឹងប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ ។[73] អច្ច័យលាភី នៃអច្ច័យទានសកលមានសិទ្ធិ និងករណីយកិច្ចដូចនឹងសន្តតិជន ដែលក្នុងនោះការបោះបង់អច្ច័យទានសកលត្រូវអនុវត្តដូចនឹងការបោះ

[71] មាត្រា១១៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[72] មាត្រា១២០១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[73] មាត្រា១១៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បង់សន្តតិកម្ម ប៉ុន្តែចំពោះការទទួលស្គាល់អច្ច័យទានសកល ពុំមានបញ្ញត្តិច្បាប់ថាត្រូវអនុវត្តដូចនឹងការទទួលស្គាល់សន្តតិកម្មនោះទេ ។ ដូចនេះការទទួលស្គាល់អច្ច័យទានសកលក៏ត្រូវអនុវត្តដូចនឹងករណីអច្ច័យទានទូទៅផងដែរ ពោលគឺអច្ច័យទានមានកំណត់ ដែលមិនចាំបាច់បង្ហាញឆន្ទៈ ឬបង្ហាញឆន្ទៈទទួលស្គាល់ទៅកាន់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍នៃអច្ច័យទាន ។

**១.១- ការយល់ព្រមទាំងស្រុង**

អច្ច័យលាភីនៃអច្ច័យទានសកលមានសិទ្ធិ និងករណីយដូចនឹងសន្តតិជន ដែលការយល់ព្រមអច្ច័យទានសកលនោះគឺដូចនឹងការយល់ព្រមលើសន្តតិកម្មចំពោះសន្តតិជនដែរ ។ សកម្មភាពរបស់អច្ច័យលាភីសកលត្រូវបានចាត់ទុកថាយល់ព្រមទាំងស្រុងតាមច្បាប់ ក្នុងករណី៖

ក- បើសន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និងសកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ- បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬការបោះបង់ នៃក្រមរដ្ឋប្បវេណី) ។

គ- ទោះបីជាសន្តតិជនបានយល់ព្រម ឬបោះបង់ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។[74]

**១.២- ការយល់ព្រមដោយមានកម្រិត**

**១.២.១- នីតិវិធីនៃការយល់ព្រមដោយមានកម្រិត**

នៅក្នុងការបង្កើតអានុភាពនៃការយល់ព្រមដោយមានកម្រិត អច្ច័យលាភីសកលត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិត រួមជាមួយបញ្ជីសារពើភ័ណ្ឌទៅកាន់តុលាការ ។[75] តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម ។ សហសន្តតិជនត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិតដោយរួមគ្នាទាំងអស់ ។ ដូច្នេះហើយប្រសិនបើសន្តតិជនម្នាក់សុខចិត្តយល់ព្រមទាំងស្រុង ហើយមិនយល់ព្រមសហការដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិតទេនោះ សន្តតិជនដទៃទៀតមិនអាចយល់ព្រមដោយមានកម្រិតលើសន្តតិកម្មនោះបានឡើយ ។ ម្យ៉ាងវិញទៀត ទោះបីជាសន្តតិជនម្នាក់បានបោះបង់សន្តតិកម្មក៏ដោយ ក៏សន្តតិជនដទៃនៅតែអាចយល់ព្រមដោយមានកម្រិតបានដែរ ដោយសារតែបុគ្គលដែលបានបោះបង់នោះ ត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង (មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណី) ។[76]

[74] ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០,ក្រមរដ្ឋប្បវេណី,មាត្រា១២៥៥

[75] ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០,ក្រមរដ្ឋប្បវេណី,មាត្រា១២៥៧

[76] សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ៣,ទំព័រ១០១

### ១.២.២- ករណីអច្ច័យលាភីសកលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើអច្ច័យលាភីសកលជាអនីតិជន ឬជាជននៅក្រោមអាណាព្យាបាលទូទៅ អច្ច័យលាភីសកលនោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបាននោះទេ លើកលែងតែជាអនីតិជនដែលទទួលបានអត្តាធីនភាពតែប៉ុណ្ណោះ ។ បើទោះបីតែអច្ច័យលាភីសកលនោះបានទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អាណាព្យាបាលរបស់អនីតិជន ឬអាណាព្យាបាលទូទៅ) ក៏ដោយ ក៏សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបានដែរ ។ ដើម្បីឱ្យអច្ច័យលាភីសកលនោះអាចយល់ព្រមដោយមានកម្រិតបាន អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវដាក់ពាក្យសុំ (មាត្រា១៧ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋ_ប្បវេណីដែលមិនមែនជាបណ្ដឹង) ។ ប្រសិនបើបានតែងតាំងអ្នកត្រួតពិនិត្យសម្រាប់អ្នកណាព្យាបាលទូទៅ ឬអាណាព្យាបាលរបស់អនីតិជនត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យនោះជាមុនសិន ( មាត្រា ១០៩០ និង មាត្រា ១១២៦ នៃក្រមរដ្ឋប្បវេណី ) ។[77]

### ១.២.៣- ករណីអច្ច័យលាភីសកលជាជននៅក្រោមហិតូបត្ថម្ភ:

អច្ច័យលាភីសកល ដែលមានសិទ្ធិ និងករណីយកិច្ចដូចសន្តតិជនអាចដាក់ពាក្យសុំដោយខ្លួនឯង ប៉ុន្តែត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈទៅតាមលក្ខខណ្ឌច្បាប់ដែលបានកំណត់ ។ មួយវិញទៀតហិតូបត្ថម្ភកៈមិនអាចដាក់ពាក្យសុំក្នុងនាមជាជននៅក្រោមហិតូបត្ថម្ភនោះទេ ដោយសារតែហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

## កថាខណ្ឌទី២- ការបោះបង់អច្ច័យទានសកល

ការបោះបង់អច្ច័យទានសកល គឺត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។ សម្រាប់ការបោះបង់នេះ ភាគីអច្ច័យលាភីដែលមានបំណងបោះបង់ អច្ច័យទានសកលត្រូវកាន់ពាក្យសុំការបោះបង់អច្ច័យទានទៅតុលាការ ។[78] ភាគីអច្ច័យលាភីត្រូវធ្វើការបោះបង់អច្ច័យទានសកលទាំងស្រុង ឬដោយមានកម្រិតនៅក្នុងអំឡុងពេល ៣ (បី) ខែ ដោយគិតចាប់ពីពេលដែលអច្ច័យលាភីដឹងថាអច្ច័យទានចំពោះខ្លួនចាប់ផ្ដើម ។[79]

ឧទាហរណ៍៖ ម្ចាស់បណ្ដាំ "ក" បានធ្វើលិខិតបណ្ដាំដោយក្នុងនោះបានធ្វើអច្ច័យទានសកលនូវចំណែក១ភាគ៥ នៃតម្លៃមត៌កសរុប ឱ្យទៅបុរស "ខ" ជាភាគីអច្ច័យលាភី ។ លុះពេលដល់ចាប់ផ្ដើមសន្តតិកម្ម បុរស "ខ" បានដឹងអំពីព័ត៌មានអំពីអច្ច័យទានសកលចំពោះខ្លួន បុរស "ខ" មិនចង់បានកម្មវត្ថុនៃអច្ច័យទានសកលនោះទេ

[77] សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ៣,ទំព័រ៩៦

[78] មាត្រា១២៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[79] មាត្រា១២៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ហើយជាបន្ទាប់ក៏បុរស "ខ" បានធ្វើការដាក់ពាក្យសុំបោះបង់អច្ច័យទានទៅតុលាការ ។ សេចក្តីសម្រេចរបស់តុលាការក្នុងការទទួលស្គាល់នូវការបោះបង់អច្ច័យទាន គឺត្រូវបានចាត់ទុកថាបុរស "ខ" មិនមែនជាអច្ច័យលាភីតាំងពីដំបូង ។

### ២.១. នីតិវិធីនៃការបោះបង់

អច្ច័យលាភីសកលត្រូវដាក់ពាក្យសុំបោះបង់សន្តតិកម្មទៅកាន់តុលាការ ដើម្បីបង្កើតអានុភាពនៃការបោះបង់អច្ច័យទានសកល ។ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម (មាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១៤) ។ ការដាក់ពាក្យសុំបោះបង់អច្ច័យទានសកលត្រូវធ្វើឡើងដោយអច្ច័យលាភីសកលម្នាក់ៗ(ករណីមានអច្ច័យលាភីច្រើន) ។ ដូចនេះ អ្នកដាក់ពាក្យមិនបាច់ដាក់ពាក្យសុំជាមួយអច្ច័យលាភីសកល ឬសន្តតិជនដទៃទេឡើយ ។ លើសពីនេះទៀត ថ្វីត្បិតតែអច្ច័យលាភីសកលម្នាក់ ឬសន្តតិជនម្នាក់បានធ្វើការយល់ព្រមទាំងស្រុងលើសន្តតិកម្មក៏ដោយ ក៏សន្តតិជនផ្សេងទៀតនៅតែអាចធ្វើការបោះបង់អច្ច័យទានបានដែរ ។[80]

### ២.២. ករណីអច្ច័យលាភីសកលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ

ដូចនឹងករណីការយល់ព្រមដោយមានកម្រិត គឺការយល់ព្រមដោយមានកម្រិតករណីអច្ច័យលាភីសកលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ (១.២.២) និងការយល់ព្រមដោយមានកម្រិតករណីអច្ច័យលាភីសកលជាជននៅក្រោមហិតូបត្ថម្ភ (១.២.៣) ក្នុងផ្នែកនេះ ។

## ផ្នែកទី៣៖ ករណីដោយឡែកនៃការទទួលស្គាល់ ឬបោះបង់ ដែលអច្ច័យលាភីជាសន្តតិជន

ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើសន្តតិជនបានបោះបង់សន្តតិកម្ម នោះត្រូវចាត់ទុកថាសន្តតិជនដែលជាអច្ច័យលាភីបានបោះបង់អច្ច័យទានផងដែរ ។ ជាគោលការណ៍អច្ច័យលាភីជាសន្តតិជន មិនអាចទទួលស្គាល់សន្តតិកម្មបានឡើយ ប្រសិនបើបានបោះបង់អច្ច័យទាន ។ ប៉ុន្តែប្រសិនបើអច្ច័យលាភីជាសន្តតិជនបានបោះបង់អច្ច័យទាន នោះសន្តតិជននៅតែអាចទទួលសន្តតិកម្មដែលមានចំពោះខ្លួនដដែល ។

## ផ្នែកទី៤៖ ករណីពិសេសនៃការលុបចោលនូវការទទួលស្គាល់ និងការបោះបង់អច្ច័យទាន

### កថាខណ្ឌទី១- មូលហេតុនៃការលុបចោលនូវការទទួលស្គាល់ និងការបោះបង់

អច្ច័យលាភីនៃអច្ច័យទានទាំងអច្ច័យទានមានកំណត់ ឬសកលដែលធ្លាប់បានទទួលស្គាល់ ឬបោះបង់រួចហើយ គឺមិនអាចលុបចោលវិញបានទេ ប៉ុន្តែក៏មានករណីអញ្ញត្រកម្មដែលអាចនាំឱ្យមានការលុបចោល ។ នីតិវិធីនៃការលុបចោលនូវការយល់ព្រម ឬការបោះបង់អច្ច័យទានត្រូវអនុវត្តដូចគ្នានឹងបញ្ញត្តិនៃការលុបចោលនូវ

[80] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ៣,ទំព័រ៩៦

ការយល់ព្រម ឬបោះបង់សន្តតិកម្ម ។[81] ការបង្ហាញឆន្ទៈដោយមានវិការៈក្នុងការយល់ព្រម ឬបោះបង់គឺជាមូល_ហេតុនាំឱ្យមានការលុបចោល ក្នុងន័យនេះអច្ច័យលាភីមានសិទ្ធិលុបចោលនូវការយល់ព្រម ឬបោះបង់កន្លងមកដោយសារតែមានវិការៈ ។

ក្នុងសន្ធានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧ បានផ្តល់និយមន័យយ៉ាងខ្លីថា វិការៈ គឺជាការប្រែប្រួលចាកពីភាពប្រក្រតី ។ អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈពោលគឺមានភាពមិនប្រក្រតី ។[82] ទម្រង់ដែលចាត់ទុកថាជាការបង្ហាញមានវិការៈមានដូចជា៖

- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។
- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។
- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងចំណេញហួសហេតុ ។

**ក- ការភាន់ច្រឡំ**

ការភាន់ច្រឡំ មានន័យថានៅក្នុងករណីដែលអ្នកបង្ហាញឆន្ទៈបានធ្វើការបង្ហាញឆន្ទៈដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយគេក៏មិនបានដឹងអំពីភាពខុសគ្នានេះនៅពេលដែលគេធ្វើការបង្ហាញឆន្ទៈឡើយ ។[83]

**ខ- ការឆបោក**

ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថាបុគ្គលណាម្នាក់ ឬតតិយជនបានធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងគាត់មិនបានដឹងពីភាពខុសគ្នានេះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ ។

លក្ខខណ្ឌដើម្បីកំណត់ថាជាការឆបោកនោះ អាចកំណត់បាននូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

១- ភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងឆបោក

២- សកម្មភាពឆបោកនោះ ត្រូវបានទទួលស្គាល់ថាខុសច្បាប់

៣- អ្នកបង្ហាញឆន្ទៈបានភាន់ច្រឡំ ដោយសារសកម្មភាពឆបោក

៤- អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយមានវិការៈដោយសារតែការភាន់ច្រឡំនោះ ។[84]

[81] មាត្រា១២០៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[82] មាត្រា៣៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[83] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ១,ទំព័រ១២០

**គ- ការគំរាមកំហែង**

លក្ខខណ្ឌនៃការគំរាមកំហែងគឺមានដូចខាងក្រោម៖

១- ភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងធ្វើឱ្យអ្នកបង្ហាញឆន្ទៈធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនមានការភ័យខ្លាច ។

២- សកម្មភាពបង្ខំត្រូវបានទទួលស្គាល់ថាខុសច្បាប់

៣- សកម្មភាពបង្ខំធ្វើឱ្យអ្នកបង្ហាញឆន្ទៈខ្លាច

៤- អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារការភ័យខ្លាចនោះ ។[85]

**ឃ- ការបង្ហាញព័ត៌មានមិនពិត**

លក្ខខណ្ឌនៃការផ្តល់ព័ត៌មិនពិតមានដូចខាងក្រោម៖

១- ហេតុដែលភាគីម្ខាង បានលើកឡើងសម្រាប់ជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិត ។

២- ប្រសិនបើអ្នកបង្ហាញឆន្ទៈបានដឹងថាហេតុនោះមិនមែនជាការពិត ខ្លួននឹងមុនបង្ហាញឆន្ទៈទេ។

៣- ភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលខ្លួនបានបង្ហាញនោះមិនមែនជាការពិត ។[86]

ឧទាហរណ៍៖ ម្ចាស់បណ្តាំ "ក" បានធ្វើអច្ច័យទានសកលនូវចំណែក១ភាគ៧នៃតម្លៃនៃមត៌កសរុបឱ្យទៅអច្ច័យលាភី "ខ" ប៉ុន្តែតម្រូវឱ្យអច្ច័យលាភី "ខ" បង់ប្រាក់ ១០,០០០ USD ឱ្យទៅបុគ្គល "គ" ។ តាមការទទួលព័ត៌មានមិនច្បាស់លាស់ អច្ច័យលាភីបានភាន់ច្រឡំថាតម្រូវឱ្យបង់ប្រាក់ ១០០,០០០ USD ឱ្យទៅបុគ្គល "គ" ដែលនាំឱ្យខ្លួនបានធ្វើការបោះបង់ទទួលអច្ច័យទាននេះ ដោយពិចារណាឃើញថាចំណែក១ភាគ៧នៃមត៌កសរុបមានតែចំនួនស្មើនឹង ២០,០០០ USD ប៉ុណ្ណោះ ។ ក្រោយពីការបោះបង់រួចហើយ អច្ច័យលាភីបានទទួលព័ត៌មានបន្ថែម និងពិតប្រាកដ ហើយជាបន្ទាប់អច្ច័លាភី "ខ" បានធ្វើការលុបចោលនូវការបោះបង់របស់ខ្លួនកន្លងមកស្របតាមនីតិវិធី ។

## កថាខណ្ឌទី២៖ អាជ្ញាយុកាលនៃសិទ្ធិលុបចោលនូវការទទួលស្គាល់ និងការបោះបង់អច្ច័យទាន

### ២.១. ថិរវេលា ៦ខែ គិតចាប់ពីពេលអាចផ្តល់សច្ចានុមតិ

[84] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ១,ទំព័រ១២៧

[85] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ១,ទំព័រ១៣២

[86] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី,ឆ្នាំ២០១៧,ភាគ១,ទំព័រ១៣២

អច្ច័យលាភីមានសិទ្ធិលុបចោលការយល់ព្រម ឬការបោះបង់អច្ច័យទានក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដោយគិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។[87] សច្ចានុមតិ សំដៅដល់ការយល់ព្រមទទួលស្គាល់ ដែលមានអានុភាពប្រតិសកម្ម ។[88] ក្នុងន័យនេះ អច្ច័យលាភីមានសិទ្ធិធ្វើការលុបចោលនូវការយល់ព្រម ឬការ បោះបង់របស់ខ្លួនចំពោះអច្ច័យទាននៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលអច្ច័យលាភីខ្លួន ឯងបានដឹងថាខ្លួនអាចធ្វើការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាននោះ ។

ឧទាហរណ៍៖ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំ "ក" សន្តតិកម្មបានចាប់ផ្តើមដោយក្នុងចំណោមនោះ មានការធ្វើអច្ច័យទាននូវដីមួយកន្លែងឱ្យទៅអច្ច័យលាភី "ខ" ហើយអច្ច័យលាភីខ្លួនឯងក៏បានដឹងអំពីដំណឹងនៃ អច្ច័យទាននេះរួចរាល់ដែរ ។ ១ (មួយ) ខែបន្ទាប់ការចាប់ផ្តើមសន្តតិកម្ម អច្ច័យលាភី "ខ" បានបង្ហាញឆន្ទៈ បោះបង់ដោយមិនទទួលយកអច្ច័យទាននេះទេ ប៉ុន្តែតាមការពិត អច្ច័យទាន "ខ" បានទទួលការគម្រាមកំហែង ដល់អាយុជីវិតពីសំណាក់សន្តតិជន "គ" ។ រយៈពេល ២ (ពីរ) ខែក្រោយពីការបោះបង់អច្ច័យទាន អច្ច័យលាភី "ខ" បានស្វែងរកការពិគ្រោះពីអ្នកច្បាប់ ហើយក្រោយពីការពិគ្រោះផ្នែកច្បាប់មក អច្ច័យលាភី "ខ" ក៏បានដឹងថា ខ្លួនមានសិទ្ធិធ្វើការលុបចោលនូវការបោះបង់នោះ ។ រយៈពេល ១ (មួយ) ខែបន្ទាប់អច្ច័យលាភី "ខ" បានដាក់ ពាក្យសុំលុបចោលនូវការបោះបង់អច្ច័យទានរបស់ខ្លួនទៅតុលាការ ដោយមូលហេតុថាសិទ្ធិលុបចោលនូវការ បោះបង់មានអំឡុងពេល ៦ (ប្រាំមួយ) ខែដោយគិតចាប់ពីពេលដែលអច្ច័យលាភីដឹងអំពីសិទ្ធិលុបចោលនូវការ បោះបង់អច្ច័យទានមិនទាន់ហួសនៅឡើយទេ ។

### ២.២. ថិរវេលា ៥ឆ្នាំ គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម

អច្ច័យលាភីមានសិទ្ធិលុបចោលនូវការយល់ព្រម ឬការបោះបង់អច្ច័យទាននៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ដោយគិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។[89] ការចាប់ផ្តើមសន្តតិកម្មមានអានុភាពនៅពេលដែល ម្ចាស់បណ្តាំទទួលមរណភាព ហើយប្រសិនបើអច្ច័យទាននោះមានភ្ជាប់លក្ខខណ្ឌបង្អង់ ឬលក្ខខណ្ឌភ្ជាប់បន្ទុក អច្ច័យលាភីបានបំពេញលក្ខខណ្ឌនោះ ។ ក្នុងន័យនេះ អច្ច័យទានមានសិទ្ធិលុបចោលនូវការយល់ព្រម ឬ ការ បោះបង់របស់ខ្លួនចំពោះអច្ច័យទាននៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ដោយគិតចាប់ពីពេលដែលសន្តតិកម្មមាន អានុភាពអនុវត្តបាន ។

ឧទាហរណ៍៖ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំ "ក" សន្តតិកម្មបានចាប់ផ្តើមដោយក្នុងចំណោមនោះ មានការធ្វើអច្ច័យទាននូវដីមួយកន្លែងឱ្យទៅអច្ច័យលាភី "ខ" ហើយអច្ច័យលាភីខ្លួនឯងក៏បានដឹងអំពីដំណឹងនៃ

[87] មាត្រា១២៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[88] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី

[89] មាត្រា១២៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អច្ច័យទាននេះរួចរាល់ដែរ ។ ១ (មួយ) ខែបន្ទាប់ការចាប់ផ្តើមសន្តតិកម្ម អច្ច័យលាភី "ខ" បានបង្ហាញឆន្ទៈបោះបង់ដោយមិនទទួលយកអច្ច័យទាននេះទេ ប៉ុន្តែតាមការពិត អច្ច័យទាន "ខ" បានទទួលការគម្រាមកំហែងដល់អាយុជីវិតពីសំណាក់សន្តតិជន "គ" ។ រយៈពេល ៤ (បួន) ឆ្នាំក្រោយពីការបោះបង់អច្ច័យទាន អច្ច័យលាភី "ខ" បានជួបដោយចៃដន្យជាមួយអ្នកដែលចំណេះដឹងផ្លូវច្បាប់ម្នាក់ ហើយក្រោយពីបានជជែក និងពិគ្រោះពីអ្នកច្បាប់នោះ អច្ច័យលាភី "ខ" បានដឹងថាខ្លួនមានសិទ្ធិធ្វើការលុបចោលនូវការបោះបង់នោះ ។ រយៈពេល ១ (មួយ) ខែបន្ទាប់អច្ច័យលាភី "ខ" បានដាក់ពាក្យសុំលុបចោលនូវការបោះបង់អច្ច័យទានរបស់ខ្លួនទៅតុលាការដោយមូលហេតុថាសិទ្ធិលុបចោលនូវការបោះបង់មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំដោយគិតពីចាប់ផ្តើមសន្តតិកម្មមិនទាន់ហួសនៅឡើយទេ ពោលគឺមានរយៈពេលសរុបត្រឹម ៤ឆ្នាំ និង២ខែ ប៉ុណ្ណោះ ។

# សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវស្តីពីអំពី **"របបគតិយុត្តនៃអច្ច័យទាននៃកម្ពុជា"** បានបង្ហាញឱ្យឃើញថាអច្ច័យទានដែលជាផ្នែកមួយស្ថិតក្នុងសន្តតិកម្មតាមមតកសាសន៍នោះពិតជាមានសារៈសំខាន់ សម្រាប់ជីវិតរស់នៅឯកជននៃក្រុមគ្រួសារនីមួយៗនិយាយដោយឡែក និងសម្រាប់ការរីកចំរើននៃសង្គមនិយាយជារួម ។ មិនតែប៉ុណ្ណោះទ្រឹស្តីច្បាប់ក៏មានទំនាក់ទំនងនឹងទ្រឹស្តីព្រះពុទ្ធផងដែរ ដោយតម្រូវអោយយើងចេះយល់យោគ គោរពគ្នា ស្គាល់ចិត្តនឹងរំងាប់ចិត្ត ព្រមទាំងចេះគ្រប់គ្រងភាពលោភលន់ដែលជាហេតុក្នុងការទាស់ទែងនាពេលបែងចែកមរតក ។ ម៉្យាងវិញទៀត ទ្រឹស្តីទាំងពីរនេះក៏មានទំនាក់ទំនងរវាងទ្រព្យ និងម្ចាស់ទ្រព្យនាពេលទទួលមរណៈភាពផងដែរ ។

មនុស្សម្នាក់ៗរស់នៅ តែងតែមានទ្រព្យភ្ជាប់ខ្លួនដែលអាចជាទ្រព្យសកម្ម និង ទ្រព្យអកម្ម ហើយនៅពេលខ្លួនទទួលអនិច្ចកម្មដោយប្រការណាមួយមិនថាជំងឺចាស់ជរា ឃាតកម្ម ឬឧបទ្វេវហេតុនោះទេ នៅពេលនោះទ្រព្យរបស់ខ្លួនចាំបាច់ត្រូវមានអ្នកទទួលខុសត្រូវ ។ អាទិភាពក្នុងការស្វែងរកអ្នកទទួលខុសត្រូវនូវមត៌ករបស់ម្ចាស់បណ្តាំ គឺជាលិខិតបណ្តាំ ប្រសិនបើម្ចាស់បណ្តាំមិនបានធ្វើលិខិតបណ្តាំនោះទេ មត៌កដែលមានទាំងសិទ្ធិ និងករណីយកិច្ចនឹងត្រូវអនុវត្តតាមបញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ ពោលគឺក្នុងក្រមរដ្ឋប្បវេណីដែលកំពុងស្ថិតនៅជាធរមាន ។ ការអនុវត្តតាមឆន្ទៈរបស់មតកជនក្នុងមតកសាសន៍មានន័យស្មើនឹងការកំណត់វិធីបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន ។ មតកជនមានសិទ្ធិផ្តល់ទ្រព្យឱ្យជនណាក៏បាន តម្លៃប៉ុន្មានក៏បាន ប៉ុន្តែជាគោលការណ៍ និងជាការការពារចំពោះសន្តតិជន ក្នុងនោះជាអប្បបរមា សន្តតិជនត្រូវទទួលបានចំណែកមត៌កនូវភាគបម្រុង ហើយការគណនាភាគបម្រុងគឺស្របតាមការកំណត់នៃបញ្ញត្តិច្បាប់ ។ អច្ច័យទាន គឺជាកិច្ចសន្យាប្រទានកម្មដែលមានចរិតលក្ខណៈជាកិច្ចសន្យាឯកតោភាគី ដោយ ទាយកឬម្ចាស់បណ្តាំ មានសិទ្ធិផ្តល់ឱ្យ និង បដិគ្គាហកឬអច្ច័យលាភី មានសិទ្ធិឯកភាពទទួល ។ លក្ខណៈសម្បត្តិនៃម្ចាស់បណ្តាំរួមមាននីតិជន អនីតិជនទទួលអត្តាធីនភាព ជននៅក្រោមអាណាព្យាបាលទូទៅជននៅក្រោមហិតូបត្ថម្ភ ហើយជាលក្ខខណ្ឌគឺខណៈពេលធ្វើលិខិតមតកសាសន៍ បុគ្គលទាំងនេះចាំបាច់ត្រូវមានសមត្ថភាពខាងឆន្ទៈ រីឯលក្ខណៈសម្បត្តិនៃអច្ច័យលាភីរួមមានសមាសភាពដូចនឹងម្ចាស់បណ្តាំ និងបូករួមទាំងអនីតិជនគ្មានអត្តាធីនភាព និងទារកក្នុងគ័ភ ក្នុងករណីអច្ច័យលាភីនេះ អាចជាសន្តតិជន ឬមិនមែនជាសន្តតិជន ហើយប្រសិនបើអច្ច័យលាភីបានទទួលមរណភាពមុន ឬដំណាលគ្នានឹងម្ចាស់បណ្តាំ នោះត្រូវផ្អែកលើឆន្ទៈរបស់ម្ចាស់បណ្តាំ ប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈទុកជាមុននៅក្នុងមតកសាសន៍ ។ ដើម្បីឱ្យលិខិតបណ្តាំមួយក្លាយជាមតកសាសន៍ត្រឹមត្រូវ លុះត្រាតែលិខិតបណ្តាំនោះធ្វើឡើងតាមទម្រង់ដែលមានកំណត់ក្នុងច្បាប់ ដែលក្នុងនោះមានលិខិតយថាភូត លិខិតឯកជន និងលិខិតសម្ងាត់ ហើយមានវិធីផ្សេងទៀតដោយអាស្រ័យលើលក្ខណៈសម្បត្តិ និងស្ថានភាពនៃម្ចាស់បណ្តាំ ។ កម្មវត្ថុនៃអច្ច័យទាន គឺមានសិទ្ធិ និងវត្ថុ ចំពោះសិទ្ធិមាននូវសិទ្ធិលើបំណុលជាប្រាក់ សិទ្ធិទាមទារឱ្យ

ប្រគល់សងវត្ថុ សិទ្ធិលើកម្មសិទ្ធិអវិភាគ និងសិទ្ធិទទួលយកបន្តនូវសុពលភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ រីឯចំពោះវត្ថុមាននូវចលនវត្ថុ និងអចលនវត្ថុ ។ ជាគោលការណ៍ មរណភាពនៃម្ចាស់បណ្តាំ គឺជាបុព្វហេតុនៃការផ្តើមសន្តតិកម្ម ឬជាការដែលនាំឱ្យអច្ច័យទានមានអានុភាព ។ ដើម្បីធានាថានៅពេលចាប់ផ្តើមសន្តតិកម្ម អច្ច័យ_ទាននៅតែមានសុពលភាពអាចអនុវត្តបាន លុះត្រាតែម្ចាស់បណ្តាំមិនបានលុបចោលខ្លឹមសារអច្ច័យទាននោះ និង ម៉្យាងទៀតស្ថានភាពនៃមត៌កអាចផ្តល់លទ្ធភាពឱ្យអ្នកមានសិទ្ធិចាត់ចែងមត៌កអនុវត្តខ្លឹមសារនៃអច្ច័យទានជូនទៅភាគីអច្ច័យលាភី ។ ក្នុងនេះដែរ រវាងម្ចាស់បំណុល និងអច្ច័យទាន ជាអាទិភាពអ្នកមានសិទ្ធិចាត់ចែងមត៌កត្រូវធ្វើការសងបំណុលឱ្យទៅកូនបំណុលជាមុនសិន មុននឹងមកបំពេញអច្ច័យទានចំពោះអច្ច័យលាភី ។ អច្ច័យទានមានប្រភេទទៅតាមកម្មវត្ថុ ប្រសិនបើកម្មវត្ថុជាចំណែកនៃភាគណាមួយ នោះហៅថា អច្ច័យទាន_សកល ហើយដែលមានលក្ខខណ្ឌដូចនឹងសន្តតិកម្មចំពោះសន្តតិជនដែរ រីឯកម្មវត្ថុនៃចំណែកវត្ថុណាមួយមានកំណត់ច្បាស់លាស់ នោះហៅថា អច្ច័យទានមានកំណត់ ម៉្យាងវិញទៀតប្រសិនបើមតកជនបានដាក់លក្ខខណ្ឌ ឬកាតព្វកិច្ចឱ្យអច្ច័យលាភីបំពេញ នោះគឺជាអច្ច័យទានមានលក្ខខណ្ឌ ដោយក្នុងនោះមានលក្ខខណ្ឌបង្អង់ និងមានបន្ទុក ។ អច្ច័យលាភី មានសិទ្ធិយល់ព្រមទទួល និងបដិសេធមិនទទួលយកអច្ច័យទាន ប៉ុន្តែប្រសិនបើការបដិសេធទទួលយកកន្លងមកនោះកើតឡើងដោយមានវិការៈ អច្ច័យលាភីមានសិទ្ធិបោះបង់នូវការយល់ព្រម ឬបដិសេធនោះ ដោយធ្វើការដាក់ពាក្យសុំទៅតុលាការដែលមានសមត្ថកិច្ច ។

សរុបមក អច្ច័យទានមានសារៈសំខាន់ណាស់សម្រាប់អច្ច័យលាភី និងម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ ដោយបុគ្គលជាសន្តតិជនមានសិទ្ធិទទួលអំណោយបន្ថែមដោយស្របច្បាប់ក្រៅពីចំណែកមតក៌ ហើយបុគ្គលដែលមិនមែនជាសន្តតិជនក៏មានសិទ្ធិទទួលអំណោយពីមតកជនដោយស្របច្បាប់ ហើយទាំងនេះបានបង្ហាញឱ្យឃើញថាឆន្ទៈរបស់មតកជនត្រូវបានគោរព ពោលគឺការយកឆន្ទៈរបស់មតកជនជាអាទិភាពនៃការអនុវត្ត ។

# អនុសាសន៍

ការសិក្សាស្រាវជ្រាវនូវប្រធានបទ **"របបគតិយុត្តនៃអច្ច័យទាននៅកម្ពុជា"** សម្រាប់ចំណុចស្តីពីអច្ច័យទាន នេះមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ដែលជាច្បាប់ទូទៅនៃនីតិឯកជន ពោលគឺទាក់ទងនឹងមូលដ្ឋាននៃឯកជនភាពរបស់មនុស្សម្នាក់ៗ ។ ចំណុចស្តីពីអច្ច័យទានទាំងនោះពិតជាត្រូវបានបញ្ញត្តិឡើងដោយមានអត្ថន័យ និងខ្លឹមសារគ្រប់គ្រាន់សម្រាប់សាធារណៈជនអាចធ្វើការឈ្វេងយល់ និងអនុវត្តតាម ហើយជាពិសេសសម្រាប់មន្ត្រីក្នុងស្ថាប័នតុលាការដែលគួរធ្វើការសិក្សា និងឈ្វេងយល់ជាចាំបាច់ឱ្យបានលម្អិត ដើម្បីត្រៀមខ្លួន និងបន្តបំពេញតួនាទីក្នុងការធ្វើការសម្រេចសេចក្តីទាំងឡាយដែលពាក់ព័ន្ធនឹងវិវាទប្រភេទនេះប្រកបដោយគុណភាពឱ្យបានជាអតិបរមា ។

ប៉ុន្តែទន្ទឹមនឹងវត្តមានក្នុងក្រមរដ្ឋប្បវេណីនេះ ការធ្វើអច្ច័យទានពីមតកជនឱ្យទៅអច្ច័យលាភី បើទោះបីជាអច្ច័យលាភីមានសិទ្ធិទទួលស្គាល់ ឬបោះបង់ក៏ដោយ ប៉ុន្តែក៏ធ្វើឱ្យអច្ច័យលាភីដែលមិនមែនសន្តតិជនខាតបង់ពេលវេលា និងផលប្រយោជន៍ផ្សេងៗ ក្នុងករណីដែលកម្មវត្ថុនៃអច្ច័យទាននោះ គឺជាអច្ច័យទានសកល ហើយដែលមតកជនបានធ្វើអច្ច័យទាននូវមតកទាំងអស់របស់ខ្លួនឱ្យទៅអច្ច័យលាភី ដែលជាហេតុនាំឱ្យអច្ច័យលាភីមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងសន្តតិជន ។ ប្រសិនបើអច្ច័យលាភីទទួលស្គាល់អច្ច័យទាន ហើយដែលកម្មវត្ថុនៃអច្ច័យទាននោះផ្តល់ប្រយោជន៍ដល់ខ្លួន នោះចាត់ទុកថាមិនធ្វើឱ្យអច្ច័យលាភីខាតបង់ផលប្រយោជន៍ទេ ប៉ុន្តែករណីមតកជនបានបន្សល់នូវបំណុល ហើយដែលបំណុលនោះមានតម្លៃខ្ពស់ជាតម្លៃមតកដែលមាននោះទោះបីរូបភាពណាមួយក៏ដោយ ក៏ធ្វើឱ្យអច្ច័យលាភីខាតបង់ប្រយោជន៍របស់ខ្លួនដែរ ។ ករណីអច្ច័យលាភីទទួលស្គាល់អច្ច័យទានសកលដោយមានកម្រិត អច្ច័យលាភីមានកាតព្វកិច្ចដាក់ពាក្យសុំទៅតុលាការ ហើយដែលលទ្ធផលនៃការទទួលខុសត្រូវក្រោយពីសងបំណុលនោះបើទោះបីមិននាំឱ្យខាតបង់ទ្រព្យផ្ទាល់ខ្លួនក្តី ប៉ុន្តែយ៉ាងហោចណាស់ក៏បានបង្កការលំបាកនូវការខាតបង់ពេលវេលា និងប្រាក់ចំណាយផ្សេងៗពាក់ព័ន្ធនឹងដាក់ពាក្យសុំទៅតុលាការ ។ ករណីអច្ច័យលាភីបោះបង់អច្ច័យទានសកល ដូចនឹងការទទួលស្គាល់ដោយមានកម្រិតដែរ ដែលអច្ច័យលាភីសកលត្រូវមានកាតព្វកិច្ចដាក់ពាក្យសុំបោះបង់ទៅតុលាការផងដែរ ។

បញ្ញត្តិស្តីពីអច្ច័យទានក្នុងក្រមរដ្ឋប្បវេណី អនុញ្ញាតឱ្យអច្ច័យលាភីសកលដែលមិនមែនជាសន្តតិជនមានសិទ្ធិ និងករណីយកិច្ចដូចនឹងសន្តតិជន ហើយបើទោះបីជាមិនចង់ទទួលយកអច្ច័យទាននោះ ក៏អច្ច័យលាភីសកលមានកាតព្វកិច្ចត្រូវបំពេញពាក់ព័ន្ធនឹងការបោះបង់ ដោយក្នុងនោះយ៉ាងហោចណាស់ក៏នាំឱ្យខាតបង់ពេលវេលា និងអាចមានជាសោហ៊ុយចំណាយផ្សេងៗទៀតផង ។

សរុបមក ជារួមបញ្ញត្តិស្តីពីអច្ច័យទានមានភាពល្អគ្រប់គ្រាន់ និងវិជ្ជមានសម្រាប់ក្នុងដំណើរវិវត្តន៍សង្គម ។ ប៉ុន្តែមាននូវចំណុចពាក់ព័ន្ធនឹងអច្ច័យលាភីសកលដែលមិនមែនជាសន្តតិជន ដែលអច្ច័យលាភីប្រភេទនេះមិន

មានសិទ្ធិបោះបង់ត្រឹមការបង្ហាញនូវឆន្ទៈដូចនឹងការបោះបង់អច្ច័យទានមានកំណត់ឡើយ ហើយដែលចំណុច នេះគួរតែមានការកែតម្រូវឱ្យអច្ច័យលាភីសកលដែលមិនមែនជាសន្តតិជនធ្វើការបោះបង់ ឬទទួលស្គាល់ដោយ មានកម្រិតត្រឹមការបង្ហាញឆន្ទៈរបស់ខ្លួន ។

# ឯកសារយោង

## ១- បទដ្ឋានគតិយុត្ត

### ១.១. រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។

### ១.២. ក្រម

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។
- ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ (បច្ចុប្បន្នត្រូវបាននិរាករណ៍) ។

### ១.៣. ច្បាប់

- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ឧសភា ២០១១ ។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១២៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ ។

## ២- សៀវភៅ និងឯកសារផ្សេងៗ

### ២.១. សៀវភៅមេរៀនលោក និងលោកស្រីសាស្ត្រាចារ្យ

- លោកសាស្ត្រាចារ្យ Peter Backer (ឆ្នាំ២០១០ ដល់២០១២ ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់ជាន់ខ្ពស់ផ្នែកច្បាប់ព្រឹទ្ធសភាពនៃព្រះរាជាណាចក្រកម្ពុជា និងបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), *សេចក្តីផ្តើមក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា*
- លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, *នីតិមរតក,* ឆ្នាំ២០០៥
- លោកស្រីសាស្ត្រាចារ្យ ស្រី វណ្ណធី, *នីតិបេតិកភណ្ឌគ្រួសារ,* ឆ្នាំ២០២១

### ២.២. ឯកសារផ្សេងៗ

- គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ_អង់គ្លេស_បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី*, ឆ្នាំ២០០៧ ។

- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,* ភ្នំពេញ ២០០៩ - ២០១០ ។
- ក្រុមការងារនៃ គ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១-៣,* ភ្នំពេញ ខែមីនា ឆ្នាំ២០១៧ ។
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ក្រុមការងារកិច្ចការរដ្ឋប្បវេណី, *សិក្ខាសាលាស្តីពី "អច្ច័យទាន និងភាគបម្រុង"*, ភ្នំពេញ ២៤ តុលា ២០១៣ ។
- សមាគមត្រាជូ, *អត្ថបទបកថាសាធារណៈស្តីពីនីតិគ្រួសារ និងវិជ្ជាជីវៈសារការី,* ខែ វិច្ឆិកា ឆ្នាំ២០១៨ ។

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាម
ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

ឧបសម្ព័ន្ធ២៖ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាម
ព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ឧសភា ២០១១ ។

ឧបសម្ព័ន្ធ៣៖ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាម
ព្រះរាជក្រមលេខ នស/រកម/០៧១០/០១២៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ ។

# ឧបសម្ព័ន្ធ ១

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ក្រមរដ្ឋប្បវេណី

# គន្ថីទី ២

# បុគ្គល

## ជំពូកទី ១

## រូបវន្តបុគ្គល

### ផ្នែកទី ១

### សមត្ថភាពទទួលសិទ្ធិ

**មាត្រា ៦.–** គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច បាន ។

**មាត្រា ៧.–** ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬ កាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបាន កំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា អន្តរជាតិ ។

**មាត្រា ៨.–** ពេលចាប់ផ្តើម និង បញ្ចប់សមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់ បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព ។

**មាត្រា ៩.–** ទារកនៅក្នុងគភ៌

១-ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើត នៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួន នៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន ។

២-ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមាន

កំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន ។

៣-ទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្ដាំនោះបាន ។

## ផ្នែកទី ២
## សិទ្ធិបុគ្គល

**មាត្រា ១០.-** អត្ថន័យនៃសិទ្ធិបុគ្គល

សិទ្ធិបុគ្គល សំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល ។

**មាត្រា ១១.-** សិទ្ធិទាមទារឱ្យបញ្ឈប់

ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬ មានការបារម្ភថា ការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្ត ឬ នឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈប់នូវការរំលោភនោះបាន ។

**មាត្រា ១២.-** សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ

បើស្ថានភាពរំលោភសិទ្ធិបុគ្គលនៅតែមានជាបន្តបន្ទាប់ ដោយសារសំណល់នៃលទ្ធផលដែលកើតពីសកម្មភាពរំលោភនោះ អ្នកដែលបានទទួលរងនូវការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់នោះ អាចទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភនោះបាន លុះត្រាតែលទ្ធផលនោះអាចដកចេញបាន ។

**មាត្រា ១៣.-** សិទ្ធិទាមទារសំណងការខូចខាត

បញ្ញត្តិនៃមាត្រា ១១ (សិទ្ធិទាមទារឱ្យបញ្ឈប់) និង មាត្រា ១២ (សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ) នៃក្រមនេះ មិនរារាំងការទាមទារសំណងការខូច

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១
### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.-** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.-** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.-** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថ-ភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.-** ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.–** អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.–** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

## កថាភាគទី ២
## ជននៅក្រោមអាណាព្យាបាលទូទៅ

**មាត្រា ២៤.–** ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ នៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភចំពោះជននោះ ។

**មាត្រា ២៥.–** អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ២៦.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣

## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

បានធ្វើឡើងដោយជននៅក្រោមហិត្ថបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិត្ថបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន :

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្ដឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិត្ថបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្ដើមហិត្ថបត្ថម្ភ) នៃក្រមនេះ ឬ ហិត្ថបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិត្ថបត្ថម្ភកៈ ។

**មាត្រា ៣១.-** ការលុបចោលការប្រកាសចាប់ផ្ដើមហិត្ថបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្ដើមហិត្ថបត្ថម្ភ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមហិត្ថបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ហិត្ថូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិត្ថូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៤
## ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

**មាត្រា ៣២.–** សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបាន ក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើសកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិត្ថូបត្ថម្ភកៈ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិនទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិត្ថូបត្ថម្ភកៈ មិនឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិត្ថូបត្ថម្ភទទួលយកសច្ចានុមតិពីហិត្ថូបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិនបើជននៅក្រោមហិត្ថូបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

**មាត្រា ៣៣.–** ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក

ហួសសិទ្ធិដែលបុគ្គលអវត្តមានបានកំណត់ អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើយល់ឃើញថា សមរម្យក្នុងការផ្តល់កម្រៃដល់អ្នកគ្រប់គ្រង ដោយគិតពិចារណា នូវទំនាក់ទំនងរវាងអ្នកអវត្តមាន និង អ្នកគ្រប់គ្រង និង ស្ថានភាពផ្សេងទៀត តុលាការអាចផ្តល់កម្រៃចំនួនសមរម្យដល់អ្នកគ្រប់គ្រង ដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមានបាន ។

## កថាភាគទី ២
## ការប្រកាសអំពីការបាត់ខ្លួន

**មាត្រា ៤១.-** ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

**មាត្រា ៤២.-** ការផ្សាយជាសាធារណៈ

ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើង ដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការផ្សាយជាសាធារណៈ ។

**មាត្រា ៤៣.–** អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) នៃក្រមនេះ បន្ទាប់ពីពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ បានកន្លងផុត និង ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រាដដែល បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់កន្លងមករហូតដល់ពេលនោះ ។

**មាត្រា ៤៤.–** ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ

១-ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ ។

២-បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ។ ប៉ុន្តែ បុគ្គលដែលមិនបានដឹងថា ការប្រកាសបាត់ខ្លួននោះ ផ្ទុយពីការពិត នៅពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ។

៣-អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ ។

៤-ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍

# ផ្នែកទី ៤
# លទ្ធកម្មនៃកម្មសិទ្ធិ

## កថាភាគទី ១
## លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ

**មាត្រា ១៦០.–** លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ

កម្មសិទ្ធិលើអចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្ម ដោយកិច្ចសន្យា សន្តតិកម្ម និង ហេតុដែលបានកំណត់នៅក្នុងផ្នែកទី ៤ (លទ្ធកម្មនៃកម្មសិទ្ធិ) នេះ ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬ ច្បាប់ផ្សេង ។

**មាត្រា ១៦១.–** អចលនវត្ថុគ្មានម្ចាស់

អចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ។

**មាត្រា ១៦២.–** អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ

១-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ ។

២-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្តើមកាន់កាប់ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះបីជាប្រភេទណាក៏ដោយ ។

**មាត្រា ១៦៣.–** អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៦២ (អាជ្ញាយុកាល

នៃដីជាប់មាត់ច្រាំងនោះ ត្រូវបង់តម្លៃដែលត្រូវបានកំណត់ដោយអ្នកវាយតម្លៃ ។ តម្លៃនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ត្រូវបានកំណត់ដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងនោះ តាមពាក្យសុំរបស់អាជ្ញាធរខេត្ត-ក្រុង ឬ អ្នកដែលមានពាក់ព័ន្ធផលប្រយោជន៍ ។ ប៉ុន្តែ ក្នុងករណីដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ មិនបង្ហាញឆន្ទៈយកកម្មសិទ្ធិលើបាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះទេ ដីគោកនោះត្រូវបានលក់ជាសាធារណៈដោយអាជ្ញាធរខេត្ត-ក្រុង ។ ប្រាក់ដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងបានបង់ ឬ ប្រាក់ដែលបានទទួលពីការលក់បាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះ ត្រូវបែងចែកឱ្យកម្មសិទ្ធិករដែលបានបាត់បង់ដីដោយសារ ការបង្កើតផ្លូវទឹកថ្មី តាមសមាមាត្រនៃតម្លៃដីដែលបានបាត់បង់ដោយសារទឹកហូរ ។

**មាត្រា ១៨៦.-** ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ

ក្នុងករណីដែលចលនវត្ថុបានក្លាយជាផ្នែកមួយនៃអចលនវត្ថុ ដោយភ្ជាប់ជាមួយនឹងអចលនវត្ថុនោះ កម្មសិទ្ធិលើអចលនវត្ថុនោះ ត្រូវមានអានុភាពទៅលើចលនវត្ថុនោះផងដែរ លើកលែងតែមានបញ្ញត្តិនៃច្បាប់ ឬ ការព្រមព្រៀងពិសេស ។ ក្នុងករណីនេះ អ្នកដែលបានបាត់បង់កម្មសិទ្ធិលើចលនវត្ថុ អាចទាមទារប្រាក់សំណងបាន តាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

## កថាភាគទី ២
## លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

**មាត្រា ១៨៧.-** លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

កម្មសិទ្ធិលើចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្ម ដោយកិច្ចសន្យា សន្តតិកម្ម និងហេតុដែលបានកំណត់នៅក្នុងផ្នែកទី ៤ (លទ្ធកម្មនៃកម្មសិទ្ធិ) នេះ ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬ ច្បាប់ផ្សេង ។

ច្នៃនោះ ត្រូវធ្លាក់ទៅម្ចាស់នៃវត្ថុធាតុដើម ។

២-ក្នុងករណីអ្នកកែច្នៃវត្ថុបានផ្តល់វត្ថុធាតុដើមមួយចំណែក មានតែករណីដែលតម្លៃវត្ថុធាតុដើម ព្រមទាំងតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ លើសពីតម្លៃវត្ថុធាតុដើមនៃអ្នកដទៃទេ ទើបអ្នកកែច្នៃត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុកែច្នៃនោះ ។

**មាត្រា ២០០.-** អានុភាពនៃឧបាគមន៍នៃចលនវត្ថុ

១-ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលត់ ដោយសារការជាប់គ្នា ការលាយច្របល់គ្នា ឬ ការកែច្នៃ សិទ្ធិដែលមាននៅលើវត្ថុនោះ ក៏ត្រូវរលត់ដែរ ។

២-សិទ្ធិរបស់អ្នកដទៃដែលមានលើវត្ថុ ដែលធ្លាប់ជាកម្មសិទ្ធិរបស់ជនដែលក្លាយជាកម្មសិទ្ធិករនៃវត្ថុភ្ជាប់គ្នា វត្ថុលាយច្របល់គ្នា ឬ វត្ថុកែច្នៃ ត្រូវបន្តអត្ថិភាពលើវត្ថុដែលត្រូវបានធ្វើលទ្ធកម្មជាថ្មីនេះទៀត ។ ក្នុងករណីនេះ ប្រសិនបើក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគ សិទ្ធិនោះត្រូវបន្តអត្ថិភាពលើចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគនោះ ។

**មាត្រា ២០១.-** ឧបាគមន៍ និង សិទ្ធិទាមទារប្រាក់សំណង

ជនដែលបាត់បង់សិទ្ធិដោយសារការជាប់គ្នា ការលាយគ្នា ការច្របល់គ្នា ឬ ការកែច្នៃនៃចលនវត្ថុ អាចទាមទារប្រាក់សំណងចំពោះអ្នកដែលបានធ្វើលទ្ធកម្មសិទ្ធិ និង ទទួលផលប្រយោជន៍បាន តាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

## ផ្នែកទី ៥
## កម្មសិទ្ធិអវិភាគ

**មាត្រា ២០២.-** និយមន័យនៃកម្មសិទ្ធិអវិភាគ

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ។

**មាត្រា ២០៣.-** សមភាពនៃចំណែកកម្មសិទ្ធិអវិភាគ

ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មតថា ស្មើគ្នា ។

**មាត្រា ២០៤.–** ការចាត់ចែងចំណែកនៃកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើអនុប្បទាន ឬ ដាក់ជាប្រាតិភោគនូវចំណែករបស់ខ្លួនបាន ។ ម្ចាស់បំណុលនៃម្ចាស់កម្មសិទ្ធិអវិភាគនេះ អាចរឹបអូសចំណែកនោះបាន ។

**មាត្រា ២០៥.–** ការប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគ អាចប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគទាំងមូល តាមសមាមាត្រនៃចំណែករបស់ខ្លួនបាន ។

**មាត្រា ២០៦.–** ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើសកម្មភាពថែទាំវត្ថុកម្មសិទ្ធិអវិភាគដោយឯកឯងបាន ។

**មាត្រា ២០៧.–** ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ មិនអាចចាត់ចែងវត្ថុកម្មសិទ្ធិអវិភាគ ឬ ធ្វើការផ្លាស់ប្តូរអ្វីសំខាន់ៗទៅលើវត្ថុកម្មសិទ្ធិអវិភាគបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត ។

**មាត្រា ២០៨.–** ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ

កិច្ចការទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ ត្រូវសម្រេចដោយមតិភាគច្រើន តាមតម្លៃនៃចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២០៦ (ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ) និង មាត្រា ២០៧ (ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ) នៃក្រមនេះ ។

**មាត្រា ២០៩.–** បន្ទុកនៃវត្ថុកម្មសិទ្ធិអវិភាគ

១-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវទទួលបន្ទុកក្នុងការបង់សោហ៊ុយគ្រប់គ្រង ពន្ធដារ ជាអាទិ៍ តាមសមាមាត្រនៃចំណែករៀងៗខ្លួន ។

២-ភោគីដែលបានចាប់ផ្ដើមកាន់កាប់អចលនវត្ថុនៅមុនពេលប្រកាសឱ្យប្រើច្បាប់ភូមិបាល ហើយបានទទួលការអនុញ្ញាតក្នុងការបន្តការកាន់កាប់ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិពីស្ថាប័នដែលមានសមត្ថកិច្ច អាចអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ចំពោះការបំពានការកាន់កាប់ដោយតតិយជន ។

៣-ក្នុងការអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អំឡុងពេល ១ (មួយ) ឆ្នាំ ដែលបានកំណត់នៅក្នុងមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា ២៤០ (សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់) នៃក្រមនេះ ត្រូវបានបកស្រាយថា ៣ (បី) ឆ្នាំ ។

## ជំពូកទី ៤
## សិទ្ធិជួលអចិន្ត្រៃយ៍

**មាត្រា ២៤៤.-** និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅទៅលើសិទ្ធិជួលអចលនវត្ថុ រយៈពេលវែង ចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤៥.-** ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ បើមិនបានបង្កើតឡើង ជាលាយលក្ខណ៍អក្សរ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ហើយអាចត្រូវបានបញ្ឈប់ ដោយភាគីម្ខាងនៅពេលណាក៏បាន ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៦១៥ (ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល) នៃក្រមនេះ ។

**មាត្រា ២៤៦.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចិន្ត្រៃយ៍

១-អ្នកជួលអចិន្ត្រៃយ៍ មិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍របស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលបានចុះបញ្ជីហើយ អាចតតាំងនឹងអនុប្បទានិកនៃកម្មសិទ្ធិដីដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍បាន ទោះបីជាកម្មសិទ្ធិលើដីនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

៣-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ដែលមិនបានចុះបញ្ជី បញ្ញត្តិនៃមាត្រា ៥៩៨ (ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ) នៃក្រមនេះ ត្រូវយកមកអនុវត្ត រហូតដល់គ្រប់អំឡុងពេល ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២៤៧.–** អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព

១-អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព មិនអាចឱ្យលើសពី ៥០ (ហាសិប) ឆ្នាំ បានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើសពី ៥០ (ហាសិប) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ (ហាសិប) ឆ្នាំ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះមិនអាចលើសពី ៥០ (ហាសិប) ឆ្នាំ ឡើយ គិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មី ។

**មាត្រា ២៤៨.–** ថ្លៃឈ្នួល

១-អ្នកជួលអចិន្ត្រៃយ៍មានករណីយកិច្ចបង់ថ្លៃឈ្នួល ចំពោះអ្នកឱ្យជួលអចិន្ត្រៃយ៍នៅពេលដែលបានកំណត់ ។

២-ប្រសិនបើពុំមានកំណត់ពេលបង់ថ្លៃឈ្នួលទេ អ្នកជួលអចិន្ត្រៃយ៍ត្រូវបង់នៅរាល់ដំណាច់ឆ្នាំ ។ ប៉ុន្តែ ចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយរដូវនោះដោយគ្មានការយឺតយ៉ាវ ។

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.–** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

## មាត្រា ៣៤៧.– ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

## មាត្រា ៣៤៨.– ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.–** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.–** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.–** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥២.-** ថបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

**មាត្រា ៣៥៣.-** ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

**មាត្រា ៣៥៤.-** ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ :

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែល

ទាំងមូលនោះ អ្នកទិញមិនចាំបាច់យល់ព្រមក៏បានដែរ ។

២-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ បានលក់ភាគដែលជាកម្មសិទ្ធិរបស់ខ្លួនម្នាក់ៗទៅអ្នកទិញតែម្នាក់ តាមកិច្ចសន្យាដោយឡែក ដោយមានការសន្យាពិសេសនៃការលោះវិញ ម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗនោះអាចលោះមកវិញ នូវភាគដែលជាកម្មសិទ្ធិរបស់ខ្លួនបាន ។

**មាត្រា ៥៦៥.–** អានុភាពនៃការមិនអនុវត្តសិទ្ធិលោះ

ប្រសិនបើអ្នកលក់មិនអនុវត្តសិទ្ធិលោះក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (អំឡុងពេលនៃការលោះ) នៃក្រមនេះទេ សិទ្ធិលោះត្រូវរលត់ ហើយកម្មសិទ្ធិរបស់អ្នកទិញនឹងក្លាយជាស្ថាពរ ។

## ជំពូកទី ២

## ការដូរ

**មាត្រា ៥៦៦.–** អត្ថន័យ

ការដូរ ត្រូវមានអានុភាព តាមការសន្យាដែលភាគីទាំងសងខាង ធ្វើការផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីប្រាក់ទៅវិញទៅមក ។

**មាត្រា ៥៦៧.–** ការយកបញ្ញត្តិនៃការលក់ទិញមកអនុវត្តដូចគ្នា

បញ្ញត្តិស្តីអំពីការលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការដូរ ។

## ជំពូកទី ៣

## ប្រទានកម្ម

**មាត្រា ៥៦៨.–** និយមន័យ

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាង

ទៀតយល់ព្រមទទួល ។

**មាត្រា ៥៦៩.-** ការផ្ទេរកម្មសិទ្ធិ

ការផ្ទេរកម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុ នៅក្នុងកិច្ចសន្យាប្រទានកម្ម ត្រូវអនុលោមតាមគោលការណ៍ទូទៅដែលកំណត់នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ) និង មាត្រា ១៨៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

**មាត្រា ៥៧០.-** ប្រទានកម្មដែលមិនធ្វើជាលាយល័ក្ខណ៍អក្សរ

ទោះបីជាបានធ្វើការសន្យាប្រទានកម្មក៏ដោយ ប្រសិនបើមិនបានធ្វើជាលាយល័ក្ខណ៍អក្សរស្តីអំពីប្រទានកម្មទេ ភាគីនៃកិច្ចសន្យា អាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបាន ។ ប៉ុន្តែ ចំពោះផ្នែកដែលបានអនុវត្តហើយ មិនអាចដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបានឡើយ ។

**មាត្រា ៥៧១.-** ការលុបចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្ត ជាអាទិ៍

១-ក្នុងករណីដែលបដិគ្គាហកបានធ្វើអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរចំពោះទាយក ទាយកអាចលុបចោលប្រទានកម្មបាន ។

២-ចំពោះផ្នែកដែលបានអនុវត្តហើយ ការលុបចោលប្រទានកម្មដែលកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបានតែក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលមានអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរនោះ ។

**មាត្រា ៥៧២.-** ការលុបចោលប្រទានកម្មដោយសារភាពទីទ័លក្ររបស់ទាយក

១-ប្រសិនបើទាយកធ្លាក់ខ្លួនក្នុងស្ថានភាពទីទ័លក្រ មិនអាចរក្សាជីវភាពរស់នៅរបស់ខ្លួនផ្ទាល់ និង បុគ្គលដែលត្រូវមានអាហារកាតព្វកិច្ច ក្រោយពីបានបង្ហាញឆន្ទៈធ្វើប្រទានកម្មហើយ ទាយកអាចលុបប្រទានកម្មនោះចោលបាន ។

២-ចំពោះផ្នែកដែលបានអនុវត្តហើយ ការលុបចោលប្រទានកម្មដែលកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបានតែក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលបានអនុវត្ត ។

**មាត្រា ៥៧៣.-** អានុភាពនៃការលុបចោលប្រទានកម្ម

ក្នុងករណីដែលបានលុបចោលប្រទានកម្មតាមបញ្ញត្តិនៃមាត្រា ៥៧១ (ការលុបចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្ត ជាអាទិ៍) និង មាត្រា ៥៧២ (ការលុបចោលប្រទានកម្មដោយសារភាពទីទ័លក្ររបស់ទាយក) ខាងលើនេះ ទាយកអាចទាមទារឱ្យសងទ្រព្យសម្បត្តិដែលបានធ្វើប្រទានកម្មនោះ ដោយផ្អែកតាមបញ្ញត្តិស្តីពីការសងនៃសេចក្តីចម្រើនដោយឥតហេតុបាន ។

**មាត្រា ៥៧៤.-** ការបន្ធូរការទទួលខុសត្រូវក្នុងការធានា

ទាយក ពុំមានបន្ទុកទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈ ឬ ការខ្វះវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃប្រទានកម្មឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើទាយកបានដឹងអំពីវិការៈ ឬ ការខ្វះនោះហើយ តែមិនបានផ្តល់ដំណឹងទៅបដិគ្គាហក ។

**មាត្រា ៥៧៥.-** ប្រទានកម្មដោយមានកំណត់ពេល

ប្រទានកម្មដែលធ្វើឡើងក្នុងគោលបំណងផ្តល់តាវកាលិកដោយមានកំណត់ពេល ត្រូវបាត់បង់អានុភាព ដោយមរណភាពរបស់ទាយក ឬ បដិគ្គាហក ។

**មាត្រា ៥៧៦.-** ប្រទានកម្មដែលមានភ្ជាប់បន្ទុក

១-ប្រទានកម្ម ដែលបដិគ្គាហកមានករណីយកិច្ចត្រូវអនុវត្តការផ្តល់តាវកាលិកជាកំណត់ ដើម្បីទទួលទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃប្រទានកម្ម ត្រូវហៅថា ប្រទានកម្មដែលមានភ្ជាប់បន្ទុក ។

២-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយកត្រូវទទួលខុសត្រូវលើប្រាតិភោគដូចគ្នានឹងអ្នកលក់ផងដែរ ត្រឹមកម្រិតនៃបន្ទុកនោះ ។

៣-ក្នុងករណីដែលភាគីម្ខាងបានធ្វើការផ្តល់តាវកាលិក នៅក្នុងប្រទានកម្មដែល

មានភ្ជាប់បន្ទុក បុគ្គលនោះអាចទាមទារ ចំពោះភាគីម្ខាងទៀតឱ្យផ្តល់តាវកាលិកបាន ។

៤-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បើគ្មានកិច្ចសន្យាពិសេសទេ លុះត្រាតែភាគីម្ខាងមិនបានធ្វើការផ្តល់តាវកាលិកទេ ទើបភាគីម្ខាងទៀតនៃកិច្ចសន្យា អាចមិនផ្តល់តាវកាលិករបស់ខ្លួនបាន ។

៥-ទាយកនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក អាចរំលាយកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកនោះ តាមបញ្ញត្តិនៃការរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តបន្ទុក ។

**មាត្រា ៥៧៧.–** ប្រទានកម្មដោយមូលហេតុមរណភាព

១-ប្រទានកម្មដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក ត្រូវហៅថាប្រទានកម្មដោយមូលហេតុមរណភាព ។

២-បញ្ញត្តិនៃអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ។

## ជំពូកទី ៤
## ការខ្ចីបរិភោគ

### ផ្នែកទី ១
### និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

**មាត្រា ៥៧៨.–** និយមន័យនៃការខ្ចីបរិភោគ

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពី

# គន្ថីទី ៨
# សន្តតិកម្ម

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ការចាប់ផ្តើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.–** មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។

**មាត្រា ១១៤៦.–** ទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

### ផ្នែកទី ២
### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.–** ការទទួលបន្តនូវមត៌ក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

ដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

**មាត្រា ១១៤៨.–** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.–** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.-** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ ៖

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

**មាត្រា ១១៥១.-** ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ ៖

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មតិ៍កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មតិ៍ក នេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មតិ៍កនេះ នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១១៥២.–** ការផ្តាច់មតិ៍កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មតិ៍កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មតិ៍កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មតិ៍កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

**មាត្រា ១១៥៣.–** ការកាន់កាប់មតិ៍ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មតិ៍កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្តាច់មតិ៍កពីសន្តតិជន ដោយមតក-សាសន៍) ខាងលើនេះ កំពុងកាន់កាប់មតិ៍ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១១៥៤.–** ការលុបចោលនូវការផ្តាច់មតិ៍កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មតិ៍កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មតិ៍កពីសន្តតិជន ដោយមតកសាសន៍) ខាង

លើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិ-ជន ។

**មាត្រា ១១៥៥.-** ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ជាតិជាខ្មែរទេ មត៌កត្រូវបែងចែក ដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះត្រូវក្លាយជាមត៌ក ហើយនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ជាតិជាខ្មែរ ។ ក្នុងករណីនេះ នីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

# ជំពូកទី ២
# សន្តតិកម្មតាមច្បាប់

## ផ្នែកទី ១
## សន្តតិជន

**មាត្រា ១១៥៦.-** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.-** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៨.-** ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមត៌ក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួន

នោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

**មាត្រា ១១៥៩.–** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.–** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្ដាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្ដាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

# ផ្នែកទី ២
# សន្តតិកម្មរបស់សហព័ទ្ធ

**មាត្រា ១១៦១.-** សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៦២.-** ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុក ម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្តាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

# ផ្នែកទី ៣
# ការសម្រួលចំណែកមត៌ក

**មាត្រា ១១៦៣.–** ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

**មាត្រា ១១៦៤.–** តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

**មាត្រា ១១៦៥.-** ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថា-ខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

**មាត្រា ១១៦៦.-** ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយ

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

ចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.-** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.-** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.-** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.-** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.-** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.-** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។

**មាត្រា ១១៧៦.-** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.-** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៨.-** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការី ត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះ ក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.-** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សីគ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.-** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.-** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្គាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្តីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.-** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.-** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

**មាត្រា ១១៨៥.-** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.-** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.-** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

## ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.-** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្ដាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.-** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្ដាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតក-សាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.-** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្ដាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្ដាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.-** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្ដាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថា បានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្ដាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.-** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្ដាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.-** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្ដាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.-** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.-** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.-** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.-** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.-** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.-** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០២.-** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.-** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.-** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមតិក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមតិក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្ដាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្ដាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.-** ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមតិក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមតិក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.-** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.-** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

# ជំពូកទី ៤
# ភាគបម្រុង

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣០.–** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្ដាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្ដាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.–** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែល

ត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

**មាត្រា ១២៣២.–** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ :

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.–** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.-** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

## ផ្នែកទី ២
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.-** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

**មាត្រា ១២៣៦.-** លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

**មាត្រា ១២៣៧.-** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។

**មាត្រា ១២៤៧.-** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង របស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមាន ឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

# ជំពូកទី ៥

# ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.-** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយ កម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះ ខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការ យល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជន របស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

**មាត្រា ១២៥០.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.-** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.-** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.-** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.-** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមតិកនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតក-ជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយព្យាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.-** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមតិក តាមចំណែកមតិកនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.-** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.-** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ឧបសម្ព័ន្ធ ២

# ព្រះរាជក្រម

នស/រកម/០៥១១/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលរដ្ឋសភា បានអនុម័ត កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖



ROYAUME DU CAMBODGE

# ច្បាប់

# ស្តីពី

# ការអនុវត្តក្រមរដ្ឋប្បវេណី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) និង មាត្រា ៥១៣ (ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតខាងក្រោម ៖

ក-លិខិតយថាភូត ។

ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

ខ-លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។

ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

គ-លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព។

ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

ឃ-លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។

ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

### មាត្រា ៩.- អត្ថន័យនៃលិខិតយថាភូត

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតខាងក្រោម ៖

ក-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ ។

ខ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ (ការតាំងនៃហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសាក្សីជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និង មាត្រា ១១៨១ (បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ កុងស៊ុលតាមបញ្ញត្តិនៃមាត្រានីមួយៗ ខាងលើនេះ ។

## មាត្រា ១០.- ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវទទួលបន្ទុកកិច្ចការសារការីជាបណ្តោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេងនៅក្នុងច្បាប់មិនលើសពី ២ នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីរាជការសាធារណៈ ដែលមានបទពិសោធន៍ការងារផ្នែកវិស័យច្បាប់ និង មានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ។

២-ចៅក្រមដែលត្រូវបានកំណត់ថាជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវបានចាត់ទុកថា មានហេតុនៃការដកហូតសមត្ថកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្តីដែលខ្លួនបានចាត់ចែងកិច្ចការសារការី ។

៣-ចំពោះសារការី និងមន្ទីរសារការីដែលបានតែងតាំងនិងបង្កើតឡើងមុនច្បាប់នេះ ត្រូវបន្តមានសមត្ថកិច្ចបំពេញកិច្ចការសារការីស្របតាមក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ជាធរមាន ។

## មាត្រា ១១.- សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់នេះ ដូចជាការផ្តល់សេចក្តីបញ្ជាក់លើលក្ខន្តិកៈ ការធ្វើលិខិតយថាភូត ជាអាទិ៍ ជាបណ្តោះអាសន្ន ។

២-ដើម្បីធ្វើលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៩ (អត្ថន័យនៃលិខិតយថាភូត) នៃច្បាប់នេះ មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវពិនិត្យ និង បញ្ជាក់អត្តសញ្ញាណរបស់ភាគីដោយសាក្សី ឬ សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ហើយក្រៅពីនេះត្រូវធ្វើការចាត់ចែងដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។

៣-បុគ្គលដែលប្រើប្រាស់សេវារបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបង់ពន្ធ ។ ចំណូលពន្ធនេះត្រូវបង្វែរចូលទៅថវិកាជាតិ ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

៤-ការបង្កើតលិខិតយថាភូត ដែលត្រូវបានធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី ការប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ដែលមានអានុភាពដូចគ្នានឹងច្បាប់ដើមនៃលិខិតយថាភូត និងចំណុចចាំបាច់ផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៥-ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១២.- ការប្រកាសជាសាធារណៈ**

១-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ១៩១ (កម្មសិទ្ធិវត្ថុបាត់) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដែលកំណត់ក្នុងកថាខណ្ឌដដែលនោះ ដោយវិធីបិទប្រកាសដែលសរសេរអំពីប្រភេទ និង លក្ខណៈនៃវត្ថុរើស ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងដែលរើសវត្ថុនោះនៅកន្លែងបិទប្រកាសរបស់ប៉ុស្តិ៍នគរបាលនោះ ។

២-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) កថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) មាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍) ឬ កថាខណ្ឌទី ១ នៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈ ស្វែងរកសន្តតិជន) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

**មាត្រា ១៣.- សិទ្ធិរបស់កម្មសិទ្ធិករនៃដី**

១-ចំពោះកម្មសិទ្ធិលើដី "ការប្រើប្រាស់ និងការអាស្រ័យផលវត្ថុដែលជាកម្មសិទ្ធិ" ដែលកំណត់ក្នុងមាត្រា ១៣៨ (និយមន័យនៃកម្មសិទ្ធិ) នៃក្រមរដ្ឋប្បវេណី ត្រូវរួមបញ្ចូលការរៀបចំ ឬ ការកែប្រែដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធដើមនៃដី ស្របតាមការប្រើប្រាស់ដែលកម្មសិទ្ធិករចង់ធ្វើតាមការកំណត់នៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

២-ត្រូវចាត់ទុកជាការកែប្រែនូវប្រភេទ ឬ រចនាសម្ព័ន្ធដើមនៃដី ចំពោះការអនុវត្តកថាខណ្ឌទី ១ ខាងលើនេះ មានការគាស់រានដី ការកាប់ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីកយកដីចេញ ការជីកអណ្តូងរ៉ែ ឬ កន្លែងយកថ្ម ការរៀបចំ ឬ ការធ្វើឲ្យស្ងួតដែនរាំជាត ការរៀបចំដីកសិកម្មទៅជាដីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្ម និង ការបង្កើតទីតាំងរោងចក្រ ជាអាទិ៍ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ត្រូវកែពាក្យ "ខេត្ត ក្រុង" ទៅជា "រាជធានី ខេត្ត" នៅក្នុងចំណុច ខ នៃមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗ ទាក់ទងទៅនឹងកូន) ។

ត្រូវកែឃ្លា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល" ទៅជា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន" នៅក្នុងមាត្រា ១០៧៦ (បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ។

ត្រូវកែឃ្លា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ" ទៅជា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់អ្នកអាណាព្យាបាលទូទៅ" នៅក្នុងមាត្រា ១១១១ (បុគ្គលដែលមិន អាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) ។

ត្រូវកែឃ្លា "នៅមុនពេលចាប់ផ្តើមសន្តតិកម្ម" ទៅជា "នៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម" នៅក្នុងវាក្យខណ្ឌទី១ កថាខណ្ឌទី១ នៃមាត្រា១១៥៧ (សន្តតិកម្មជំនួស) ។

ត្រូវបន្ថែមឃ្លា "ចំពោះសន្តតិកម្មនោះ" បន្ទាប់ពីឃ្លា "បុគ្គលនោះមិនមែនជាសន្តតិជន" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៦១ (អានុភាពនៃការបោះបង់) ។

ត្រូវកែឃ្លា "ការបែងចែកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ" ទៅជា "ការបែងចែកត្រូវធ្វើទៅតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ដូចជាលិខិតជាលាយលក្ខណ៍អក្សរជាអាទិ៍" នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៦៦ (ការពិភាក្សាបែងចែកមរតក) ។

## មាត្រា ៨២.- ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់

ក្រមរដ្ឋប្បវេណីចាស់ ដែលបានអនុញ្ញាតប្រកាសឲ្យប្រើ ដោយព្រះមហាក្សត្រ នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩២០ និង ដែលត្រូវបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មិនមានអានុភាពឡើយ ។

## មាត្រា ៨៣.- អានុភាពនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត

ក្រៅពីច្បាប់ និង បទដ្ឋានគតិយុត្តដែលកំណត់ចាប់ពីមាត្រា ៧៨ (ការធ្វើឲ្យនិរាករនូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ) ដល់មាត្រា ៨២ (ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់) ច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតដែល មានអានុភាពនៅកាលបរិច្ឆេទនៃការអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងលែងមានអានុភាពត្រឹមទំហំ ដែលផ្ទុយនឹងក្រមរដ្ឋប្បវេណី ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

# ឧបសម្ព័ន្ធ ៣

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និងបណ្តឹងជិតចិត្ត) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានយកមកអនុវត្ត ដោយយោងតាមកថាខណ្ឌទី ១ ខាងលើនេះ ។

## ជំពូកទី ៣
## ជនពាក់ព័ន្ធ

### មាត្រា ១៥.- ជនពាក់ព័ន្ធ

ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ជនដាក់ពាក្យសុំ ភាគីម្ខាងទៀតនៃពាក្យសុំ និងជនផ្សេងទៀត ដែលទទួលឥទ្ធិពលផ្ទាល់ដល់សិទ្ធិរបស់ខ្លួន ឬ ដល់ឋានៈរបស់ខ្លួនតាមផ្លូវច្បាប់ដោយដីកាសម្រេចអំពីរឿងក្តីនោះ អាចចូលរួមក្នុងនីតិវិធីនៃរឿងក្តីនោះ ក្នុងនាមជាជនពាក់ព័ន្ធនៅក្នុងរឿងក្តីនោះ ។

### មាត្រា ១៦.- សមត្ថភាពរបស់ជនពាក់ព័ន្ធ

ជនដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) ខាងលើនេះ ត្រូវតែជាបុគ្គលដែលអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ។

### មាត្រា ១៧.- សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី

១- បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចធ្វើសកម្មភាពនៃនីតិវិធីចាំបាច់ ដោយតាំងខ្លួនជាជនពាក់ព័ន្ធក្នុងនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះបាន ។

២- អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើសកម្មភាពនៃនីតិវិធីសុពលបានឡើយ ប្រសិនបើសកម្មភាពនោះមិនបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបានកំណត់ខាងក្រោមនេះ ៖

ក- ករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ ។

ខ- ករណីដែលអនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើសកម្មភាពពាក់ព័ន្ធនឹងឋានៈរបស់ខ្លួន ។

៣- បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ត្រូវយកមកអនុវត្តចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ ខាងលើនេះ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

៤- បញ្ញត្តិចាប់ពីមាត្រា ៣៣ (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) ដល់មាត្រា ៣៨ (ការអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមត្ថភាពអាចធ្វើសកម្មភាពនៃនីតិវិធីសុពលក្នុងនាមជាជនពាក់ព័ន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ និង ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

**មាត្រា ១៨.- សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ**

១- ជនពាក់ព័ន្ធអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីទាំងអស់ ដោយខ្លួនឯងផ្ទាល់ ឬ ធ្វើសកម្មភាពនោះ ដោយឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង ។

២- ទោះបីជនពាក់ព័ន្ធបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ជននោះអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីបានដែរ ។

**មាត្រា ១៩.- លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ**

១- អ្នកតំណាងដោយអាណត្តិដែលកំណត់ក្នុងមាត្រា ១៨ (សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ត្រូវតែជាមេធាវី ឬ ជនដែលបានទទួលនូវការអនុញ្ញាតពីតុលាការ ។

២- តុលាការអាចលុបចោលការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដែលផ្តល់ជនក្រៅពីមេធាវីនៅពេលណាក៏បាន ។

**មាត្រា ២០.- ការបញ្ជាក់នូវសិទ្ធិតំណាងដោយអាណត្តិ**

សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ដែលត្រូវបានជ្រើសតាំងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១៨ (សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ) នៃច្បាប់នេះ ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះ

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការកំណត់អ្នកទទួលបន្តនូវសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ មាត្រា១១៤៧ (ការទទួលបន្តនូវមត៌ក) ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី៣ នៃកថាខណ្ឌដដែលនោះ | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២ ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន និងការលុបចោលនូវការផ្តាច់មត៌កនោះ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) មាត្រា១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) និងមាត្រា១១៥៤ (ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន) | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៣ ការបញ្ជាក់មតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម ឬលំនៅឋានរបស់ម្ចាស់បណ្តាំ |
| | ៤ ការលុបចោលអច្ច័យទាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៩៣ (ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៥ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២១៣ (ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៦ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២១៨ (ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៧ ការផ្តល់កម្រៃចំពោះអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិ នៃកថាខណ្ឌទី២ មាត្រា១២២៦ (កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៨ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកប្រតិបត្តិមតកសាសន៍ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២២៧ (ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៣១ (ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១០ ការអនុញ្ញាតឱ្យបោះបង់ភាគបម្រុង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៤៦ (ការបោះបង់ភាគបម្រុង) | តុលាការនៃលំនៅឋានរបស់មតកជន |
| | ១១ ការពន្យារអំឡុងពេលនៃការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ១២ ការទទួលពាក្យសុំលុបចោលការយល់ព្រមដោយមានកម្រិត ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា១២៥២(ការលុបចោលការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៣ ការទទួលពាក្យសុំយល់ព្រមសន្តតិកម្មដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៥៧ (វិធីនៃការយល់ព្រមដោយកម្រិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៤ ការទទួលពាក្យសុំបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៦០ (ការបោះបង់សន្តតិកម្ម) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៥ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៦ ការចាត់ចែងដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី ៣ មាត្រា ១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៧ ការបែងចែកមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៧០ (ការបែងចែកដោយតុលាការ) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៨ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២០ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៨៩ (ករណីដែលមានសន្តតិជនច្រើននាក់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២១ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២២ ការអនុញ្ញាតឱ្យចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩២ (សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៣ ការផ្តល់កម្រៃចំពោះអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩៣ (កម្រៃសម្រាប់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ២៤ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ឬកថាខណ្ឌទី១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១២៩៦ (ការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៥ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៦ ការចាត់ចែងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *